ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២០ លេខ ១ ខែមីនា ២០១៦ តម្លៃ ១.៥០០៛

# ការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅជនបទកម្ពុជា៖ ផលប៉ះពាល់លើទិន្នផលស្រូវ និងចំណូលពីផលដំណាំ

## សេចក្ដីផ្ដើម

តាំងពីដើមរៀងមក កសិកម្មជាវិស័យសំខាន់ជាងគេនៅក្នុងសេដ្ឋកិច្ចកម្ពុជា ដោយសារប្រជាជនភាគច្រើនលើសលុប រស់នៅតាមតំបន់ជនបទ។ ដីធ្លីនៅតែជាកត្តាស្នូលសម្រាប់ជីវភាពប្រជាជននៅជនបទ ព្រោះវាមិនត្រឹមតែជាប្រភពនៃសេដ្ឋកិច្ចចិញ្ចឹមពោះ និងសុវត្ថិភាពទ្រព្យធនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមធ្យោបាយដ៏សំខាន់មួយនៃការបង្កើនធនធានទៀតផង (Deininger and Binswanger 1999)។



សុវត្ថិភាពការកាន់កាប់ដីធ្លី សម្រួលដល់ការដាក់បញ្ចាំកម្ចី របររកស៊ី ធ្វើផ្ទះសម្បែង ទិន្នផលស្រូវ និងចំណូលពីផលដំណាំ ខេត្តកណ្ដាល ខែឧសភា ឆ្នាំ២០១៥

មកទល់ឆ្នាំ២០០១ ក្នុងចំណោមដីធ្លីនៅប្រទេសកម្ពុជាទាំងមូល មានត្រឹម ១០% ប៉ុណ្ណោះដែលមានប័ណ្ណកម្មសិទ្ធិ។ ហេតុនេះ នៅឆ្នាំ២០០២ រដ្ឋាភិបាលកម្ពុជា បានចាប់ផ្ដើមកម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធថ្មីមួយ ដោយមានជំនួយទ្រទ្រង់ពីដៃគូអភិវឌ្ឍន៍ ដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសផ្សេងៗ មានជាអាទិ៍ អាល្លឺម៉ង់ ស៊ុយអែត ដាណឺម៉ាក ជប៉ុន និង កូរ៉េខាងត្បូង (Thomson 2010)។ កិច្ចប្រឹងប្រែងចុះបញ្ជីដីធ្លី កំពុងដំណើរការទៅមុខនេះ សំដៅផ្ដល់នូវសន្តិសុខដីធ្លីឲ្យបានកាន់តែប្រសើរក្នុងទូទាំងប្រទេស និងជំរុញទីផ្សារដីធ្លីនៅជនបទ (Sar 2010)។ កម្មវិធីចុះបញ្ជីដីធ្លីថ្មីនេះ ក៏ជួយធ្វើឲ្យសាមញ្ញផងដែរនូវ នីតិវិធីចុះបញ្ជីដីធ្លីសម្រាប់ម្ចាស់ដីនានា។

ចំណុចសំខាន់មួយគួរស្វែងយល់ គឺការអនុវត្តការចុះបញ្ជីដីធ្លីជាផ្លូវការទ្រង់ទ្រាយធំ វាមានប៉ះពាល់បែបណាទៅលើផលិតភាពកសិកម្មនៅតំបន់ជនបទ។ ទោះបីពេលវេលាបានកន្លងទៅជិត ១៥ឆ្នាំហើយក្ដី ក៏ប្រធានបទនេះនៅតែមិនទាន់មានការសិក្សាស្រាវជ្រាវឲ្យបានគ្រប់គ្រាន់។ ការសិក្សានេះសំដៅពិនិត្យពីផលប៉ះពាល់នៃកម្មវិធីចុះបញ្ជីដីធ្លីនៅជនបទកម្ពុជា។ ការពិនិត្យជារួមពីលំនាំតាំងពីដើមរៀងមកនៃការកាន់កាប់ដីធ្លីនៅកម្ពុជា និងការសិក្សាដោយសង្ខេប លើឯកសារពាក់ព័ន្ធនឹងការកាន់កាប់ដី និងកម្មសិទ្ធិដី ជួយបង្ហាញពីសាវតាខ្លះៗ និងកត្តាជំរុញដល់ការសិក្សានេះ។ បន្ទាប់មកទៀត មានការបង្ហាញពីលទ្ធផលរកឃើញសំខាន់ៗ និងការពិភាក្សាពីឥទ្ធិពលនៃកម្មវិធីចុះបញ្ជីដីធ្លីទៅលើផលកសិកម្ម ហើយនៅផ្នែកចុងក្រោយ មានផ្ដល់នូវសេចក្ដីសន្និដ្ឋាន។

## សាវតានៃសិទ្ធិកាន់កាប់ដីធ្លី

មុនពេលស្ថិតក្រោមរបបអាណានិគមបារាំង ប្រជាជនទូទៅអាចកាន់កាប់ បន្តមរតក លក់ និងដាំដុះលើដីដោយជាក់ស្ដែង

អត្ថបទនេះ ចងក្រងឡើងដោយ ស្រី បុប្ផារ័ត្ន អ្នកស្រាវជ្រាវផ្នែកសេដ្ឋកិច្ច នៃ CDRI ដោយប្រើប្រាស់ព័ត៌មានបានពីការសិក្សារបស់ Sry (2013)។ សូមយោងឯកសារនេះថា៖ Sry Bopharath. 2016. “On Systematic Land Titling in Rural Cambodia: Its Impact on Rice Yield and Crop Revenue.” *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* 20(1): 1-5. ភ្នំពេញ វិទ្យាស្ថាន CDRI។

## មាតិកា

ការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅជនបទកម្ពុជា៖ ផលប៉ះពាល់លើទិន្នផលស្រូវ និងចំណូលពីផលដំណាំ ............................ ១
ការវិភាគផ្អែកតាមបទពិសោធន៍ជាក់ស្ដែងលើ កត្តាកំណត់ការជ្រើសយកប្រភេទផ្សេងៗនៃសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ នៅតំបន់ជនបទក្នុងប្រទេសកម្ពុជា ......... ៦
ឧបសគ្គរារាំងការលើកកម្ពស់រូបិយវត្ថុក្នុងស្រុក៖ ការសិក្សាប្រៀបធៀបនឹងប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ ............... ១៣
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ...................... ១៩
– ស្ថានភាពក្នុងប្រទេស........................ ២១
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ......................................... ២៨

បាន ប៉ុន្តែដីទាំងអស់ជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ ហើយមិនមានការចុះបញ្ជីជាផ្លូវការនូវសិទ្ធិកាន់កាប់ដីឯកជនឡើយ។ នៅជិតចុងសតវត្សរ៍ទី១៩ បារាំងបានចាប់ផ្តើមរៀបចំឲ្យមានច្បាប់គ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លី ដើម្បីកាត់បន្ថយអំណាចព្រះមហាក្សត្រ និងបង្កើតចំណូលពន្ធ (Chandler 2008, 174)។ ច្បាប់ភូមិបាលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៨៨៤ ប៉ុន្តែ រហូតដល់ទសវត្សរ៍១៩៣០ ទើបមានការដាក់អនុវត្តជាក់ស្តែង ដោយនៅពេលនោះ ដីស្រែភាគច្រើន ត្រូវបានចុះបញ្ជីជាទ្រព្យឯកជន ហើយម្ចាស់ដីអាចលក់ដីរបស់ខ្លួនដោយពេញសិទ្ធិបាន។

ក្រោយកម្ពុជាទទួលបានឯករាជ្យ ប្រព័ន្ធចុះបញ្ជីដីធ្លីខាងលើនេះបានបន្តអនុវត្តរហូតដល់ឆ្នាំ១៩៧៥។ ជំរឿនថ្នាក់ជាតិ ឆ្នាំ១៩៦២ មានកត់ត្រានូវ ក្បាលដីកសិកម្ម ៨០០.០០០ឡូត៍ ដែលក្នុងនោះ ៨៤% ជាកម្មសិទ្ធិឯកជន (Sar 2010)។ នៅក្រោមរបបសមូហភាពជ្រុលនិយម តម្រូវឡើងដោយខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ (Frings 1994) កម្មសិទ្ធិដីឯកជនត្រូវបានលុបចោល ហើយឯកសារដីធ្លីភាគច្រើនត្រូវបំផ្លាញអស់ (Hap 2010)។ ទោះយ៉ាងណាក្តី ការជំនួសកម្មសិទ្ធិឯកជនដោយកម្មសិទ្ធិសមូហភាពនេះ មានអាយុកាលខ្លីណាស់។ តម្រូវការសេរីភាវូបនីយកម្មសេដ្ឋកិច្ចកាន់តែលេចច្បាស់ឡើង នាំឲ្យមានការបង្កើតច្បាប់អនុញ្ញាតកម្មសិទ្ធិឯកជនលើអចលនទ្រព្យវិញ នៅឆ្នាំ១៩៨៩ (Gottesman 2004)។ នៅឆ្នាំ១៩៩២ មានការធ្វើកំណែទម្រង់ច្បាប់ភូមិបាលឆ្នាំ១៨៨៤ ប៉ុន្តែក្នុងនោះ មិនមានសេចក្តីចែងពីប្រព័ន្ធគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព ឬក៏ព័ត៌មានសព្វគ្រប់ស្តីពីកម្មសិទ្ធិឯកជននោះទេ។ ទោះបីមានការបង្កើតរបបប្រជាធិបតេយ្យថ្មីនៅឆ្នាំ១៩៩៣ ក្តី ក៏មិនមានកំណែទម្រង់ដីធ្លីតាមផ្លូវច្បាប់ជាដុំកំភួនបន្ថែមអ្វីទៀតទេ គឺរហូតដល់ឆ្នាំ២០០១ ទើបមានការអនុម័តវិសោធនកម្មលើច្បាប់ភូមិបាល។

វិសោធនកម្មច្បាប់ភូមិបាលឆ្នាំ២០០១ បានបែងចែកកម្មសិទ្ធិដីធ្លីជាបីប្រភេទ៖ កម្មសិទ្ធិរដ្ឋ កម្មសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាព។ ដីរដ្ឋ រួមមាន ដីទាំងអស់ដែលមិនត្រូវបានបែងចែកទៅឲ្យឯកជន។ ដីរដ្ឋមានពីរប្រភេទ៖ ដីសាធារណៈរបស់រដ្ឋ (សម្រាប់ផលប្រយោជន៍សាធារណៈ) និងទ្រព្យឯកជនរបស់រដ្ឋ (កាន់កាប់ដោយរដ្ឋ)។ ដីសាធារណៈរបស់រដ្ឋ សម្រាប់ប្រើជាផលប្រយោជន៍សាធារណៈ និងរួមមាន បឹង ទន្លេ ស្ទឹង ដីព្រៃ តំបន់អភិរក្សធម្មជាតិ តំបន់បុរាណវិទ្យា តំបន់វប្បធម៌និងបេតិកភ័ណ្ឌ និងអគារសាធារណៈ ដូចជា មន្ទីរពេទ្យ សាលារៀន និងអគាររដ្ឋបាល ជាដើម។ ទ្រព្យឯកជនរបស់រដ្ឋ អាចលក់ដោះដូរ ឬជួលបាន ហើយអាចប្រើប្រាស់សម្រាប់ជាកម្មវត្ថុនៃកិច្ចសន្យាស្របច្បាប់ទាំងឡាយ ដូចជា សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គម រហូតដល់ ៩៩ឆ្នាំ (Cambodian Center for Human Rights 2013)។ ទ្រព្យឯកជន អាចប្រើសម្រាប់ផលិតកម្មដំណាំ ឬការស្នាក់នៅជាលក្ខណៈបុគ្គល ហើយអាចជាកម្មសិទ្ធិបុគ្គល ឬកម្មសិទ្ធិរួមគ្នា។ ផ្អែកតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ២៣ ដីទ្រព្យសមូហភាព រួមមាន ដីវត្តអារាម និងដីរបស់សហគមន៍ប្រជាជនដើមដែល "រស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព" (CDC, CIB and CSEZB 2016)។

ការចុះបញ្ជីដីធ្លីនៅកម្ពុជា ចែកចេញជាពីរប្រភេទ៖ លក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ អនុវត្តឡើងមួយភូមិម្តងៗ តាមក្របខ័ណ្ឌពេលវេលាជាក់លាក់មួយ ចំណែកឯការចុះបញ្ជីដាច់ដោយដុំ អាចឲ្យបុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីដីនៅពេលណាក៏បាន។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ហើយការចុះបញ្ជីដីធ្លីដាច់ដោយដុំ ធ្វើឡើងតាមសំណើរបស់ម្ចាស់ដីនីមួយៗ។

រូបភាព១៖ នីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

**១. ការផ្សព្វផ្សាយព័ត៌មានពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅភូមិគោលដៅ**
ម្ចាស់ដីទាំងអស់ត្រូវចូលរួមក្នុងព្រឹត្តិការណ៍នេះ

↓

**២. នីតិវិធីបច្ចេកទេស**
អ្នកស្រុកត្រូវយល់ស្របជាមួយអ្នកជិតខាងខ្លួន លើព្រំដី និងបង្គោលកំណត់ព្រំដី មុនពេលមន្ត្រីសុរិយោដីចុះមកពិនិត្យ។ មន្ត្រីសុរិយោដី វាស់វែងដី និងកត់ត្រាព័ត៌មានសំខាន់ៗទាំងអស់។ ម្ចាស់ដីផ្តិតមេដៃលើឯកសារនៃកិច្ចព្រមព្រៀងលើការវាស់វែងដី នៅចំពោះមុខមន្ត្រីសុរិយោដី។

↓

**៣. ការដាក់បង្ហាញជាសាធារណៈ**
ម្ចាស់ដីទាំងអស់ ត្រូវពិនិត្យផ្ទៀងផ្ទាត់លើទំហំដី ឈ្មោះ និងប្រភេទនៃទ្រព្យសម្បត្តិ។ ប្រសិនបើព័ត៌មានមិនត្រឹមត្រូវទេ ពួកគេត្រូវដាក់ពាក្យបណ្តឹង ឬស្នើឲ្យក្រុមការងាររដ្ឋបាលកែតម្រូវឯកសារដែលត្រូវដាក់បង្ហាញជាសាធារណៈក្នុងរយៈពេលយ៉ាងហោចណាស់ ៣០ថ្ងៃ។

↓

**៤. សេចក្តីសម្រេច**
បន្ទាប់ពីបានដាក់បង្ហាញពីស្ថានភាពដីជាសាធារណៈរួចមក ក្រុមការងាររដ្ឋបាលត្រូវផ្ញើឯកសារទៅអភិបាលខេត្ត/ក្រុងដើម្បីអនុម័ត។

↓

**៥. ការចេញប័ណ្ណ**
ក្រោយដំណើរការនេះបានចប់សព្វគ្រប់ មានការរៀបចំពិធីដើម្បីប្រគល់ប័ណ្ណកម្មសិទ្ធិដីទៅឲ្យម្ចាស់ដី។

ប្រភព៖ MLMUPC 2013

## ការសិក្សាលើឯកសារពាក់ព័ន្ធ

ទ្រឹស្តីសេដ្ឋកិច្ច Neoclassical economic theory បានកំណត់ថា ចំណែកដីដែលគ្មានការទទួលស្គាល់តាមផ្លូវច្បាប់ជាផ្លូវការ គឺដូចជា "មូលធនងាប់" (Soto 2000)។ ដីកម្មសិទ្ធិឯកជន គួរតែធ្វើការចុះបញ្ជី ដើម្បីផ្លាស់ប្តូរមូលធនងាប់នេះ ឲ្យទៅជាមូលធនរស់វិញ។ Soto (2000) បានលើកនូវហេតុផលបីសម្រាប់ការចេញប័ណ្ណដីធ្លីស្របច្បាប់ឲ្យទៅប្រជាជនក្រីក្រ។ ទី១ ប្រជាជនត្រូវការនូវអារម្មណ៍មានសុវត្ថិភាពក្នុងការកាន់កាប់ដីរបស់ខ្លួន ទើបអាច

រូបភាព២៖ នីតិវិធីចុះបញ្ជីដីធ្លីដាច់ដោយដុំ




ប្រភព៖ Torhonen 2001

ធ្វើវិនិយោគទៅលើអាជីវកម្ម និងផ្ទះសម្បែងរបស់ខ្លួន។ ទី២ ការកាន់កាប់ដីស្របច្បាប់ វាកែប្រែដីឲ្យទៅជាទ្រព្យអាចដោះដូរបាន ដែលអាចប្រើប្រាស់ជាវត្ថុដាក់ធានា ដើម្បីយកប្រាក់កម្ចី។ ទី៣ តាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ការផ្តល់ប័ណ្ណកម្មសិទ្ធិគ្មានកាលកំណត់ ជួយឲ្យប្រទេសកំពុងអភិវឌ្ឍន៍អាចចេញផុតពីភាពក្រីក្រ។ ជាលទ្ធផល ប្រទេសជាច្រើន បានអនុវត្តកម្មវិធីចុះបញ្ជីដីធ្លី។ ការសិក្សាស្រាវជ្រាវជាក់ស្តែងមួយចំនួន រកឃើញថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ជួយបង្កើនផលកសិកម្ម វិនិយោគ និងការប្រើឥណទាន ប៉ុន្តែការសិក្សាខ្លះទៀតរកឃើញថា វាគ្មានឥទ្ធិពលសោះ ឬផ្តល់នូវលទ្ធផលចម្រុះ។

ឧទាហរណ៍ ដោយប្រើវិធីសាស្ត្រ difference-in-differences ដើម្បីវាយតម្លៃលើ កម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅប្រទេសប៉េរូ ពីឆ្នាំ១៩៩៤ ដល់ ២០០០ នោះ Fort (2007) បានរកឃើញឥទ្ធិពលវិជ្ជមាននៃកម្មវិធីនេះ ទៅលើការធ្វើវិនិយោគជាលក្ខណៈបុគ្គល។ ស្រដៀងគ្នាដែរ Deininger and Jin (2006) បានបង្ហាញពី ឥទ្ធិពលវិជ្ជមាននៃកម្មសិទ្ធិដីធ្លី ទៅលើការធ្វើវិនិយោគនៅប្រទេសអេត្យូពី។ នៅវៀតណាម Do និង Iyer (2008) រកឃើញថា កំណែទម្រង់ដីធ្លីតាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ វាជះឥទ្ធិពលទៅលើ ការសម្រេចចិត្តធ្វើវិនិយោគរយៈពេលវែងរបស់គ្រួសារ ទៅក្នុងវិស័យកសិកម្ម។

ផ្ទុយមកវិញ Borrows and Roth (1990) រកឃើញថា មិនមានភាពខុសគ្នាអ្វីគួរឲ្យកត់សំគាល់នៅក្នុងវិនិយោគ និងផលិតភាព រវាងដីមានប័ណ្ណ នឹងដីមិនមានប័ណ្ណកម្មសិទ្ធិ នៅប្រទេសកេនយ៉ា អ៊ូហ្គង់ដា និងហ្ស៊ីមបាវ៉េ នោះទេ។ ពួកគេ លើកឡើងថា ការផ្គត់ផ្គង់ និងតម្រូវការវិនិយោគ មានកម្រិតទាប ដោយសារភាពមានខ្វះនៃទីផ្សារ និងបន្តទៀតថា វិនិយោគអាចត្រូវរាំងស្ទះ ដោយសារកង្វះវិធានច្បាប់សម្រាប់ការពារសិទ្ធិបុគ្គលក្នុងការទទួលបាន និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន។

ឯកសារពាក់ព័ន្ធនានា ផ្តល់នូវភស្តុតាងខ្លះៗពី ផលប៉ះពាល់វិជ្ជមាននៃប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ ទៅលើវិនិយោគ។ ការសិក្សាដោយ Markus and Udry (2008) នៅប្រទេសហ្គាណា រកឃើញថា ការកាន់កាប់ដីមានសុវត្ថិភាព វាជះឥទ្ធិពលទៅលើការធ្វើវិនិយោគលើដីធ្លី និងលើដីជាតិដី។ នៅប្រេស៊ីល ការមានប័ណ្ណកម្មសិទ្ធិដីផ្លូវការ មានទំនាក់ទំនងជាមួយកំណើនវិនិយោគលើដីធ្លី និងកំណើនថ្លៃដី (Alston, Libecap and Schneider 1996)។ Galiani and Schargrodsky (2010) បានបង្ហាញពី

បែបបទដែលប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង ជំរុញឲ្យមានការធ្វើវិនិយោគទៅលើ ផ្ទះសម្បែង។ ការសិក្សាស្រាវជ្រាវរបស់ Markussen (2008) នៅកម្ពុជា បង្ហាញថា សិទ្ធិលើទ្រព្យសម្បត្តិមានឥទ្ធិពលវិជ្ជមាន និង មានទំនាក់ទំនងជាមួយផលិតភាពកសិកម្ម និងថ្លៃដី។

## វិធីសាស្ត្រសិក្សាស្រាវជ្រាវ

### *ទិន្នន័យ និងស្ថិតិបែបពណ៌នា*

ការសិក្សានេះ ប្រើទិន្នន័យបានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ និង ២០០៨ និងព័ត៌មានបានពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ទាក់ទងនឹងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុង ៣៣៨ភូមិ ពីឆ្នាំ២០០៤ ដល់ ២០០៨។

បណ្ដាក្រុមបានយកមកសិក្សា គឺមាន ភូមិដែលគេបានចេញប័ណ្ណកម្មសិទ្ធិដីឲ្យពីឆ្នាំ២០០៥ ដល់ ២០០៧ ហើយក្រុមទុកសម្រាប់ប្រៀបធៀប (control group) គឺភូមិទាំងឡាយដែលមិនស្ថិតក្នុងកម្មវិធីចុះបញ្ជីដីធ្លី។ បន្ទាប់ពីបានរៀបចំឲ្យមានតុល្យភាពគ្នាក្នុងលក្ខណៈសំគាល់សំខាន់ៗនៃក្រុមទាំងពីរមក ការសិក្សាបានសម្រេចជ្រើសយក ១៤ភូមិត្រូវសិក្សា (១២៩គ្រួសារ) និង ១៤៨ភូមិទុកសម្រាប់ប្រៀបធៀប (១៧៧៥គ្រួសារ)។ គ្រួសារប្រហែល ៨០% មានមេគ្រួសារជាបុរស ហើយអាយុមធ្យមនៃមេគ្រួសារគឺ ៤៦ឆ្នាំ។ អត្រាសមាជិកក្នុងបន្ទុកគឺ ៧៨% ដែលខ្ពស់ជាខ្លាំង។ គ្រួសារនីមួយៗមានដីកសិកម្មជាមធ្យម ០,៦ហិកតា ដែលភាគច្រើនជាដីសើម និងទទួលបានទិន្នផលស្រូវ ១,៦តោន/ហិកតា (តារាង១)។

### *ការធ្វើម៉ូដែលពីផលិតភាពកសិកម្ម និងផលប៉ះពាល់លើប្រាក់ចំណូល (សូមមើលឯកសារជាភាសាអង់គ្លេស)*

## លទ្ធផលរកឃើញជាក់ស្ដែង

ឥទ្ធិពលរំពឹងទុកដ៏សំខាន់មួយនៃ កម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺកំណើនផលិតភាពកសិកម្ម។ លទ្ធផលរកឃើញជាក់ស្ដែង មិនមានផ្ដល់ភស្តុតាងអ្វីថា កម្មវិធីចុះបញ្ជីដីធ្លីមានជះឥទ្ធិពលវិជ្ជមានទៅលើទិន្នផលស្រូវ និងចំណូលពីផលដំណាំនោះទេ។

## សេចក្ដីសន្និដ្ឋាន

លទ្ធផលនៃការសិក្សានេះ មិនគាំទ្រដល់សម្មតិកម្មថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ វាមានផលប៉ះពាល់វិជ្ជមានទៅលើផលកសិកម្មនៃក្បាលដីនីមួយៗ ដូចមានលើកឡើងនៅក្នុងឯកសារពាក់ព័ន្ធជាច្រើនទៀតនោះទេ។ កម្មវិធីចុះបញ្ជីដីធ្លី ហាក់មិនមានរួមចំណែកអ្វីគួរឲ្យកត់សំគាល់ឡើយ នៅក្នុងកំណើនផលិតភាពកសិកម្មនៅកម្ពុជា។

បើគិតតាមលទ្ធផលអាចមើលឃើញ ការមិនសម្រេចបានតាមការរំពឹងទុក អាចគួរឲ្យខកចិត្តដែរ។ បទពិសោធន៍នៅកម្ពុជា មិនខុសគ្នាអ្វីច្រើនពីនៅ កេនយ៉ា អ៊ូហ្គង់ដា និង ហ្ស៊ីមបាវេ ទេ ព្រោះនៅប្រទេសទាំងនោះ កំណែទម្រង់ដីធ្លី ក៏មានផលប៉ះពាល់តិចតួចទៅលើផលិតកម្មកសិកម្មដែរ (Borrows and Roth 1990)។ ទោះបីជាកម្មវិធីនេះ បានអនុវត្តជាបន្តបន្ទាប់ តាំងពីឆ្នាំ២០០២មកក្ដី ក៏ការចេញប័ណ្ណកម្មសិទ្ធិដីជាផ្លូវការនៅជនបទកម្ពុជា នៅមានកម្រិតនៅឡើយ។ ដូច្នេះ គួរបង្កើនល្បឿនចុះបញ្ជីដីធ្លី ជាពិសេសសម្រាប់ម្ចាស់ដីតូចៗ ដើម្បីពង្រីកកម្មសិទ្ធិដីធ្លី និងពង្រឹងអត្ថប្រយោជន៍នៃការកាន់កាប់ដីមានសុវត្ថិភាព។

ទំនាក់ទំនងរវាងកម្មសិទ្ធិដីធ្លី នឹងកំណើនវិស័យកសិកម្ម ជាវិស័យថ្មីមួយសម្រាប់ការសិក្សាស្រាវជ្រាវនៅកម្ពុជា ហើយចំណេះដឹងដែលមានការសិក្សាស្រាវជ្រាវបញ្ជាក់គាំទ្រ គឺនៅមានកម្រិតនៅឡើយ។ កិច្ចប្រឹងប្រែងសិក្សាស្រាវជ្រាវទៅថ្ងៃអនាគត គួរមានការសិក្សាដោយប្រើទិន្នន័យបានពី អង្កេតនៅត្រង់ចំណុចមួយនៃពេលវេលា (cross sectional study) ក្នុងរយៈពេលមួយវែងគ្រប់គ្រាន់។

## ឯកសារយោង


Alston, L., D.G. Libecap and R. Schneider. 1996. “The Determinants and Impact of Property Rights: Land Titles on the Brazilian Frontier.” *The Journal of Law, Economics and Organization* 12(1): 25-61.

Angrist, D.J., and S.J. Pischke. 2009. *Mostly Harmless Economictrics: An Empiricist’s Companion.* New Jersey: Princeton University Press.

Borrows, R., and M. Roth. 1990. “Land Tenure and Investment in African Agriculture: Theory and Evidence.” *The Journal of Modern African Studies* 28(2): 265-297.

Cambodia Center for Human Rights. 2013. *Cambodia: Land in Conflict: An Overview of the Land Situaton.* Phnom Penh: Cambodia Center for Human Rights.

CDC, CIB and CSEZB. 2016. “Land Law.” Accessed 9 May 2016, www.cambodiainvestment .gov.kh/land-law_010430.html.

Chandler, D. 2008. *A History of Cambodia* (4th ed.). Boulder, CO: Westview.

Deininger, K., and H. Binswanger. 1999. “The Evolution of the World Bank’s Land Policy: Principles, Experience, and Future Challenges.” *The World Bank Research Observer* 14(2): 247-76.

Deininger, K., and S. Jin. 2006. Tenure Security and Land-Related Investment: Evidence from Ethiopia. *European Economic Review* 50:1245-1277.

Do, T.Q., and L. Iyer. 2008. Land Titling and Rural Transition in Vietnam. *Economic Development and Cultural Change* 56(3): 531-579.

Fort, R. 2007. *Property Rights after Market Liberalization Reforms: Land Titling and Investments in Rural Peru.* Wageningen: Wageningen Academic Publishers.

Frings, V. 1994. 1994. “Cambodia after Decollectivation (1989-1992). *Journal of Contemporary Asia* 24(1): 49-66.

Galiani, S., and E. Schargrodsky. 2010. “Property Rights for the Poor: Effects of Land Titling.” *Journal of Public Economics* 94(9-10): 700-729.

Gottesman, E. 2004. *Cambodia after the Khmer Rouge: Inside the Politics of Nation Building.* London: Yale University Press.

Hap, P. 2010.” Implementation of Cambodia’s Laws on Land Tenure.” Doctoral dissertation, Nagoya University.


តទៅទំព័រ ១០

## ឧបសម្ព័ន្ធ

តារាង A1៖ អថេរពណ៌នាសំខាន់ៗ ឆ្នាំ២០០៤ និង ២០០៨

| ក្រុមទុកសម្រាប់ប្រៀបធៀប | | | | | 2004 & 2008 |
|---|---|---|---|---|---|
| | មធ្យម (mean) | គម្លាតស្តង់ដា | អប្បបរមា | អតិបរមា | ចំនួន |
| ភេទមេគ្រួសារ (1=បុរស) | 0.81 | 0.40 | - | - | 2638 |
| អាយុមេគ្រួសារ (ឆ្នាំ) | 46.19 | 13.98 | 19 | 88 | 2638 |
| មេគ្រួសារចេះអាន និងសរសេរ (%) | 0.69 | 0.47 | - | - | 2638 |
| ទំហំគ្រួសារ (នាក់) | 4.95 | 1.96 | 1 | 14 | 2638 |
| អត្រាសមាជិកក្នុងបន្ទុក (%) | 0.78 | 0.69 | 0 | 5 | 2611 |
| កម្ចីផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.12 | 0.32 | - | - | 2638 |
| កម្ចីក្រៅផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.28 | 0.44 | - | - | 2638 |
| ទំហំក្បាលដី (ហិកតា) | 0.70 | 0.91 | 0.001 | 15 | 5221 |
| ផលិតកម្មស្រូវ (តោន/ហិកតា) | 1.74 | 1.08 | 0 | 5 | 3051 |
| ចំណូល (ដុល្លារ/ហិកតា) | 388.70 | 498.01 | 0 | 8981.35 | 5145 |
| ប្រភេទដី (ហិកតា) | | | | | |
| ដីសើម | 0.48 | 0.50 | - | - | 5221 |
| ដីស្ងួត | 0.15 | 0.35 | - | - | 5221 |
| ទាំងដីសើម និងស្ងួត | 0.04 | 0.19 | - | - | 5221 |
| **ចំការ** | 0.24 | 0.42 | - | - | 5221 |
| សួនបន្លែ | 0.03 | 0.17 | - | - | 5221 |
| ផ្សេងទៀត | 0.08 | 0.26 | - | - | 5221 |
| ដីស្រោចស្រព (ហិកតា) | 0.45 | 0.49 | - | - | 5221 |
| គម្រោងក្នុងភូមិ (% នៃគម្រោងសរុប) | | | | | |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍកសិកម្ម | 0.10 | 0.30 | - | - | 293 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.23 | 0.42 | - | - | 293 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍទឹក | 0.09 | 0.28 | - | - | 293 |
| NGO៖ ការអភិវឌ្ឍកសិកម្ម | 0.14 | 0.34 | - | - | 293 |
| NGO៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.11 | 0.30 | - | - | 293 |
| NGO៖ ការអភិវឌ្ឍទឹក | 0.08 | 0.28 | - | - | 293 |
| រដ្ឋាភិបាល៖ ជំនួយបច្ចេកទេសដាំដំណាំ សត្វចិញ្ចឹម ឬនេសាទ | 0.10 | 0.20 | - | - | 293 |

| អថេរក្រុមយកមកសិក្សា | | | | | 2004 & 2008 |
|---|---|---|---|---|---|
| | មធ្យម (mean) | គម្លាតស្តង់ដា | អប្បបរមា | អតិបរមា | ចំនួន |
| ភេទមេគ្រួសារ (1=បុរស) | 0.80 | 0.41 | - | - | 197 |
| អាយុមេគ្រួសារ (ឆ្នាំ) | 45.36 | 14.45 | 21 | 85 | 197 |
| មេគ្រួសារចេះអាន និងសរសេរ (%) | 0.78 | 0.42 | | | 197 |
| ទំហំគ្រួសារ (នាក់) | 4.77 | 1.73 | 1 | 12 | 197 |
| អត្រាសមាជិកក្នុងបន្ទុក (%) | 0.79 | 0.69 | 0 | 4 | 194 |
| កម្ចីផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.19 | 0.39 | - | - | 197 |
| កម្ចីក្រៅផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.26 | 0.44 | - | - | 197 |
| ទំហំក្បាលដី (ហិកតា) | 0.55 | 1.28 | 0.003 | 16 | 411 |
| ផលិតកម្មស្រូវ (តោន/ហិកតា) | 1.52 | 0.71 | 0 | 5 | 242 |
| ចំណូល (ដុល្លារ/ហិកតា) | 370.33 | 504.77 | 0 | 6150.06 | 381 |
| ប្រភេទដី (ហិកតា) | | | | | |
| ដីសើម | 0.60 | 0.48 | - | - | 411 |
| ដីស្ងួត | 0.07 | 0.25 | - | - | 411 |
| ទាំងដីសើម និងស្ងួត | 0.03 | 0.16 | - | - | 411 |
| **ចំការ** | 0.11 | 0.31 | - | - | 411 |
| សួនបន្លែ | 0.01 | 0.11 | - | - | 411 |
| ផ្សេងទៀត | 0.20 | 0.37 | - | - | 411 |
| ដីស្រោចស្រព (ហិកតា) | 0.32 | 0.47 | - | - | 411 |
| គម្រោងក្នុងភូមិ (% នៃគម្រោងសរុប) | | | | | |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍកសិកម្ម | 0.15 | 0.36 | - | - | 27 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.34 | 0.49 | - | - | 27 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍទឹក | 0.11 | 0.33 | - | - | 27 |
| NGO៖ ការអភិវឌ្ឍកសិកម្ម | 0.22 | 0.44 | - | - | 27 |
| NGO៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.11 | 0.33 | - | - | 27 |
| NGO៖ ការអភិវឌ្ឍទឹក | 0.19 | 0.40 | - | - | 27 |
| រដ្ឋាភិបាល៖ ជំនួយបច្ចេកទេសដាំដំណាំ សត្វចិញ្ចឹម ឬនេសាទ | 0.18 | 0.25 | - | - | 27 |

សម្គាល់៖ ១ដុល្លារ = ៤០៦៥រៀល ក្នុងឆ្នាំ២០០៨។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងឆ្នាំ២០០៤ = ៨១ និង ក្នុងឆ្នាំ២០០៨ = ១៦៦ (សន្ទស្សន៍គោលឆ្នាំ២០០៦ = ១០០)។

# ការវិភាគផ្អែកតាមបទពិសោធន៍ជាក់ស្តែង លើកត្តាកំណត់ការជ្រើសយកប្រភេទផ្សេងៗនៃ សកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ នៅតំបន់ជនបទក្នុងប្រទេសកម្ពុជា

## សេចក្តីផ្តើម

នៅកម្ពុជា ប្រជាជនក្រីក្រ និងងាយរងគ្រោះជាងគេភាគច្រើនរស់នៅតំបន់ជនបទ និងមានជីវភាពពឹងផ្អែកលើវិស័យកសិកម្ម។ វិស័យកសិកម្មបានផ្លាស់ប្តូរយ៉ាងខ្លាំងក្នុង ១៥ឆ្នាំចុងក្រោយនេះ ប៉ុន្តែនៅតែមិនទាន់ស្រូបយកអស់នូវកម្លាំងពលកម្មក្នុងជនបទ ឬបង្កើតការងារឲ្យបានគ្រប់គ្រាន់ ហើយនាពេលបច្ចុប្បន្ន បានផ្តល់ការងារឲ្យមិនដល់ ៦០% នៃកម្លាំងពលកម្មនៅជនបទនោះទេ (CDRI 2013)។

បញ្ហាចម្បងដែលវិស័យកសិកម្មកំពុងប្រឈមមុខគឺ ផលិតភាពទាប សេវាផ្សព្វផ្សាយបច្ចេកទេសនៅមានកម្រិត ភាពទន់ខ្សោយនៃម្ចាស់ដីតូចៗក្នុងការចូលរួមក្នុងទីផ្សារ ផលិតកម្មពឹងលើធាតុអាកាស ការប្រែប្រួលអាកាសធាតុ និងកំណើនភាពគ្មានដីធ្លី។ ម៉្យាងការធ្វើកសិកម្មតាមរដូវកាល តម្រូវឲ្យកសិករស្វែងរកការងារក្រៅពីស្រែចំការផ្ទាល់ខ្លួន នៅពេលផុតរដូវដាំដុះ។ ដូច្នេះ ជីវភាពពឹងផ្អែកលើកសិកម្ម និងងាយរងគ្រោះស្រាប់នេះ វាកាន់តែមិននឹងន និងមានហានិភ័យច្រើនឡើង ក្នុងអំឡុងពេលមិនសូវមានការងារធ្វើ។

ដើម្បីកាត់បន្ថយភាពងាយរងគ្រោះក្នុងជីវភាព ហើយអាចទប់ទល់នឹងហានិភ័យក្នុងវិស័យកសិកម្ម ប្រជាជននៅជនបទជាច្រើន ជាពិសេសម្ចាស់ដីតូចៗ និងគ្រួសារគ្មានដីធ្លី ត្រូវចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ (ការងារមានប្រាក់កម្រៃ និង/ឬអាជីវកម្មផ្ទាល់ខ្លួន) ក្នុងវិស័យកសិកម្ម ឬវិស័យមិនមែនកសិកម្ម។ ប៉ុន្តែនៅតាមមូលដ្ឋាន ឱកាសការងារនៅមានតិច ព្រោះមិនទាន់មានសហគ្រាសខ្នាតតូច និងមធ្យម (SMEs) ដោយសារ តំបន់ជនបទមានកំណើនសេដ្ឋកិច្ចស្ពឹកយឺតយ៉ាវ។ ស្ថានភាពនេះ បានជំរុញឲ្យអ្នកនៅជនបទធ្វើចំណាកស្រុកទៅទីក្រុង និងក្រៅប្រទេស ដើម្បីរកការងារធ្វើ។ ម៉្យាងទៀត ចំណូលខ្ពស់បានពីការងារក្នុងវិស័យមិនមែនកសិកម្ម អាចទាក់ទាញគ្រួសារនៅជនបទ ឲ្យចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលពីការងារក្រៅពីកសិកម្ម។

ដោយសារបញ្ហាដូចខាងលើ ការសម្រេចចិត្តធ្វើការងារក្រៅពីមុខរបរស្រែចំការរបស់គ្រួសារនីមួយៗ អាចអាស្រ័យលើកត្តារុញច្រាន និងកត្តាអូសទាញមួយចំនួន ដូចជា ទីតាំង ជំនាញ និងទ្រព្យធន។ ជាទូទៅ គ្រួសារមានប្រាក់ចំណូលទាប តែងប្រឈមនឹងហានិភ័យកម្រិតខ្ពស់ជាង និងមានសមត្ថភាពតិច ក្នុងការទប់ទល់នឹងការប៉ះទង្គិចផ្សេងៗលើប្រាក់ចំណូល។ ដូច្នេះ ប្រភពចំណូលក្រៅពីមុខរបរស្រែចំការរបស់គ្រួសារក្រីក្ររំពឹងថានឹងមានច្រើនមុខ ជាងគ្រួសារធូរធារ។

សកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ បានក្លាយជាចំណុចសំខាន់បណ្តើរៗមួយនៃ យុទ្ធសាស្ត្រសម្រាប់ បំពេញបន្ថែម និងធ្វើពិពិធកម្មជីវភាពនៅជនបទ កែលំអសុខុមាលភាពនៅតាមជនបទ និងជាពិសេស កាត់បន្ថយហានិភ័យក្នុងវិស័យកសិកម្ម។ បច្ចុប្បន្ន ការធ្វើពិពិធកម្មប្រភពចំណូលរបស់គ្រួសារនៅតាមជនបទ កំពុងមានការយកចិត្តទុកដាក់ជាខ្លាំងពីអ្នកធ្វើគោលនយោបាយ។ គោលនយោបាយកាន់តែប្រសើរសម្រាប់បង្កើតការងារក្រៅពីមុខរបរស្រែចំការ និងកែលំអការគ្រប់គ្រងហានិភ័យក្នុងវិស័យកសិកម្ម តម្រូវឲ្យមានការយល់ដឹងកាន់តែប្រសើរពីកត្តារុញច្រាន-អូសទាញនានា និងឥទ្ធិពលរបស់វាទៅលើការសម្រេចចិត្តរបស់គ្រួសារ ដើម្បីចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។

ការសិក្សានេះមានគោលដៅពិនិត្យថា តើកត្តាណាខ្លះជួយកំណត់ជម្រើសនៃ ការចូលរួមក្នុងការងារក្រៅពីមុខរបរស្រែចំការនៅតាមជនបទកម្ពុជា។ អត្ថបទនេះមានការរៀបរាប់ដោយសង្ខេបពី ការប្រមូលទិន្នន័យ និងបច្ចេកទេសវិភាគដែលបានយកមកប្រើ និងលក្ខណៈសំខាន់ៗមួយចំនួននៃទិន្នន័យប្រមូលបាន។ បន្ទាប់មក មានការពិភាក្សាពីលទ្ធផលប៉ាន់ប្រមាណសម្រាប់ អថេរនីមួយៗដាច់ពីគ្នា និងសេចក្តីសន្និដ្ឋានខ្លីមួយផ្អែកលើលទ្ធផលរកឃើញសំខាន់ៗ។

## វិធីសាស្ត្រស្រាវជ្រាវ

### *ការប្រមូលទិន្នន័យ*

ការសិក្សានេះ ប្រើប្រាស់ទិន្នន័យបានពីអង្កេតលើវិស័យកសិកម្មក្នុងឆ្នាំ២០១៥ សម្រាប់ការស្រាវជ្រាវមួយស្តីពី សកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរស្រែចំការក្នុងតំបន់ជនបទ (FAO 2015)។ អង្កេតនេះបានអនុវត្តឡើងក្នុង ៨ភូមិ នៅក្នុងខេត្តបាត់ដំបង កំពត ព្រៃវែង និងក្រចេះ ដែលតំណាងឲ្យតំបន់អេកូ-កសិកម្មផ្សេងៗ គឺតំបន់ទន្លេសាប តំបន់ឆ្នេរ តំបន់ទំនាបទន្លេមេគង្គ និងតំបន់ភ្នំ/ខ្ពង់រាប។ នៅក្នុងភូមិនីមួយៗ ក្រុមស្រាវជ្រាវបានជ្រើសរើសដោយចៃដន្យនូវ គ្រួសារចំនួន ៤០គ្រួសារ (២០គ្រួសារ មានប័ណ្ណក្រីក្រ និង ២០គ្រួសារ មិនមាន

អត្ថបទនេះ រៀបចំដោយ ស៊ឹម សុខចេង ប្រធានផ្នែកស្តីទី ថេង វុទ្ធី អតីតប្រធានផ្នែក ខៀវ ភិរម្យ អ្នកស្រាវជ្រាវ និង អៀ សុធី អ្នកស្រាវជ្រាវ ផ្នែកកសិកម្ម នៃវិទ្យាស្ថាន CDRI ។ សូមយោងឯកសារនេះថា៖ Sim Sokcheng, Theng Vuthy, Khiev Pirom and Ear Sothy. 2016. “An Empirical Analysis of Factors Determining Choices between Different Subcategories of Off-farm Activities in Rural Cambodia.” *Cambodia Development Review* 20(1): 6-11.

ប័ណ្ណក្រីក្រ) សម្រាប់ធ្វើសម្ភាសន៍ ដូច្នេះសរុបទាំងអស់មាន ៣២០គ្រួសារកសិករសំណាក។

### *ការជ្រើសរើសអថេរ*

អថេរពឹងផ្អែក (dependent variable) គឺការចូលរួមក្នុងប្រភេទផ្សេងៗនៃ សកម្មភាពនៃការរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។ ដើម្បីបង្ហាញពីលក្ខណៈច្រើនបែបយ៉ាង (ពោលគឺមានតម្លៃច្រើនជាងពីរ: polychotomous) អថេរនេះមានតម្លៃស្មើ 0 ប្រសិនបើសមាជិកគ្រួសារគ្មានចូលរួមសោះ ក្នុងសកម្មភាពធ្វើការងារក្រៅពីមុខរបរស្រែចំការ, មានតម្លៃ ១ សម្រាប់ការធ្វើការងារក្នុងវិស័យកសិកម្មតែមួយមុខ, មានតម្លៃ ២ សម្រាប់ការងារមិនមែនកសិកម្មតែមួយមុខ, មានតម្លៃ ៣ សម្រាប់ការងារក្នុងវិស័យកសិកម្ម និងមិនមែនកសិកម្មទាំងពីរមុខ, មានតម្លៃ ៤ សម្រាប់ការងារដែលជាអាជីវកម្មផ្ទាល់ខ្លួនតែមួយមុខ, មានតម្លៃ ៥ សម្រាប់ការងារដែលជាអាជីវកម្មផ្ទាល់ខ្លួន និងការងារមានប្រាក់កម្រៃទាំងពីរមុខ។ ការស្រាវជ្រាវពីមុនៗស្ដីពីការចូលរួមក្នុងការងារក្រៅពីមុខរបរស្រែចំការ បានគូសបញ្ជាក់ពី ឥទ្ធិពលនៃលក្ខណៈសំខាន់ៗរបស់គ្រួសារ ប្រជាសាស្ត្ររបស់គ្រួសារ លក្ខណៈនៃមូលធនមនុស្ស លក្ខណៈនៃស្រែចំការ ចំណូលមិនមែនបានមកពីពលកម្ម និងស្ថានភាពសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ ដូច្នេះ ក្រុមស្រាវជ្រាវបានបញ្ចូលកត្តាទាំងនេះជា អថេរឯករាជ្យ (independent variables)។

### *ការធ្វើម៉ូដែលនៃការផ្គត់ផ្គង់កម្លាំងពលកម្មនៃសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ*

ការផ្គត់ផ្គង់កម្លាំងពលកម្មក្រៅពីមុខរបរស្រែចំការរបស់គ្រួសារនៅជនបទ អាចកំណត់ថាជា លទ្ធផលនៃឥទ្ធិពលអថេរឯករាជ្យផ្សេងៗរួមមាន លក្ខណៈរបស់គ្រួសារ លក្ខណៈជាមូលធនមនុស្សនៃមេគ្រួសារ លក្ខណៈស្រែចំការ ចំណូលមិនមែនបានពីកម្លាំងពលកម្ម និងស្ថានភាពសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ ផ្អែកតាម Haile Abraha, Peerlings and Gardebroek (2008) លទ្ធផលនេះអាចបញ្ជាក់ឡើងដោយ៖

$$\begin{cases} H^0 = f\left(P_q, P_x, \bar{A}, \bar{Y}, K, Z\right) & \text{if} \quad w > w^r \\ H^0 = 0 & \text{if} \quad w \leq w^r \end{cases}$$

នៅពេលដែលប្រាក់កម្រៃក្រៅពីមុខរបរធ្វើស្រែចំការ ($w$) វាច្រើនជាង ប្រាក់កម្រៃបម្រុង (reservation wage $w^r$) កសិករនឹងចូលរួមនៅក្នុងសកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរធ្វើស្រែចំការ។

### *ការធ្វើម៉ូដែលនៃការចូលរួមធ្វើការងារក្រៅពីមុខរបរស្រែចំការ (សូមមើលឯកសារជាភាសាអង់គ្លេស)*

### *ស្ថិតិបកស្រាយ*

ទាំងចំណូលបានពីស្រែចំការ និងចំណូល ក្រៅពីមុខរបរស្រែចំការ សុទ្ធតែសំខាន់សម្រាប់គ្រួសារភាគច្រើននៅជនបទ និងតំណាងឲ្យប្រមាណ ៩០% នៃប្រាក់ចំណូលសរុប (FAO 2015)។ មានសកម្មភាពក្រៅពីមុខរបរស្រែចំការ ៣ប្រភេទ ដែលគេកំណត់ថា ជាប្រភពចម្បងនៃចំណូលបានពីការងារក្រៅពីមុខរបរស្រែចំការ៖ ការងារក្នុងវិស័យកសិកម្ម ការងារមិនមែនកសិកម្ម និងអាជីវកម្មផ្ទាល់ខ្លួន។

ការងារនៅក្នុងវិស័យកសិកម្ម ជាទូទៅមាន សកម្មភាពគាំទ្រផ្សេងៗក្នុងវិស័យកសិកម្ម និងបណ្ដាសកម្មភាពក្រោយការប្រមូលផលដំណាំ[1] ការនេសាទខ្លះ ការដាំដុះស្រូវ ការដាំដំណាំហូបផលយូរឆ្នាំ ការយកផលព្រៃឈើ និងការកាប់ឈើ។ ការងារមិនមែនកសិកម្មភាគច្រើនជា ការងារក្នុងរោងចក្រកាត់ដេរ/សម្លៀកបំពាក់ រោងម៉ាស៊ីនកិនស្រូវ និងសំណង់។ អាជីវកម្មផ្ទាល់ខ្លួន ជាទូទៅមាន ការលក់ទំនិញរាយ និងការផ្ដល់សេវា ដូចជា ការដឹកជញ្ជូន

1 រួមបញ្ចូលទាំងសកម្មភាពបន្ទាប់បន្សំ ពាក់ព័ន្ធនឹងផលិតកម្មកសិកម្ម និងមិនមែនអនុវត្តសម្រាប់គោលដៅផលិតកម្ម (ឧ. ការរៀបចំដី ប្រមូលផល និងគ្រប់គ្រងសត្វល្អិតចង្រៃ) សកម្មភាពគាំទ្រផ្សេងៗសម្រាប់ផលិតកម្មសត្វចិញ្ចឹម និងការរៀបចំគ្រាប់ពូជសម្រាប់ដាំដុះបន្តទៀត។

តារាង១៖ ភាគរយនៃគ្រួសារមានសមាជិកចូលរួមក្នុងប្រភេទផ្សេងៗនៃសកម្មភាពក្រៅពីមុខរបរស្រែចំការ គិតតាមខេត្ត និងកម្រិតនៃភាពក្រីក្រ

| | បាត់ដំបង | កំពត | ក្រចេះ | ព្រៃវែង | ក្រីក្រ | មិនក្រីក្រ | សរុប |
|---|---|---|---|---|---|---|---|
| គ្មានសកម្មភាពក្រៅពីមុខរបរស្រែចំការ | 24.9 | 23.8 | 17.4 | 29.8 | 20.01 | 27.65 | 24.1 |
| មានការងារក្រៅពីមុខរបរស្រែចំការ | 75.1 | 76.3 | 82.6 | 70.2 | 79.99 | 72.35 | 75.9 |
| មានការងារក្នុងវិស័យកសិកម្មតែមួយមុខ | 17.5 | 10.0 | 36.3 | 6.3 | 25.33 | 10.59 | 17.5 |
| មានការងារមិនមែនកសិកម្មតែមួយមុខ | 22.5 | 30.0 | 12.5 | 36.3 | 21.33 | 28.82 | 25.3 |
| មានទាំងការងារក្នុងវិស័យកសិកម្ម និងមិនមែនកសិកម្ម | 7.5 | 5.0 | 11.3 | 10.0 | 13.33 | 4.12 | 8.4 |
| មានអាជីវម្មផ្ទាល់ខ្លួនតែមួយមុខ | 16.3 | 11.3 | 12.5 | 11.3 | 9.33 | 15.88 | 12.8 |
| មានទាំងអាជីវម្មផ្ទាល់ខ្លួននិងការងារយកប្រាក់កម្រៃ | 11.3 | 20.0 | 10.0 | 6.3 | 10.67 | 12.94 | 11.9 |

ប្រភព៖ អង្កេតគ្រួសារកសិករ ឆ្នាំ២០១៥

និងកន្លែងលំហែកំសាន្ត និងមានការផលិត និងលក់ផលិតផលសិប្បកម្មមួយចំនួនតូច។

ដូចមានបង្ហាញក្នុងតារាង១ ស្រាប់ ៧៦% នៃគ្រួសារទាំងអស់នៅក្នុងអង្កេត មានសមាជិកយ៉ាងតិច ១នាក់ ដែលបានចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ អត្រានៃការចូលរួមនៅខេត្តក្រចេះ មានកម្រិតខ្ពស់ (៨២,៥%) ដោយឡែកនៅខេត្តព្រៃវែង វាមានកម្រិតទាបជាង (៧០,២%)។ ដំណាំដាំសម្រាប់លក់ (កៅស៊ូ ម្រេច ដំឡូងឈើ) ជាកត្តាចម្បងជំរុញការងារយកប្រាក់កម្រៃក្នុងវិស័យកសិកម្មនៅខេត្តក្រចេះ និងផ្តល់នូវប្រភពចំណូលដល់ ៣៦,៣% នៃគ្រួសារក្នុងខេត្តនេះ។ ផ្ទុយទៅវិញ នៅខេត្តព្រៃវែង មានតែ ៦,៣% នៃគ្រួសារទាំងអស់ប៉ុណ្ណោះដែលធ្វើការក្រៅពីមុខរបរស្រែចំការ និងក្នុងវិស័យកសិកម្មតែមួយមុខ ហើយក្នុងវិស័យមិនមែនកសិកម្ម ការងារយកប្រាក់កម្រៃ មានចំណែកធំជាងគេ រហូតដល់ ៣៦,៣%។

ប្រមាណ ៣៤%[2] នៃគ្រួសារក្នុងអង្កេត បានចូលរួមក្នុងសកម្មភាពមិនមែនកសិកម្ម (តារាង១) ដែលជាប្រភេទចម្បងនៃការងារក្រៅពីមុខរបរស្រែចំការ ក្នុងការសិក្សានេះ។ ប្រភេទចម្បងបន្ទាប់នៃ សកម្មភាពក្រៅពីមុខរបរស្រែចំការ គឺគ្រួសារប្រមាណ ២៦% ធ្វើការងារក្នុងវិស័យកសិកម្ម ដែលជាទូទៅ មានស្រាប់នៅក្នុងភូមិ និងខេត្តរបស់គាត់ ហើយភាគច្រើនធ្វើស្រែចំការតាមរដូវកាល។ អ្នកធ្វើការក្នុងវិស័យមិនមែនកសិកម្ម ត្រូវទៅក្រៅភូមិ ដែលអាចនៅក្នុងខេត្តគាត់កំពុងរស់នៅ ឬខេត្តផ្សេង។

គ្រួសារក្រីក្រ ៨០% និង គ្រួសារមិនក្រីក្រ ៧២% បានរួមចំណែកក្នុងការងារក្រៅពីមុខរបរស្រែចំការ ដែលមានប្រភេទខុសៗគ្នាគួរឲ្យកត់សំគាល់។ សកម្មភាពកសិកម្ម ជាប្រភេទចម្បងនៃការងារក្រៅពីមុខរបរស្រែចំការ អនុវត្តដោយគ្រួសារក្រីក្រ (៣៩%) រីឯគ្រួសារមិនក្រីក្រ ផ្តោតលើការងារមិនមែនកសិកម្ម និងអាជីវកម្មផ្ទាល់ខ្លួន។

## លទ្ធផលប៉ាន់ស្មាន

ផ្នែកនេះ ពិភាក្សាអំពីលទ្ធផលរកឃើញ (regression results) សម្រាប់ ការចូលរួមរបស់គ្រួសារក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ ដូចមានចុះក្នុងតារាង២ ។

### *លក្ខណៈរបស់គ្រួសារ*

ក្រុមស្រាវជ្រាវបានរកឃើញថា ភាពក្រីក្រមានផលប៉ះពាល់អវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ ការងារក្នុងវិស័យកសិកម្ម។ លទ្ធផលនេះស្របតាម Shi, Heerink and Ou (2007) ដែលរកឃើញថា គ្រួសារក្រីក្រចង់ស្វែងរកប្រភពចំណូលផ្សេងៗទៀត។ ប៉ុន្តែ ម៉ូដែលអនុវត្តប្រើដោយក្រុមស្រាវជ្រាវបានបញ្ជាក់ថា ម្ចាស់ដីតូចៗដែលក្រីក្រ និងពលករគ្មានដីធ្លី គឺអាចរកបានការងារ (ទាំងការងារក្នុងវិស័យកសិកម្ម និងមិនមែនកសិកម្ម) តែនៅក្នុងតំបន់ជនបទប៉ុណ្ណោះ។ បញ្ហានេះអាចមកពី អត្រាសមាជិកគ្រួសារក្នុងបន្ទុកកម្រិតខ្ពស់ រហូតដល់ ០,៩ និងកង្វះខាតសមាជិកគ្រួសារសកម្មផ្នែកសេដ្ឋកិច្ចដើម្បីទៅស្វែងរកការងារនៅឯទីក្រុង ឬតំបន់ផ្សេងទៀត។[3]

គ្រួសារសម្បូរទ្រព្យសម្បត្តិ មានឱកាសច្រើន ក្នុងការចាប់ផ្តើមអាជីកម្ម ហើយក្លាយទៅជាអ្នកមានអាជីវកម្មផ្ទាល់ខ្លួន ឬក៏អាចរកបានការងារមិនមែនកសិកម្ម នៅខាងក្រៅមូលដ្ឋានរបស់ខ្លួន។ នៅក្នុងម៉ូដែលបានអនុវត្តប្រែនេះ អថេរ (dummy variable) សម្រាប់តំណាងឲ្យស្ថានភាពក្រីក្ររបស់គ្រួសារ (ក្រីក្រ=0, មិនក្រីក្រ=១) មិនមានសារៈសំខាន់ខាងស្ថិតិទេ សម្រាប់អាជីវកម្មផ្ទាល់ខ្លួន ឬការងារមិនមែនកសិកម្ម។ លក្ខណៈនេះបង្ហាញថា គ្រួសារក្រីក្រ និងមិនក្រីក្រ មិនទំនងជាមានអនុវត្ត អាជីវកម្មផ្ទាល់ខ្លួន ឬការងារយកប្រាក់កម្រៃមិនមែនកសិកម្មនោះទេ។

ទំហំគ្រួសារ ជះឥទ្ធិពលវិជ្ជមាន គួរឲ្យកត់សំគាល់ទៅលើប្រូបាប៊ីលីតេនៃ ការចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ សម្រាប់គ្រួសារដែលអាចចូលរួមក្នុងការងារវិស័យកសិកម្ម និងមិនមែនកសិកម្មទាំងពីរមុខ។ លទ្ធផលរកឃើញនេះ ស្របគ្នាជាមួយនឹង Leeuwen and Dekkers (2013) ដែលលើកថា នៅពេលចំនួនសមាជិកគ្រួសារកើនឡើង ប្រូបាប៊ីលីតេនៃការចូលរួមរបស់គ្រួសារនោះ នៅក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ ទាំងផ្នែកកសិកម្ម និងមិនមែនកសិកម្ម ក៏កើនឡើងដែរ។ គ្រួសារនៅជនបទ ត្រូវការប្រាក់ចំណូលបន្ថែម ដើម្បីបំពេញលើកង្វះប្រាក់ចំណូលបានពីស្រែចំការ។

ចំនួនឆ្នាំដែលគ្រួសារនីមួយៗ បានរស់នៅក្នុងភូមិរបស់ខ្លួន វាមានសារៈសំខាន់ផ្នែកស្ថិតិសម្រាប់ ការងារបម្រើខ្លួនឯង រីឯប្រភេទផ្សេងៗទៀតនៃសកម្មភាពក្រៅពីមុខរបរស្រែចំការ វាមានសញ្ញាអវិជ្ជមាន។ ដូច្នេះ កសិករមានការផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងសកម្មភាពកសិកម្ម ហើយចំណូលបានពីស្រែចំការសំខាន់ខ្លាំងណាស់សម្រាប់គាត់។ ចំណុចនេះបង្ហាញថា ចំណូលបានពីការងារក្រៅពីមុខរបរស្រែចំការ វាជួយបំពេញបន្ថែម ជាជាងប្រជែងគ្នាជាមួយនឹង ចំណូលរំពឹងថាបានពីស្រែចំការ។

### *លក្ខណៈប្រជាសាស្ត្រ និងមូលធនមនុស្ស*

អាយុមេគ្រួសារ ជះឥទ្ធិពលវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើការងារក្នុងវិស័យកសិកម្ម ហើយផលលើវដ្តនៃជីវិត (age-squared) ក៏ជះឥទ្ធិពលអវិជ្ជមានគួរឲ្យកត់សំគាល់ដែរ។ អាយុមានទំនាក់ទំនងវិជ្ជមានខ្លាំងជាមួយនឹង ប្រូបាប៊ីលីតេនៃការចូលរួមក្នុងការងារក្រៅពីមុខរបរស្រែចំការ។ ប៉ុន្តែ នៅពេលសមាជិកគ្រួសារកាន់តែចាស់អាយុ ប្រូបាប៊ីលីតេនៃការចូលរួមក្នុងការងារកសិកម្មយកប្រាក់កម្រៃ តែងថយចុះគួរឲ្យកត់សំគាល់។ ការស្រាវជ្រាវនេះ ផ្តល់លទ្ធផលស្របគ្នាជាមួយ Haile Abraha, Peerlings and Gardebroek (2008) ដែលថា មេគ្រួសារវ័យក្មេងទំនងត្រូវការ និងអាចធ្វើបានច្រើនជាងនូវ ការងារក្រៅពីមុខរបរស្រែចំការ។

2 អ្នកមានការងារក្នុងវិស័យកសិកម្មតែមួយមុខ (២៥,៣%) បូកនឹង អ្នកមានទាំងការងារក្នុងវិស័យកសិកម្ម និងការងារមិនមែនកសិកម្ម (៨,៤%)។

3 អត្រាសមាជិកគ្រួសារក្នុងបន្ទុក (dependency ratio) របស់គ្រួសារ គឺជា ចំនួនសមាជិកគ្រួសារក្រោមអាយុ ១៥ឆ្នាំ និងលើ ៦៤ឆ្នាំ ចែកជាមួយនឹង ចំនួនសមាជិកធ្វើការងារនិងមានអាយុពី ១៥ឆ្នាំ ទៅ ៦៤ឆ្នាំ។

យេនឌ័រមេគ្រួសារ មិនមានផលប៉ះពាល់អ្វីគួរឲ្យកត់សម្គាល់ទេ ទៅលើការចូលរួមរបស់ម្ចាស់ដីតូចៗ និងអ្នកគ្មានដីធ្លី ក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។

កម្រិតអប់រំរបស់មេគ្រួសារ មិនមានផលប៉ះពាល់គួរឲ្យកត់សំគាល់ទេ ទៅលើ ការងារក្នុងវិស័យកសិកម្ម គឺស្របគ្នានឹងលទ្ធផលរកឃើញក្នុងការសិក្សាពីមុនៗដែលបង្ហាញពី ទំនាក់ទំនងអន់ខ្សោយរវាង ការអប់រំ នឹងការងារក្នុងវិស័យកសិកម្ម។ ការអប់រំជះឥទ្ធិពលវិជ្ជមានទៅលើការងារបម្រើខ្លួនឯង ទោះបីមិនមានសារៈសំខាន់ផ្នែកស្ថិតិក្ដី ហើយជះឥទ្ធិពលវិជ្ជមានដោយមានសារៈសំខាន់ផ្នែកស្ថិតិ ទៅលើការងារបម្រើខ្លួនឯង និងការងារយកប្រាក់កម្រៃ នៅកម្រិត ១០%។ មេគ្រួសារមានការអប់រំខ្ពស់ តែងមានផលិតភាព និងសមត្ថភាពច្រើនជាង ក្នុងការធ្វើអាជីវកម្ម ឬរកបានការងារក្រៅពីមុខរបរស្រែចំការ។

ការបណ្ដុះបណ្ដាល ក៏ជះឥទ្ធិពលវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ អាជីវម្មផ្ទាល់ខ្លួនដែរ។ អ្នកដែលទទួលបានការបណ្ដុះបណ្ដាលវិជ្ជាជីវៈ តែងមានសមត្ថភាពច្រើនជាងក្នុងការគ្រប់គ្រងអាជីវកម្ម ឬក្លាយជាអ្នកមានអាជីវម្មផ្ទាល់ខ្លួន ប៉ុន្តែអ្នកដែលមិនមានជំនាញអ្វីពិសេស មិនទំនងអាចធ្វើដូច្នោះបានទេ។ គេតែងវាយការណ៍ថា កង្វះខាតជំនាញជាឧបសគ្គចម្បងមួយដល់ការធ្វើអាជីវម្មផ្ទាល់ខ្លួន ដូច្នេះហើយនៅទីបំផុត គ្រួសារក៏ត្រូវប្រើជម្រើសចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។

### *លក្ខណៈស្រែចំការ*

ទ្រព្យមានផលិតភាពរបស់គ្រួសារ ដូចជា ដីដាំដុះ/ទំហំដី ជាកត្តារុញច្រានយ៉ាងសំខាន់មួយទៀត នៃការចូលរួមរបស់គ្រួសារ ក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ ទំហំស្រែចំការជះឥទ្ធិពលអវិជ្ជមាន គួរឲ្យកត់សំគាល់ទៅលើការងារមិនមែនកសិកម្ម និងអាជីវម្មផ្ទាល់ខ្លួន (នៅកម្រិត ៥%) និងលើការងារយកប្រាក់កម្រៃ (នៅកម្រិត ១%)។

ដោយសារប្រាក់ចំណូលបានពីផលដំណាំ វាមិនគ្រប់គ្រាន់សម្រាប់ដោះស្រាយតម្រូវការប្រចាំថ្ងៃរបស់ខ្លួន ម្ចាស់ដីតូចៗ និងកសិករគ្មានដីធ្លី ទំនងទៅចូលរួមក្នុងការងារមិនមែនកសិកម្មតែមួយមុខ ឬក៏ក្នុងការងារក្នុងវិស័យកសិកម្មផង និងមិនមែនកសិកម្មផងទាំងពីរមុខ។ ប្រាក់ចំណូលរកបាននៅស្រែចំការអំពី ការចិញ្ចឹមសត្វ ការនេសាទ និងផលិតផលព្រៃឈើ ក៏ជះឥទ្ធិពលអវិជ្ជមានគួរឲ្យកត់សំគាល់ដែរទៅលើ ការចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ លទ្ធផលរកឃើញនេះ ស្រដៀងគ្នានឹង ការសិក្សាពីមុនៗ ដែលបង្ហាញថា កំណើនប្រាក់ចំណូលបានពីសកម្មភាពធ្វើស្រែចំការ តែងកាត់បន្ថយការចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។

### *លក្ខខណ្ឌសេដ្ឋកិច្ចក្នុងមូលដ្ឋាន*

កត្តារុញច្រាន និងកត្តាអូសទាញផ្នែកសេដ្ឋកិច្ច ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តធ្វើការងារ ក្រៅពីមុខរបរស្រែចំការ របស់គ្រួសារនីមួយៗ។ ថ្លៃស្រូវ ដែលតំណាងឲ្យ ទីផ្សារផលិតផលកសិកម្មល្អឥតខ្ចោះ វាជះឥទ្ធិពលអវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ ការងារមិនមែនកសិកម្ម នៅកម្រិត ៥%។ ចំណូលខ្ពស់បានពីផលស្រូវវស្សា ដោយសារ ថ្លៃស្រូវកើនឡើង វាធ្វើឲ្យថយចុះប្រូបាប៊ីលីតេនៃ ការចូលរួមរបស់គ្រួសារក្នុងការងារមិនមែនកសិកម្ម។ ចំណុចនេះបង្ហាញថា ថ្លៃនៅទីផ្សារដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ពី ការចូលរួមរបស់គ្រួសារនៅក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។

អថេរទីផ្សារហិរញ្ញវត្ថុ ដែលតំណាងដោយអត្រាការប្រាក់លើកម្ចី មិនមានជាប់ទាក់ទងអ្វីគួរឲ្យកត់សំគាល់ ជាមួយនឹង ប្រភេទណាមួយនៃសកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរស្រែចំការទាំងប្រាំប្រភេទនោះទេ។ ទោះបីជាមិនមានសារៈសំខាន់ផ្នែកស្ថិតិក្ដី ក៏សញ្ញានៃការជះឥទ្ធិពលទៅលើអត្រាការប្រាក់កម្ចី វាមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ណាស់។ ក្រុមស្រាវជ្រាវបានរកឃើញឥទ្ធិពលអវិជ្ជមានលើអាជីវម្មផ្ទាល់ខ្លួន ដែលបង្ហាញថា អត្រាការប្រាក់កាន់តែខ្ពស់ឡើង ធ្វើឲ្យថយចុះកាន់តែខ្លាំងនូវ ប្រូបាប៊ីលីតេរបស់គ្រួសារក្នុងការបង្កើតអាជីវកម្ម និងការក្លាយជាអ្នកមានអាជីវម្មផ្ទាល់ខ្លួន។ ផ្ទុយទៅវិញ ក្រុមស្រាវជ្រាវបានរកឃើញទំនាក់ទំនងវិជ្ជមាន ជាមួយនឹង ការងារមិនមែនកសិកម្ម។

លទ្ធផលខាងលើអាចបញ្ជាក់ថា កំណើននៃអត្រាការប្រាក់កម្ចី អាចបង្កើនប្រូបាប៊ីលីតេនៃការចូលរួមក្នុងសកម្មភាពមិនមែនកសិកម្ម។ ដោយសារកសិករនៅជនបទភាគច្រើន ប្រើប្រាស់ឥណទានដើម្បីធ្វើវិនិយោគក្នុងផលិតកម្មកសិកម្ម ដូច្នេះកំណើនអត្រាការប្រាក់កម្ចី អាចកាត់បន្ថយផលចំណេញបានពីកសិកម្ម ហើយបង្ខំឲ្យកសិករទៅស្វែងរកប្រភពចំណូលផ្សេងទៀត អំពីការងារយកប្រាក់កម្រៃមិនមែនក្នុងវិស័យកសិកម្ម។ ដោយឡែកប្រមាណ ៥៨% នៃគ្រួសារក្នុងអង្កេត បានប្រាប់ថា គាត់មិនអាចមានអាជីវម្មផ្ទាល់ខ្លួន ឬចាប់ផ្ដើមអាជីវកម្មបានទេ ពីព្រោះខ្វះដើមទុនសម្រាប់ធ្វើវិនិយោគ។

### *ទីតាំង និងកត្តានៅតាមភូមិ*

មេគុណប៉ាន់ស្មាននៃ អថេរតំណាងឲ្យទីតាំង (dummy variable) សម្រាប់ខេត្តក្រចេះ មានតួលេខវិជ្ជមាន និងមានសារៈសំខាន់ផ្នែកស្ថិតិ សម្រាប់ការមានការងារក្នុងវិស័យកសិកម្មតែមួយមុខ និងការងារមិនមែនកសិកម្មតែមួយមុខ។ ចំណុចនេះមានន័យថា កត្តានៅតាមភូមិ ដូចជា លទ្ធភាពចូលទីផ្សារ និងការអភិវឌ្ឍសេដ្ឋកិច្ច វារួមចំណែកធ្វើឲ្យ ការចូលរួមក្នុងការងារលើវិស័យកសិកម្មនៅខេត្តក្រចេះ មានប្រូបាប៊ីលីតេខ្ពស់គួរសម។ កត្តាទាំងនេះ ក៏មានសារៈសំខាន់គួរកត់សំគាល់ ប៉ុន្តែជះឥទ្ធិពលអវិជ្ជមាន ទៅលើការងារមិនមែនកសិកម្ម។ ភូមិទាំងពីរដែលគេបានធ្វើអង្កេតក្នុងខេត្តក្រចេះ ស្ថិតនៅដាច់ស្រយាលគួរសម ហើយមានដំណាំឧស្សាហកម្ម និងដំណាំដាំសម្រាប់លក់ជាច្រើន (កៅស៊ូ ដំឡូងឈើ ស្វាយចន្ទី ម្រេច និងពពួកសណ្ដែក) នៅជុំវិញទីនោះ។ ទាំងអស់នេះបង្ហាញពីមូលហេតុដែលនៅខេត្តក្រចេះ មានគ្រួសារចូលរួមនៅក្នុងការងារធ្វើស្រែចំការ ច្រើនជាង ក្នុងការងារមិនមែនស្រែចំការ។

មេគុណ (dummy coefficient) សម្រាប់ខេត្តកំពតជះឥទ្ធិពលវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើអាជីវម្មផ្ទាល់ខ្លួន និង

ការងារយកប្រាក់កម្រៃ ហើយបង្ហាញពី ប្រូបាប៊ីលីតេខ្ពស់នៃការធ្វើអាជីវកម្មផ្ទាល់ខ្លួន និងការងារយកប្រាក់កម្រៃ។

## សេចក្តីសង្ខេប

ការងារក្រៅពីមុខរបរស្រែចំការ និងការងារស្រែចំការ ជាប្រភពចំណូលចម្បងសម្រាប់គ្រួសារ។ ប្រមាណ ៧៦% នៃគ្រួសារក្នុងអង្កេត បានចូលរួមក្នុងទម្រង់ខ្លះនៃ សកម្មភាពរកចំណូលក្រៅពីមុខរបរស្រែចំការ។ ការងារមិនមែនកសិកម្ម ជាប្រភពចម្បងនៃចំណូលបានពីការងារក្រៅពីមុខរបរស្រែចំការ បន្ទាប់មកគឺ ការងារក្នុងវិស័យកសិកម្ម និងអាជីវកម្មផ្ទាល់ខ្លួន។

ការវិភាគផ្អែកលើបទពិសោធន៍ជាក់ស្តែង បង្ហាញថា គ្រួសារក្រីក្រ តែងចូលរួមក្នុងការងារកសិកម្ម ឬការងារមិនមែនកសិកម្មនៅជនបទ ក្នុងចំនួនច្រើនជាង គ្រួសារមិនក្រីក្រ។ ស្ថានភាពនេះប្រហែលដោយសារ គ្រួសារក្រីក្រមានតិចជាងនូវ កម្លាំងពលកម្មកំពុងធ្វើសកម្មភាពសេដ្ឋកិច្ច ដូចអាចមើលឃើញតាម អត្រាសមាជិកគ្រួសារក្នុងបន្ទុកកម្រិតខ្ពស់ ដូច្នេះហើយក៏មិនអាចទៅធ្វើសកម្មភាពក្រៅពីមុខរបរស្រែចំការប្រភេទផ្សេងទៀត ជាពិសេសការងារនៅក្រៅភូមិ។

គ្រួសារមិនក្រីក្រ តែងចូលរួមក្នុងប្រភេទផ្សេងៗនៃការងារក្រៅពីស្រែចំការផ្ទាល់ខ្លួន ឬអាជីវកម្មផ្ទាល់ខ្លួន គួបផ្សំនឹង ការងារក្រៅពីមុខរបរស្រែចំការ និងយកប្រាក់កម្រៃ។ សញ្ញាអវិជ្ជមានសម្រាប់ទំនាក់ទំនងរវាង រយៈពេលដែលគ្រួសារមួយរស់នៅក្នុងភូមិនោះជាមួយនឹងការងារក្រៅពីមុខរបរស្រែចំការ បង្ហាញអំពីការផ្សារភ្ជាប់យ៉ាងខ្លាំងនៃគ្រួសារនៅជនបទ ទៅនឹងសកម្មភាពកសិកម្ម។ ប្រសិនបើ ចំណូលបានពីស្រែចំការតែមួយមុខ វាអាចផ្គត់ផ្គង់ជីវភាពបានគ្រប់គ្រាន់នោះ គ្រួសារនៅជនបទទំនងជាផ្តោតទៅលើការងារស្រែចំការ ជាជាង សកម្មភាពក្រៅពីមុខរបរស្រែចំការ។ ពួកគេចង់រស់នៅក្នុងភូមិរបស់ខ្លួន ជាជាងការធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើ។

ក្នុងចំណោមលក្ខណៈប្រជាសាស្ត្ររបស់គ្រួសារ និងលក្ខណៈមូលធនមនុស្ស អាយុ និងការបណ្តុះបណ្តាលរបស់មេគ្រួសារ ជះឥទ្ធិពលយ៉ាងសំខាន់ផ្នែកស្ថិតិ ទៅលើ ការចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ ការបណ្តុះបណ្តាល ក៏ដើរតួនាទីសំខាន់ដែរ ក្នុងការចាប់ផ្តើមអាជីវកម្ម ឬធ្វើអាជីវកម្មផ្ទាល់ខ្លួន និងក្នុងការរកបានការងារក្រៅពីមុខរបរស្រែចំការ និងយកប្រាក់កម្រៃ។ ទ្រព្យសម្បត្តិគ្រួសារ ជាពិសេស ទំហំដីដាំដុះ ជាកត្តាសំខាន់មួយដែលកំណត់ការសម្រេចចិត្តរបស់គ្រួសារ ក្នុងការធ្វើការងារក្រៅពីមុខរបរស្រែចំការ។ ម្ចាស់ដីតូចៗ និងគ្រួសារគ្មានដីធ្លី ទំនងចូលរួមច្រើនជាងក្នុងការងារមិនមែនស្រែចំការ។

សរុបមក លក្ខខណ្ឌសេដ្ឋកិច្ចក្នុងមូលដ្ឋាន ដូចជា លទ្ធភាពចូលទីផ្សារ ការអភិវឌ្ឍសេដ្ឋកិច្ច និងទីតាំងភូមិសាស្ត្រ ក៏ជះឥទ្ធិពល (កត្តាអូសទាញ) ទៅលើការសម្រេចចិត្តរបស់គ្រួសារក្នុងការចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរស្រែចំការ។ ចំណុចសំខាន់បំផុត ក្រុមស្រាវជ្រាវបានរកឃើញនូវទំនាក់ទំនងអវិជ្ជមានយ៉ាងខ្លាំង រវាង ទីផ្សារផលិតផលកសិកម្មជាមួយនឹង ការងារមិនមែនកសិកម្ម។ កំណើនថ្លៃស្រូវ ជួយបង្កើនចំណូលបានពីផលិតកម្មស្រូវ និងកាត់បន្ថយការចូលរួមរបស់គ្រួសារក្នុងការងារមិនមែនកសិកម្ម។ ការងារកសិកម្មតែងមានច្រើនជាង នៅតាមតំបន់មានការដាំដុះដំណាំដាំសម្រាប់លក់ និងដំណាំឧស្សាហកម្ម ដូចជានៅខេត្តក្រចេះ ជាដើម។ ស្រដៀងគ្នានេះដែរ ទីតាំងមានការប្រមូលផ្តុំសកម្មភាពសេដ្ឋកិច្ចច្រើន ដូចជានៅខេត្តកំពត ជាដើម តែងមានផ្តល់ច្រើនជាងនូវ ឱកាសសម្រាប់ធ្វើអាជីវកម្មផ្ទាល់ខ្លួន និងឱកាសធ្វើអាជីវកម្មផ្សេងៗ។

## ឯកសារយោង


Chang, Hung-Hao, and Ashok Mishra. 2008. "Impact of Off-farm Labor Supply on Food Expenditures of the Farm Household." Food Policy 33(6):657-664. http://dx.doi.org/10.1016/j.foodpol.2008.02.002.

CDRI (Cambodia Development Research Institute). 2013. Cambodia's Development Dynamics: Past Performance and Emerging Priorities. Phnom Penh: CDRI.

FAO (Food and Agricutural Organization). 2015. "Study on Off-farm Income Generation Activities in Cambodia." Unpublished.

Haile Abraha, N., J.H.M. Peerlings and C. Gardebroek. 2008. "Off-farm Labor Supply and the Role of Rainfall: A Case Study in Tigray, Northern Ethiopia." Proceedings of the 6th International Conference on the Ethiopian Economy, Bahir Dar University, Ethiopia, 3-5 July.

van Leeuwen, Eveline, and Jasper Dekkers. 2013. "Determinants of Off-farm Income and its Local Patterns: A Spatial Microsimulation of Dutch Farmers." Journal of Rural Studies 31:55-66. http://dx.doi.org/10.1016/j.jrurstud.2013.02.002.

Shi, Xiaoping, Nico Heerink and Futian Qu. 2007. "Choices between Different Off-farm Employment Sub-categories: An Empirical Analysis for Jiangxi Province, China." China Economic Review 18(4):438-455. http://dx.doi.org/10.1016/j.chieco.2006.08.001.


---

*តពីទំព័រ ៤* **ការចុះបញ្ជីដីធ្លី...**


Markus, G., and C. Udry. 2008. "The Profits of Power: Land Rights and Agricultural Investment in Ghana." *Journal of Political Economy* 116(6): 981-1022.

Markussen, T. 2008. "Property Rights, Productivity and Common Property Resources: Insights from Rural Cambodia." *World Development* 36(11): 2277-2296.

MLMUPC. 2013. *Report on Land Administration for Dissemination under Land Administration Sub-Sector Program.* Phnom Penh: Ministry of Land Management Urban Planning and Construction in Cambodia.

Sar, S. 2010. "Land Reform in Cambodia." Paper presented at the International Federation of Surveyors Congress, Kuala Lumpur, 16-21 June. Unpublished document.

de Soto, Hernando. 1986. "The Mystery of Capital." *Journal of Commonwealth Law and Legal Education* 2(2): 73-88.

de Soto, Hernando. 2000. *The Mystery of Capital: Why Capitalism Triumphs in the West and Fails Everywhere Else.* New York: Basic Books.

Sry B. 2013. "On Effectiveness of Systematic Land Tittling in Rural Cambodia." Master's thesis, University of Tsukuba, Japan.

Thomson, A. 2010. *Gender Equality in Systematic Land Registration.* Phnom Penh: Canadian International Development Agency.

Torhonen, P.M. 2001. "Developing Land Administration in Cambodia." *Computers, Environment and Urban Systems* 25(4-5): 407-428.

តារាង ២៖ លទ្ធផល multinomial probit regression សម្រាប់ការចូលរួមរបស់គ្រួសារក្នុងប្រភេទផ្សេងៗ នៃសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ

| | អថេរពឹងអាស្រ័យ (dependent variable): ការចូលរួមរបស់គ្រួសារក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ការងារក្នុងវិស័យកសិកម្ម | | ការងារមិនមែនកសិកម្ម | | ទាំងការងារកសិកម្ម និងមិនមែនកសិកម្ម | | អាជីវកម្មផ្ទាល់ខ្លួន | | អាជីវកម្មផ្ទាល់ខ្លួន និងការងារយកប្រាក់កម្រៃ | |
| | មេគុណ | z | មេគុណ. | z | មេគុណ | z | មេគុណ. | z | មេគុណ. | z |
| ***លក្ខណៈរបស់គ្រួសារ*** | | | | | | | | | | |
| គ្រួសារ_ក្រីក្រ | -1.0450*** | -3.41 | 0.1393 | 0.5 | -0.8985*** | -2.53 | 0.0444 | 0.15 | -0.4783 | -1.44 |
| គ្រួសារ_ទំហំ | 0.0475 | 0.53 | 0.1032 | 1.27 | 0.3486*** | 3.54 | -0.1389 | -1.53 | 0.0909 | 1.04 |
| គ្រួសារ_ឆ្នាំ_ភូមិ | -0.0130 | -0.89 | -0.0171 | -1.31 | -0.0057 | -0.36 | -0.0333* | -2.26 | -0.0044 | -0.3 |
| ***លក្ខណៈប្រជាសាស្ត្រ និងមូលធនមនុស្ស*** | | | | | | | | | | |
| មេគ្រួសារ_ភេទ | 0.3797 | 1.04 | 0.2619 | 0.8 | 0.6004 | 1.45 | -0.0008 | 0 | 0.5000 | 1.24 |
| មេគ្រួសារ_អាយុ | 0.1557*** | 2.51 | 0.0655 | 1.14 | 0.0808 | 1.08 | 0.0830 | 1.44 | 0.2174*** | 2.84 |
| មេគ្រួសារ_អាយុ2 | -0.0018*** | -2.97 | -0.0008 | -1.34 | -0.0009 | -1.25 | -0.0009 | -1.54 | -0.0019*** | -2.76 |
| មេគ្រួសារ_ការអប់រំ | -0.0765 | -1.56 | -0.0225 | -0.54 | -0.1169** | -2.09 | 0.0059 | 0.13 | 0.0793* | 1.61 |
| មេគ្រួសារ_ការបណ្តុះបណ្តាលវិជ្ជាជីវៈ | 0.2053 | 0.48 | 0.0715 | 0.21 | -0.5505 | -0.88 | 0.7693** | 2.14 | 0.8273*** | 2.09 |
| ***លក្ខណៈកសិដ្ឋាន*** | | | | | | | | | | |
| ការដាំដុះ_ដី | 0.0263 | 0.32 | -0.2311** | -2.03 | -0.3229* | -1.79 | 0.0121 | 0.15 | -0.4687*** | -3 |
| ចំណូលសរុប_សត្វចិញ្ចឹម | 0.0002 | 0.32 | 0.0002 | 0.28 | 0.0005 | 0.59 | 0.0009 | 1.18 | 0.0009 | 1.39 |
| ចំណូលសរុប_នេសាទ | -0.0001 | -0.09 | -0.0025* | -1.68 | -0.0014 | -1.03 | -0.0011 | -0.37 | -0.0007 | -0.38 |
| ចំណូលសរុប_ព្រៃឈើ | -0.0052* | -1.66 | -0.0021 | -0.75 | -0.0052* | -1.8 | -0.0081*** | -2.62 | -0.0044 | -1.43 |
| ***ស្ថានភាពសេដ្ឋកិច្ចនៅមូលដ្ឋាន*** | | | | | | | | | | |
| ថ្លៃ_ស្រូវវស្សា | -0.0010 | -0.2 | -0.0083** | -1.93 | -0.0067 | -1.35 | -0.0035 | -0.72 | -0.0121** | -2.43 |
| អត្រា_កម្ចី | -0.0812 | -0.84 | 0.0514 | 1.06 | -0.1637 | -1.4 | -0.0734 | -0.71 | -0.0831 | -0.62 |
| បាត់ដំបង | 0.6252 | 1.46 | -0.1410 | -0.4 | -0.2294 | -0.5 | 0.3949 | 0.97 | 0.5329 | 1.19 |
| កំពត | 0.3139 | 0.43 | 0.7050 | 1.33 | 0.1126 | 0.17 | 0.2123 | 0.34 | 2.1248*** | 3.46 |
| ក្រចេះ | 1.4475*** | 2.7 | -1.0022** | -1.93 | -0.3322 | -0.58 | 0.4890 | 0.84 | 0.0933 | 0.15 |
| ថេរ (constant) | -1.6130 | -0.37 | 6.7087 | 1.74 | 4.2204 | 0.85 | 3.0651 | 0.72 | 4.3444 | 0.9 |
| ចំនួនករណីបានពិនិត្យសង្កេត | 320 | | | | | | | | | |
| Wald chi2(85) | 238.0 | | | | | | | | | |
| Log pseudolikelihood | -452.1 | | | | | | | | | |

កំណត់សំគាល់: មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត *10%, **5% និង ***1%

ចេញផ្សាយថ្មីៗ

# ការប្រែប្រួលអាកាសធាតុ និង អភិបាលកិច្ចធនធានទឹកនៅកម្ពុជា

## បញ្ហាប្រឈម និងការប្រមើលពីសន្តិសុខទឹក និងការប្រែប្រួលអាកាសធាតុ ក្នុងអាងស្ទឹងមួយចំនួននៅកម្ពុជា




គម្រោងសិក្សាផ្តោតលើដែនរងទឹកភ្លៀងបី នៅជុំវិញបឹងទន្លេសាប មានស្ទឹងជ្រៃបាក់ក្នុងខេត្តកំពង់ឆ្នាំង ស្ទឹងជីនិតក្នុងខេត្តកំពង់ធំ និងស្ទឹងពោធិ៍សាត់ក្នុងខេត្តពោធិ៍សាត់។ លទ្ធផលស្រាវជ្រាវចម្បងៗមានជាអាទិ៍ (១) ការយល់ដឹងកាន់តែប្រសើរ ក្នុងចំណោមអ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកស្រាវជ្រាវ សិស្ស និងនិស្សិត អំពីផលពាក់ព័ន្ធដល់ជីវភាពរស់នៅនៃការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងធារាសាស្ត្រ បណ្តាលមកពី ការប្រែប្រួលអាកាសធាតុ និងប្រព័ន្ធមនុស្សនៅអាងទន្លេសាប និង (២) វិធីប្រសើរឡើងដើម្បីដាក់បញ្ចូលចំណេះដឹងមូលដ្ឋាន និងភស្តុតាងជាក់ស្តែងផ្អែកវិទ្យាសាស្ត្រ ទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងការធ្វើផែនការនៅកម្ពុជា។

ការវាយតម្លៃគ្រប់ជ្រុងជ្រោយពី បញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ចទឹក ការប្រែប្រួលអាកាសធាតុ និងសមត្ថភាពបន្សាំ ក្នុងបីខេត្ត បង្ហាញថា ការផ្លាស់ប្តូរផ្សេងៗនៃអាកាសធាតុកំពុងប៉ះពាល់ដល់ជីវភាពរស់នៅក្នុងសហគមន៍មូលដ្ឋាន ហើយផលប៉ះពាល់នេះប្រែប្រួលខុសៗគ្នាទៅតាមតំបន់។ ការរំកិលពេលចាប់ធ្លាក់ភ្លៀងនៅរដូវវស្សា មានផលពាក់ព័ន្ធយ៉ាងច្បាស់ទាំងទៅលើការធ្វើស្រែប្រាំង និងស្រែវស្សា។ ការសិក្សានេះក៏គូសរំលេចផងដែរនូវបញ្ហាដែលប៉ះពាល់ខ្លាំងបំផុតដល់សហគមន៍មូលដ្ឋាន ជាពិសេស កំណើនប្រេកង់ទឹកជំនន់ និងព្យុះភ្លៀងមានរន្ទះ ដែលពួកគេយល់ថាជាភាពងាយរងគ្រោះមួយដែរទៅនឹងការប្រែប្រួលអាកាសធាតុ។

ការធ្វើផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវមានការសម្រេចចិត្តដោយមានកិច្ចសហការគ្នា ព័ត៌មានគ្រប់គ្រាន់ និងក្របខ័ណ្ឌមួយសម្រាប់បញ្ជ្រាបបញ្ហាធន់នឹងអាកាសធាតុ ទៅក្នុងការធ្វើផែនការអភិវឌ្ឍន៍។ CDRI និងដៃគូសហការនានា មានការត្រេកអរដោយបានចូលរួមជួយកែលំអការធ្វើផែនការផ្អែកលើវិទ្យាសាស្ត្រ សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានទឹក នៅអាងទន្លេសាប។ ចំណេះដឹងទទួលបានពីគម្រោងនេះនឹងជួយលើកកម្ពស់ ការយល់ដឹងរបស់អ្នកធ្វើការសម្រេចចិត្តនៅកម្រិតមូលដ្ឋាន និងកម្រិតជាតិ អំពី (១) បែបបទដែលការប្រែប្រួលនៃអាកាសធាតុ និងប្រព័ន្ធមនុស្ស ជះឥទ្ធិពលទៅលើបរិមាណទឹក និងសន្តិសុខទឹក (២) ផលពាក់ព័ន្ធនៃការប្រែប្រួលក្នុងបរិមាណទឹកដែលមាន ទៅដល់ជីវភាពរស់នៅក្នុងតំបន់ដែនរងទឹកភ្លៀងបានចុះសិក្សា និង (៣) បែបបទដែលការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹក អាចជួយបង្កើនសមត្ថភាពបន្សាំ និងសម្រេចបានសន្តិសុខទឹក។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh។
ឯកសារបោះពុម្ពផ្សាយអាចរកបាននៅវិទ្យាស្ថាន CDRI និងនៅហាងលក់សៀវភៅ ម៉ូនូរ៉ម។

# ឧបសគ្គរារាំងការលើកកម្ពស់រូបិយវត្ថុក្នុងស្រុក៖ ការសិក្សាប្រៀបធៀបនឹងប្រទេស បូលីវី អេក្វាទ័រ និងប៉េរូ

## សេចក្តីផ្តើម

កម្ពុជា ចាប់ផ្តើមមានដុល្លារូបនីយកម្មនៅដើមទសវត្សរ៍ ១៩៩០ ហើយបច្ចុប្បន្នគេសំគាល់ថាជា សេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារខ្លាំងបំផុតនៅអាស៊ី (Duma 2011)។ ទោះបីជាមានអត្ថប្រយោជន៍មួយចំនួនដូចជា ការពង្រឹងផ្នែកហិរញ្ញវត្ថុ ការជួយសម្រួលដល់ពាណិជ្ជកម្ម សញ្ញាបង្ហាញសម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពរូបិយវត្ថុ (ដូច្នេះមិនសូវចាំបាច់មានគ្រឿងលើកទឹកចិត្ត) ក្តី ក៏ដុល្លារូបនីយកម្ម បានបង្កបញ្ហាមួយចំនួន ដែលត្រូវមានការយកចិត្តទុកដាក់ផ្នែកគោលនយោបាយ។ ដុល្លារូបនីយកម្ម ធ្វើឲ្យប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុថយចុះ កាត់បន្ថយតួនាទីជាអ្នកផ្តល់កម្ចីចុងក្រោយបង្អស់ របស់ធនាគារជាតិនៃកម្ពុជា (NBC) និងធ្វើឲ្យការគ្រប់គ្រងនយោបាយរូបិយវត្ថុមានកម្រិត។ ម្យ៉ាងវិញទៀត រូបិយវត្ថុ គឺជានិមិត្តរូបនៃអធិបតេយ្យភាពជាតិ។ ការពឹងផ្អែកលើប្រាក់ដុល្លារ ធ្វើឲ្យកម្ពុជាខាតបង់ចំណូលបានពីការផលិតរូបិយវត្ថុ (seignorage) ហើយអត្ថប្រយោជន៍នេះ បែរជាបានទៅដល់រដ្ឋាភិបាលសហរដ្ឋអាមេរិកឯណោះវិញ (Tal and Dabadie 2007)។ ដុល្លារូបនីយកម្ម មានផ្តល់ទាំងអត្ថប្រយោជន៍ និងគុណវិបត្តិ ប៉ុន្តែការវិភាគដោយប្រៀបធៀបរវាងផលប្រយោជន៍ និងការខាតបង់ បង្ហាញថា ការខាតបង់វាធំលើសពី ផលប្រយោជន៍ទទួលបាន (Kang 2005; Tal and Dabadie 2007)។

រដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិជាបន្តបន្ទាប់ បានបង្ហាញពីសមត្ថភាពក្នុងការក្សាលំនឹងអត្រាប្តូរប្រាក់ ស្ថិរភាពថ្លៃទំនិញ និងកំណើនសេដ្ឋកិច្ច (Menon 2008)។ ប៉ុន្តែ ទោះបីជា NBC បានបោះពុម្ពក្រដាសប្រាក់រៀលជាថ្មី តាំងពីជាងបីទសវត្សរ៍កន្លងមកហើយក្តី ក៏សាធារណជនមិនទាន់មានទំនុកចិត្តឡើងវិញលើរូបិយវត្ថុក្នុងស្រុកឡើយ ហើយប្រទេសកម្ពុជានៅតែកំពុងប្រឹងតស៊ូជំរុញការប្រើប្រាស់ប្រាក់រៀល ទប់ទល់នឹងរូបិយប័ណ្ណបរទេសផ្សេងៗ។ ស្ថានភាពនេះ បង្ហាញពីចន្លោះខ្វះខាតនៅក្នុងការស្រាវជ្រាវដែលមានស្រាប់។ ការសិក្សាពីមុនៗ ភាគច្រើនបានរំលងចោលសំណួរថា ហេតុអ្វីកម្ពុជាបានបរាជ័យក្នុងការលើកកម្ពស់ប្រាក់រៀល។ អត្ថបទនេះ មានបំណងចូលរួមចំណែកក្នុងការពិភាក្សានេះ ដោយទាញយកបទពិសោធន៍នៅតំបន់អាមេរិកឡាទីន ជាពិសេស នៅប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ។ អត្ថបទនេះ ចាប់ផ្តើមតាមការពិនិត្យគ្រួសៗពីប្រវត្តិប្រាក់រៀល តមកទៀតពិនិត្យពីស្ថានភាពបច្ចុប្បន្ន និងកិច្ចប្រឹងប្រែងបំបាត់ដុល្លារូបនីយកម្ម។ បន្ទាប់មក មានការពិភាក្សាពីបទពិសោធន៍នៅប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ ដើម្បីជាមេរៀនសម្រាប់កម្ពុជា។

## កត្តាប្រវត្តិសាស្ត្រដែលប៉ះពាល់ដល់ប្រាក់រៀល

### *ការបំបាត់ចោលរូបិយវត្ថុជាតិ (១៩៧៥-៧៩)*

បន្ទាប់ពីចូលកាន់អំណាចក្នុងឆ្នាំ១៩៧៥ របបខ្មែរក្រហមបានកំទេចចោលនូវអគារធនាគារជាតិ និងលុបចោលរូបិយវត្ថុ (Prasso 2001)។ ក្រដាសប្រាក់រៀល បានក្លាយជាសន្លឹកក្រដាសធម្មតា គ្មានតម្លៃដែលហើរប៉ើងរប៉ាត់រប៉ាយនៅតាមថ្នល់ គ្មាននរណាម្នាក់ចាប់អារម្មណ៍នោះឡើយ ហើយក៏គ្មានប្រតិបត្តិការហិរញ្ញវត្ថុដែរ។ ប្រព័ន្ធធនាគារ ត្រូវបំផ្លាញចោលទាំងស្រុង។

### *ការភ័យខ្លាចបន្ទាប់ពីសង្គ្រាមស៊ីវិល (របបសេដ្ឋកិច្ចផែនការ ១៩៧៩-៨៩ (១៩៧៩-៨៩)*

ដោយសេដ្ឋកិច្ចនៅយ៉ាប់យ៉ឺនខ្លាំង ហើយបទពិសោធន៍សង្គ្រាមស៊ីវិលក៏នៅថ្មីៗ ក្នុងសតិអារម្មណ៍របស់ប្រជាជននោះ ទំនុកចិត្តលើប្រាក់រៀលបានធ្លាក់ចុះដល់សូន្យ។ អង្ករឃើញមានប្រើប្រាស់ជាទូទៅជំនួសឲ្យក្រដាសប្រាក់ ដើម្បីទិញទំនិញផ្សេងៗ ហើយគេប្រើមាសដើម្បីទិញអង្ករ (Prasso 2001)។ នេះជាប្រព័ន្ធដោះដូរទំនិញ នឹងទំនិញ (Barter System)។ ទោះបីជានៅក្នុងរបបសេដ្ឋកិច្ចផែនការ ឬមានការរឹតត្បិតលើការប្រើប្រាស់រូបិយប័ណ្ណបរទេសក្តី ក៏ប្រជាជនបានប្រើប្រាស់ និងទទួលយកប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ យ៉ាងទូលំទូលាយនៅកម្ពុជា ព្រោះយល់ឃើញថា ជាមធ្យោបាយមានសុវត្ថិភាពសម្រាប់រក្សាតម្លៃ (Tal and Dabadie 2007)។

### *អស្ថិរភាពសេដ្ឋកិច្ច និងនយោបាយ៖ ឱនភាពថវិកា លំហូរចូលនៃប្រាក់ដុល្លារ និងអតិផរណាដ៏ធ្ងន់ធ្ងរ (ចុងទសវត្សរ៍១៩៨០ ដល់ ដើមទសវត្សរ៍១៩៩០)*

ចំណូលរដ្ឋាភិបាលដែលមានតិចក្នុងទសវត្សរ៍១៩៩០ បានបង្កឱនភាពថវិកាដែលដោះស្រាយមួយភាគធំដោយសាច់ប្រាក់បានពី NBC។ NBC បានបញ្ចេញរូបិយវត្ថុស្មើនឹង ២០% នៃចំណាយសាធារណៈនៅឆ្នាំ១៩៨៩ និងបង្កើនដល់ ៤០% នៅឆ្នាំ១៩៩០ (Irvin 1993)។ បន្ទាប់មក អតិផរណាក៏ចាប់ផ្តើម ហើយក្លាយជា

---

អត្ថបទនេះ រៀបចំដោយ ឃន ដាលីន កម្មសិក្សាការីផ្នែកសេដ្ឋកិច្ច នៃវិទ្យាស្ថាន CDRI ដោយប្រើប្រាស់ព័ត៌មានបានពីនិក្ខេបបទរបស់ខ្លួនក្នុងឆ្នាំ២០១៥។ សូមយោងអត្ថបទនេះថា៖ Khorn Dalin. 2016. "The Obstacles to Promoting Local Currency: A Cross-Country Study of Bolivia, Ecuador and Peru." *Cambodia Development Review* 20(1): 13-18.

១ "ផលធៀបរវាងចំណាយលើការផលិត និងចែកចាយរូបិយវត្ថុ ជាមួយនឹងចំណូលទទួលបានពីការផ្គត់ផ្គង់រូបិយវត្ថុនេះឲ្យគេប្រើប្រាស់" (Tal and Dabadie 2007: 12)។

អតិផរណាលោតផ្លោះ មានអត្រាលេខបីខ្ទង់ នៅឆ្នាំ១៩៩២។ ប្រាក់រៀលធ្លាក់ថ្លៃយ៉ាងគំហុកធៀបនឹងប្រាក់ដុល្លារ ពី ៨០០ នៅឆ្នាំ១៩៩០ ដល់ ២៦០០ រៀល/ដុល្លារ នៅខែមីនា ១៩៩២ (Irvin 1993)។ ការបាត់បង់អំណាចទិញ ផុសចេញពីការធ្លាក់ថ្លៃនេះ បានធ្វើឲ្យសាធារណជនបាត់បង់ទំនុកចិត្តលើប្រាក់រៀល។

បន្ទាប់មកទៀត ស្ថានភាពនយោបាយក្នុងស្រុក មានភាពប្រែប្រួលល្អឡើងវិញ ដោយមានការចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ ដែលបានបើកផ្លូវសម្រាប់សេរីភាវូបនីយកម្មផ្នែកនយោបាយ។ អាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNTAC) ដែលចូលមកប្រទេសកម្ពុជា ដើម្បីត្រួតពិនិត្យលើការបោះឆ្នោតថ្នាក់ជាតិលើកដំបូង បន្ទាប់ពីសង្គ្រាមស៊ីវិលនោះ ជាព្រឹត្តិការណ៍ដ៏សំខាន់បំផុត ព្រោះបាននាំមកនូវ លំហូរចូលដ៏ធំសម្បើមនៃមូលធនពីបរទេស ជាលើកទី១ ដែលភាគច្រើនក្នុងទម្រង់ជាប្រាក់ដុល្លារអាមេរិក ហើយក៏ជាប្រតិបត្តិការរក្សាសន្តិភាពនៃ អង្គការសហប្រជាជាតិ

រូបភាព១៖ ប្រាក់បញ្ញើជាប្រាក់រៀល និងរូបិយប័ណ្ណបរទេស និងការផ្គត់ផ្គង់រូបិយវត្ថុ




ប្រភព៖ Beresford et al. 2004, NBC 2005, 2010, 2013, 2014

រូបភាព២៖ ចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសនៃការផ្គត់ផ្គង់រូបិយវត្ថុ (FCD/M2)




ប្រភព៖ NBC 2005, 2010, 2013, 2014

ដែលបានចំណាយថវិកាអស់ច្រើនបំផុត រហូតដល់ប្រមាណ ១,៧ ប៊ីលានដុល្លារ (Tal and Dabadie 2007)។

## ស្ថានភាពបច្ចុប្បន្ន និងកិច្ចប្រឹងប្រែងបំបាត់ដុល្លារូបនីយកម្ម

### *សមាសធាតុនៃរូបិយវត្ថុទូទៅ (Broad Money) នៅកម្ពុជា*

ផ្នែកនេះ ពណ៌នាពីទិន្នន័យរបស់ NBC ស្ដីពីការផ្គត់ផ្គង់រូបិយវត្ថុ (M2) ពីឆ្នាំ១៩៩៣ ដល់ ២០១៤។ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (FCD) មានច្រើនជាងគេ ដោយកើនពី ៨៤% នៃបញ្ញើសរុបនៅឆ្នាំ១៩៩៣ ដល់ ៩៥% នៅឆ្នាំ២០១៤ រីឯប្រាក់បញ្ញើជាប្រាក់រៀល (RD) បានធ្លាក់ចុះពី ១៦% មកត្រឹម ៥%។ នៅពេលសេដ្ឋកិច្ចកើនឡើង FCD និង RD ក៏កើនឡើងដែរ។ ពីឆ្នាំ១៩៩៣ ដល់ ២០១៤ FCD បានកើនពី ១២១ ប៊ីលានរៀល ដល់ ៣៥.១៦១ប៊ីលានរៀល ហើយ RD កើនពី ២៣ប៊ីលានរៀល ដល់ ១៨០៥ប៊ីលានរៀល (រូបភាព១)។ ប៉ុន្តែ FCD កើនក្នុងអត្រាខ្ពស់ជាង RD ព្រោះតម្រូវការប្រាក់រៀល មានកម្រិតទាបជាងរូបិយប័ណ្ណបរទេស (Beresford et al. 2004)។ ក្នុងពេលដំណាលគ្នានោះ សន្ទស្សន៍ដុល្លារូបនីយកម្ម បានកើនពី ៣៦% ដល់ ៨៣% (រូបភាព២)។ ការគណនានេះ មិនមានគិតបញ្ចូលនូវរូបិយវត្ថុបរទេសកំពុងចរាចរទេ (FCC: Foreign Currency in Circulation outside the banking system) ហើយតួលេខរបស់វាក៏គេមិនដឹងដែរ។

### *មូលហេតុនាំឲ្យដុល្លារូបនីយកម្មបន្តកើតមាន*

មានមូលហេតុចម្បងពីរ នាំឲ្យដុល្លារូបនីយកម្ម នៅតែបន្តទៅមុខ។ មូលហេតុទី១គឺ ភាពងាយស្រួល ក្នុងការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ហើយមូលហេតុទី២ គឺតម្រូវការ និងលំហូរចូលនៃប្រាក់ដុល្លារកើនឡើង។ ការយល់ថា ប្រាក់ដុល្លារឃើញមានការប្រើប្រាស់យ៉ាងទូលំទូលាយជាស្រេច នៅក្នុងសេដ្ឋកិច្ច ធ្វើឲ្យវាក្លាយជាជម្រើសគេចូលចិត្តប្រើ នៅក្នុងប្រតិបត្តិការទូទាត់ផ្សេងៗ។ ថ្លៃទំនិញ និងសេវាភាគច្រើនគេកំណត់ជាដុល្លារ ហើយការទូទាត់ក៏ធ្វើឡើងដោយប្រើប្រាក់ដុល្លារ។ បៀវត្សរ៍ក្នុងវិស័យឯកជនភាគច្រើន តែងផ្ដល់ឲ្យជាដុល្លារ ហើយប្រាក់ឈ្នួលអប្បបរមា ក៏កំណត់ជាដុល្លារ។ លើសពីនេះទៀត បច្ចុប្បន្នមិនទាន់មានការដាក់កំហិត ឬរឹតត្បិតអ្វីលើការប្រើប្រាស់ប្រាក់ដុល្លារទេ។

ផសស នៅកម្ពុជា (គិតតាមថ្លៃបច្ចុប្បន្នជាប្រាក់ដុល្លារ) កើនជិតមួយជាបីពីឆ្នាំ២០០៣ ដល់ ២០១៣ ដោយមានអត្រាកំណើនផសស ប្រចាំឆ្នាំ ប្រហែល ៧% ពីឆ្នាំ២០១១ ទៅ ២០១៤ (World Bank 2016, 2015)។ សូចនាករសេដ្ឋកិច្ចចម្បងៗប្រាំផ្ដល់នូវភស្តុតាងនៃកំណើនលំហូរចូលប្រាក់ដុល្លារ។ ចំណូលផ្នែកទេសចរណ៍អន្តរជាតិដែលរួមចំណែក២៩,៩%ក្នុង ផសស នៅឆ្នាំ ២០១៤ បានកើនខ្ពស់ជាងមុន ៥,៥៦ដង ពីឆ្នាំ២០០៣ ដល់ ២០១៣។ ក្នុងអំឡុងពេលដដែល វិនិយោគផ្ទាល់ពីបរទេសសុទ្ធកើនខ្ពស់ជាងមុន ១៦,០២ដង ជំនួយអភិវឌ្ឍន៍ផ្លូវការសុទ្ធ កើន ១,៥៥ដង ហើយប្រាក់ផ្ញើរចរន្តសុទ្ធ កើន ១,៧៧ដង។ លើសពីនេះទៀត ដោយសារឱនភាពពាណិជ្ជកម្មសុទ្ធបានរីកធំ ស្របតាមកំណើនការនាំចូលនោះ តម្រូវការប្រាក់ដុល្លារក៏បានកើនឡើង។ សូចនាករទាំងប្រាំនេះ គេតែងគណនាជាប្រាក់ដុល្លារ ជាជាងប្រាក់រៀល។ ម្យ៉ាងទៀត ពីឆ្នាំ២០១១ ដល់ ២០១៤ ប្រាក់បញ្ញើកើន ៧,៨៨ដង ហើយកម្ចីកើន ៣,១៧ដង (NBC 2014) ដែលបង្ហាញពីការរឹងប៉ឹងឡើងផ្នែកហិរញ្ញវត្ថុ និងសកម្មភាពសេដ្ឋកិច្ចកាន់តែខ្លាំងក្លា។

សរុបមក ប្រាក់ដុល្លារផ្ដល់នូវលទ្ធភាពកាន់តែប្រសើរផ្នែកសេដ្ឋកិច្ច ដូច្នេះហើយក៏មានតម្រូវការច្រើនជាងប្រាក់រៀល។ ប្រការនេះ បានកាត់បន្ថយជាខ្លាំងនូវជម្រើសគោលនយោបាយរូបិយវត្ថុ។ ដោយហេតុថា ក្នុងរូបិយវត្ថុកំពុងចរាចរ មានប្រាក់រៀលតែមួយភាគតូចនោះ ដូច្នេះ NBC មិនអាចធ្វើអន្តរាគមន៍នៅក្នុងទីផ្សារដោយការផ្គត់ផ្គង់រូបិយវត្ថុ(ឬរូបិយវត្ថុទូទៅM2)ដើម្បីបន្ថយផលប៉ះពាល់នៃបញ្ហាហិរញ្ញវត្ថុបានឡើយ។ ហេតុនេះ ត្រូវលើកកម្ពស់ រូបិយវត្ថុក្នុងស្រុកជាចាំបាច់ ដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ជាពិសេសដើម្បីទទួលបានអំណាចផ្នែករូបិយវត្ថុ។

### *ការវិភាគពីការអនុវត្តគោលនយោបាយ*

កន្លងមក មិនទាន់មានគោលនយោបាយស្វាហាប់ណាមួយសម្រាប់លើកកម្ពស់ ប្រាក់រៀលឡើយ ហើយក៏មិនមានការកំណត់ ពេលវេលាជាក់លាក់អ្វី ដើម្បីបំបាត់ដុល្លារូបនីយកម្មឡើយ (McGrath 2015)។ ខាងផ្នែកតម្រូវការ ការទូទាត់វិក្កយបត្រអគ្គិសនីនិងទឹក ពន្ធ និងបៀវត្សរ៍ក្នុងវិស័យសាធារណៈ ត្រូវប្រើប្រាស់ប្រាក់រៀលជាចាំបាច់ (Tal and Dabadie 2007)។ អង្កេតនាពេលថ្មីៗមួយបង្ហាញថា ការទូទាត់បៀវត្សរ៍ជាប្រភពធំជាងគេនៃរូបិយប័ណ្ណបរទេសនៅកម្ពុជា (Khou and Odajima 2015)។

ខាងផ្នែកផ្គត់ផ្គង់វិញ NBC បានរក្សាស្ថិរភាពសេដ្ឋកិច្ចជាពិសេស ស្ថិរភាពថ្លៃទំនិញនិងសេវា និងអត្រាប្ដូរប្រាក់។ អតិផរណា គេគ្រប់គ្រងវាបានឲ្យនៅត្រឹម ៤% នៅឆ្នាំ២០១៣ (NBC 2013)។ លើសពីនេះទៀត NBC បានបញ្ចេញក្រដាសប្រាក់ថ្មីៗទៅក្នុងសេដ្ឋកិច្ច ដើម្បីជំនួសក្រដាសប្រាក់ចាស់ៗដែលសឹកខូច ហើយតាមនេះ អាចលើកស្ទួយមោទនភាពប្រជាជនទៅលើប្រាក់រៀល។ គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងស្របតាមច្បាប់ស្ដីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនក្នុងឆ្នាំ២០០៧។ នេះជាមធ្យោបាយមួយទៀត ដើម្បីបង្កើនការប្រើប្រាស់ប្រាក់រៀល ព្រោះការកំណត់ថ្លៃធ្វើឡើងជាប្រាក់រៀល ទាំងនៅក្នុងទីផ្សារបឋម និងទីផ្សារបន្ទាប់បន្សំ។ ទោះយ៉ាងណាក្ដី ផ្សារមូលបត្រកម្ពុជា សព្វថ្ងៃមិនទាន់លូតលាស់បានពេញលេញទេ ហើយរដ្ឋាភិបាលក៏មិនទាន់ចេញផ្សាយប័ណ្ណរតនាគារដែរ។ សមិទ្ធផលមួយទៀតគឺ NBC បានបង្កើតទីផ្សារអន្តរធនាគារមួយដែលដំណើរការបានពេញលេញហើយ ដើម្បីជួយគ្រប់គ្រងហានិភ័យនៃសាច់ប្រាក់ងាយស្រួល។ រដ្ឋាភិបាល ក៏ជិតអនុម័តចេញនូវគោលនយោបាយថ្មីៗទៀត ដើម្បីជំរុញប្រាក់រៀល និងបដិដុល្លារូបនីយកម្ម ដូចជា តាមរយៈការជំរុញទីផ្សារហិរញ្ញវត្ថុជាដើម។

## ដុល្លារូបនីយកម្មនៅប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ

### *ហេតុអ្វីជ្រើសរើសប្រទេសទាំងបីនេះសម្រាប់ការសិក្សា?*

ប្រទេសបូលីវី អេក្វាទ័រ និង ប៉េរូ ធ្លាប់មានដុល្លារូបនីយកម្មកម្រិតខ្ពស់ដូចនៅកម្ពុជាដែរ។ អត្រាជាមធ្យមនៃ FCD ធៀបនឹងប្រាក់បញ្ញើសរុបជាមធ្យម សម្រាប់អំឡុងពេលពីឆ្នាំ១៩៩៥ ដល់ ២០០៤ មានចាប់ពី ៩៤% នៅកម្ពុជា ៩០% នៅបូលីវី ៧៦% នៅអេក្វាទ័រ និង ៦៨% នៅប៉េរូ (Alvarez-Plata and Garcia-Herrero 2007)។ បូលីវី អេក្វាទ័រ និង ប៉េរូ បានអនុវត្តយុទ្ធសាស្ត្រខុសៗគ្នា ក្នុងការឆ្លើយតបទៅនឹងដុល្លារូបនីយកម្ម។ អេក្វាទ័រ បានប្រែក្លាយប្រទេសខ្លួនជាសេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារជាផ្លូវការ រីឯ បូលីវី និង ប៉េរូ បានជ្រើសយក បដិដុល្លារូបនីយកម្ម ជាជម្រើសដំបូង។ បូលីវី និង ប៉េរូ បានតម្រូវឲ្យអនុវត្តគោលនយោបាយនេះជាកាតព្វកិច្ច ប៉ុន្តែវាត្រឹមតែធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើង និងកាន់តែជំរុញដុល្លារូបនីយកម្ម។ យុទ្ធវិធីទី២ របស់ពួកគេ គឺការអភិវឌ្ឍទីផ្សារ ដែលទទួលបានជោគជ័យច្រើនជាងយុទ្ធវិធីមុន។

### *បទពិសោធន៍របស់ប្រទេសទាំងបី៖ មុន និងក្រោយពេលដុល្លារូបនីយកម្មកើតឡើង*

អេក្វាទ័រ បានប្រើប្រាស់ប្រាក់ដុល្លារជាផ្លូវការនៅឆ្នាំ២០០០ ជាផ្នែកមួយនៃកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីគ្រប់គ្រងអស្ថិរភាពសេដ្ឋកិច្ច និងនយោបាយធ្ងន់ធ្ងរ។ បន្ទាប់ពីក្លាយជា សេដ្ឋកិច្ចប្រើប្រាក់ដុល្លារជាផ្លូវការ អត្រាអតិផរណាបានធ្លាក់ចុះយ៉ាងខ្លាំង ពី ៩៦,០៩% នៅឆ្នាំ២០០០ មក ៣៧,៦៨% នៅឆ្នាំ២០០១ និង ៣,៥៧%នៅឆ្នាំ២០១៤ (World Bank 2016)។នៅចុងទសវត្សរ៍ ១៩៩០ អេក្វាទ័រ បានជួបនឹងការធ្លាក់ចុះអត្រាកំណើន រហូតដល់ -៤,៧៤% នៅឆ្នាំ១៩៩៩។ និន្នាការនេះ បានប្រែប្រួលប្រសើរឡើងវិញជាបណ្ដើរៗចាប់ពីឆ្នាំ២០០០ មក ដោយ ផសស បាន កើនរហូតដល់ ៣,៨០% ក្នុងឆ្នាំ២០១៤។ ម្យ៉ាងវិញទៀត ពាណិជ្ជកម្មដែលនៅស្ពឹកស្រពន់ខ្លាំង មុនពេលដុល្លារូបនីយកម្មផ្លូវការនោះ បានកើនអត្រារួមចំណែកនៅក្នុង ផសស។

ស្រដៀងនឹងបទពិសោធន៍របស់អេក្វាទ័រដែរ ដុល្លារូបនីយកម្មនៅបូលីវី បានកើតមានឡើងជាចម្លើយតបនឹងអតិផរណាលោតផ្លោះ និងអស្ថិរភាពសេដ្ឋកិច្ចនៅទសវត្សរ៍១៩៧០។ ប៉ុន្តែ វិបត្តិជញ្ជីងទូទាត់ និងអត្រាអតិផរណា ៣២,១៣% នៅឆ្នាំ១៩៨១ បាននាំឲ្យមានការដាក់អនុវត្ត គោលនយោបាយបដិដុល្លារូបនីយកម្មជាកាតព្វកិច្ចក្នុងឆ្នាំ១៩៨២។ ប្រាំឆ្នាំជាប់ៗគ្នានៃកំណើន ផសស អវិជ្ជមាន និងអតិផរណាលោតផ្លោះ បានកើតមានឡើងបន្ទាប់ពីនោះ។ អត្រាអតិផរណាប្រចាំឆ្នាំជាមធ្យមស្ទុះឡើងយ៉ាងលឿន ដល់ ១២៣,៥៤% ក្នុងឆ្នាំ១៩៨២ ១១.៧៤៩,៦៤% ក្នុងឆ្នាំ១៩៨៥ និង ២៧៣,៣៥% ក្នុងឆ្នាំ១៩៨៦ មុននឹងធ្លាក់ចុះមកក្នុងកម្រិតអាចគ្រប់គ្រងបានវិញ ប្រមាណពី ១៤ ទៅ ២១% នៅអំឡុងឆ្នាំ១៩៨៧-៩២ (World Bank 2016)។ បន្ទាប់ពីនោះមក គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ ដែលបានដាក់អនុវត្តនៅឆ្នាំ២០០៦ ក៏ចាប់ផ្ដល់លទ្ធផលជាវិជ្ជមាន។ នៅឆ្នាំ២០១៤ ប្រាក់បញ្ញើជារូបិយវត្ថុបូលីវីយ៉ាណូ របស់បូលីវី ធៀបនឹងប្រាក់បញ្ញើសរុប កើនដល់ ៧៨% ធៀបនឹង ២៣% នៅឆ្នាំ២០០៦ រីឯឥណទានក្នុងស្រុកធៀបនឹងឥណទានសរុប កើនដល់ ៩២% ធៀបនឹង ១៥% នៅឆ្នាំ ២០០៦ (Catacora 2014)។

ការព្យាយាមសម្រេចនូវ លក្ខណៈវិនិច្ឆ័យបី (ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយប្រយ័ត្នប្រយែង និងចីរភាពប្រទេសជាតិក្នុងផ្នែកបំណុល) ហាក់ទទួលបានជោគជ័យក្នុងការធ្វើឲ្យសេដ្ឋកិច្ចបូលីវី មានលំនឹង បន្ទាប់ពីការអនុវត្តបដិដុល្លារូបនីយកម្ម (Staines 2014)។ គោលនយោបាយនៅអំឡុងទសវត្សរ៍១៩៩០ នាំឲ្យមានអតិផរណាទាបជាងមុន កំណើនថេរនៃ ផសស និងកំណើនពាណិជ្ជកម្ម។ គោលនយោបាយលើកទឹកចិត្ត ដើរតួនាទីសំខាន់ក្នុងការជំរុញប្រាក់បូលីវីយ៉ាណូ ជាចម្បងតាមរយៈ អត្រាខុសគ្នាខ្លាំងនូវប្រាក់បម្រុងកាតព្វកិច្ច ការបង្កើតសំវិធានធនសម្រាប់ទប់ទល់ហានិភ័យលើឥណទាន ការដាក់កម្រិតលើបំណុលជាប្រាក់បរទេសសុទ្ធ និងពន្ធលើប្រតិបត្តិការហិរញ្ញវត្ថុជាប្រាក់បរទេស (Staines 2014)។ តួយ៉ាង ធនាគារកណ្ដាលបូលីវី បានបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ច ពី ៧,៥% ដល់ ៣០% និងកំណត់អត្រាប្ដូរប្រាក់ (ថ្លៃទិញ និងថ្លៃលក់ អតិបរមា និងអប្បបរមា) សម្រាប់រូបិយប័ណ្ណបរទេស ឲ្យខ្ពស់ជាង សម្រាប់ប្រាក់បូលីវីយ៉ាណូ។ ប្រតិបត្តិការជារូបិយប័ណ្ណបរទេសលើសពី ២០០០ ដុល្លារ ត្រូវជាប់ពន្ធ (MEPF 2013)។ ប្រាក់បៀវត្សរ៍អប្បបរមានៅបូលីវី គេកំណត់វាជារូបិយវត្ថុក្នុងស្រុក គឺខុសពីនៅកម្ពុជា។ បំណុលរដ្ឋាភិបាល គិតជាភាគរយនៃ ផសស ធ្លាក់ចុះពី ៨០,៤% នៅឆ្នាំ២០០៥ មកត្រឹម ៣២,៤% នៅឆ្នាំ២០១៤ ដែលនាំឲ្យបូលីវីជាប់ចំណាត់ថ្នាក់ទី៥ ដោយ Trading Economics (2016)[២]។ លក្ខខណ្ឌទីផ្សារទាំងនេះ អំណោយផលដល់រដ្ឋាភិបាលក្នុងការចេញប័ណ្ណរតនាគារ ជាពិសេស ប័ណ្ណមានទឹកប្រាក់ជារូបិយវត្ថុបូលីវីយ៉ាណូ ដែលបានជួយកាត់បន្ថយ ដុល្លារូបនីយកម្មផ្នែកឥណទាន (Garcia-Escribano and Sosa 2011)។

ប្រទេសប៉េរូ ក៏ធ្លាប់ជួបនឹងអតិផរណាលោតផ្លោះ និងកំណើនដុល្លារូបនីយកម្មដែរ នៅពាក់កណ្ដាលទសវត្សរ៍១៩៧០ ដែលកាន់តែធ្ងន់ធ្ងរឡើង រហូតដល់រដ្ឋាភិបាលត្រូវបង្ខំឲ្យប្រជាជនប្ដូររូបិយប័ណ្ណបរទេសដែលខ្លួនមាន ទៅជារូបិយវត្ថុក្នុងស្រុក។ ប៉ុន្តែវិធានការនេះ ហុចលទ្ធផលផ្ទុយពីគោលបំណង ព្រោះដុល្លារូបនីយកម្ម បន្តកើនឡើង ហើយប្រាក់បញ្ញើជាប្រាក់ដុល្លារកើនដល់ ៨០% នៃបញ្ញើសរុបនៅឆ្នាំ១៩៩០ ធៀបនឹងជាង ៦០%

---

២ ការកំណត់គុណសម្បត្តិផ្នែកបំណុល ដែលរាយការណ៍ឡើងដោយ សេវាកំណត់គុណសម្បត្តិចម្បងៗប្រាំ គឺ Moody's, Standard & Poor's, Fitch, Economic Indicators, និង Financial Markets បែងចែកចំណាត់ថ្នាក់ទាំង១០ នៅក្នុង Trading Economics (2016) ដូចតទៅ៖ ទី១ ចំណាត់ថ្នាក់កំពូល ទី២ ចំណាត់ថ្នាក់ខ្ពស់ ទី៣ ចំណាត់ថ្នាក់មធ្យមកម្រិតខ្ពស់ ទី៤ ចំណាត់ថ្នាក់មធ្យមកម្រិតទាប ទី៥ ចំណាត់ថ្នាក់មានការឆក់ឱកាសកេញចំណេញមិនគួរវិនិយោគ ទី៦ ចំណាត់ថ្នាក់មានការឆក់ឱកាសកេញចំណេញខ្លាំង ទី៧ ចំណាត់ថ្នាក់មានហានិភ័យខ្ពស់ ទី៨ ចំណាត់ថ្នាក់មានការឆក់ឱកាសកេញចំណេញខ្លាំងបំផុត ទី៩ ចំណាត់ថ្នាក់មិនអាចសងបំណុលដោយមានការប្រមើលឃើញពីលទ្ធភាពតិចតួចក្នុងការរើបឡើងវិញ និង ទី១០ ចំណាត់ថ្នាក់មិនអាចសងបំណុល។

បន្តិច នៅទសវត្សរ៍១៩៨០ (Staines 2014)។ គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ ដើរតួនាទីសំខាន់បំផុតក្នុងការជួយសម្រួលបដិដុល្លារូបនីយកម្មនៅប្រទេសប៉េរូ។ ដំបូង វាជួយទប់កំណើនអតិផរណា ដោយធ្វើឲ្យអតិផរណាថយចុះជាងពាក់កណ្ដាល ពី ១៦៣,៤០% នៅឆ្នាំ១៩៨៥ មកត្រឹម ៧៧,៩២% នៅឆ្នាំ១៩៨៦ ប៉ុន្តែ នៅឆ្នាំក្រោយៗនោះទៀត អតិផរណាបានស្ទុះឡើងវិញ រហូតដល់កម្រិតកំពូល ៧៤៨១,៦៦% នៅឆ្នាំ១៩៩០ (World Bank 2016)។ គោលនយោបាយជាច្រើន ដែលបានដាក់អនុវត្តនៅដើមទសវត្សរ៍ ២០០០ បានធ្វើឲ្យប្រាក់បញ្ញើជាប្រាក់ដុល្លារ ធ្លាក់ចុះមកត្រឹម ៥២% ហើយដុល្លារូបនីយកម្មឥណទានធ្លាក់មកត្រឹម ៥៥% នៅឆ្នាំ២០០៩ ធៀបនឹងជិត ៨០% ដូចគ្នានៅឆ្នាំ២០០១។

នៅទសវត្សរ៍២០០០ ម៉ាក្រូសេដ្ឋកិច្ចនៅប៉េរូ គេប្រមើលឃើញល្អ ដោយសារអតិផរណាបានថយចុះ ហើយ ផសស មានកំណើនវិជ្ជមាន។ បំណុលរដ្ឋាភិបាល គិតជាចំណែកនៃ ផសស បានថយចុះ ធ្វើឲ្យប៉េរូឡើងដល់ចំណាត់ថ្នាក់ទី៤ នៅក្នុង Trading Economics (2016) និងបានចេញផ្សាយប័ណ្ណរតនាគារមានទឹកប្រាក់ជារូបិយវត្ថុក្នុងស្រុក។ គោលនយោបាយប្រយ័ត្នប្រយែងបានអនុម័តប្រើ រួមមាន អត្រាខុសគ្នាខ្លាំងនូវប្រាក់បម្រុងកាតព្វកិច្ច ការបង្កើតសំវិធានធន សម្រាប់ទប់ទល់ហានិភ័យលើឥណទាន និង ការដាក់កម្រិតលើបំណុលជាប្រាក់បរទេសសុទ្ធ។ មានគម្លាតគ្នាយ៉ាងធំរវាង អត្រាប្រាក់បម្រុងកាតព្វកិច្ច សម្រាប់ប្រាក់សុលប៉េរូ (តិចជាង ៥%) នឹងរូបិយប័ណ្ណបរទេស (ជាង ៣០%) (Garcia-Escribano 2010) ហើយសំវិធានធន សម្រាប់ទប់ទល់ហានិភ័យលើឥណទាន ជារូបិយប័ណ្ណបរទេស (២០%) ត្រូវបានកំណត់ខ្ពស់ជាង សំវិធានធន លើឥណទានជារូបិយវត្ថុក្នុងស្រុក (៨%)។ ធនាគារកណ្ដាលរបស់ប៉េរូ រក្សាស្ថិរភាពអត្រាប្ដូរប្រាក់ ដោយការសន្សំបង្គរទុនបម្រុងអន្តរជាតិ (Sossini, Quispe and Serrano 2013)។ ដូចគ្នានឹងនៅ ប្រទេសបូលីវីដែរ ប្រាក់បៀវត្សរ៍អប្បបរមានៅ ប្រទេសប៉េរូ ត្រូវបានកំណត់ជារូបិយវត្ថុក្នុងស្រុក។

## *ភាពស្រដៀងគ្នា ភាពខុសគ្នា និងគោលនយោបាយ*

នៅបូលីវី កម្ពុជា អេក្វាទ័រ និងប៉េរូ ដុល្លារូបនីយកម្មជាការឆ្លើយតបទៅនឹងអស្ថិរភាពសេដ្ឋកិច្ច និងនយោបាយ ជាពិសេសអតិផរណាលោតផ្លោះ។ ករណីនៅកម្ពុជា ខុសប្លែកពីប្រទេសឯទៀតទាំងអស់ ព្រោះរូបិយវត្ថុក្នុងស្រុក ត្រូវបានបោះបង់ចោលស្ទើរតែទាំងស្រុង(១៩៧៥-៧៩)ហើយបន្តិចក្រោយមកសេដ្ឋកិច្ចកម្ពុជាមានប្រាក់ដុល្លារអាមេរិកច្រើនសន្ធឹកសន្ធាប់ ហូរចូលណែនណាន់តាន់តាប់ភ្លាមៗ រហូតដល់ស្មើនឹង ពីរភាគបី នៃ ផសស នៅឆ្នាំ១៩៩៣ (Khou and Ken 2015)។

មេរៀនពីប្រទេសអេក្វាទ័រ បង្ហាញថា កម្ពុជាមិនគួរជ្រើសរើសដំណោះស្រាយ ពេលគឺ ដុល្លារូបនីយកម្មជាផ្លូវការទេ ព្រោះម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា គេប្រមើលថា មានស្ថិរភាពល្អ និងមាននិន្នាការវិជ្ជមាន។ ផ្អែកលើបទពិសោធន៍ដែលបូលីវី និងប៉េរូ បានឆ្លងកាត់ មានការជួយមតិយ៉ាងខ្លាំងក្លាថា កម្ពុជាគួរជៀសវាងបដិដុល្លារូបនីយកម្មជាកាតព្វកិច្ច ពីព្រោះ វាអាចត្រឹមតែធ្វើឲ្យ ដុល្លារូបនីយកម្មកាន់តែកើនឡើង។ ក្នុងបញ្ហានេះ ការអភិវឌ្ឍទីផ្សារ អាចជាគោលនយោបាយដ៏ប្រសើរ សម្រាប់លើកកម្ពស់ប្រាក់រៀល (Tal and Dabadie 2007; Duma 2011)។ ការប្រៀបធៀបឆ្លងកាត់ប្រទេសនូវ បុរេលក្ខខណ្ឌសម្រាប់បដិដុល្លារូបនីយកម្មបានបង្ហាញនូវភាពមិនមិនស៊ីគ្នារវាងគោលនយោបាយលើកកម្ពស់ប្រាក់រៀល និង គោលនយោបាយទាក់ទាញលំហូរចូលមូលធនមកកម្ពុជា ពីព្រោះ កិច្ចប្រឹងប្រែងទាក់ទាញភ្ញៀវទេសចរ និងវិនិយោគិនបរទេស វាជាគ្រឿងលើកទឹកចិត្តឲ្យប្រើប្រាក់ដុល្លារ។

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅអេក្វាទ័រ មិនខុសគ្នាអ្វីច្រើនពីនៅប៉េរូ និងបូលីវីទេ ប៉ុន្តែអេក្វាទ័រជាប់ចំណាត់ថ្នាក់ទី៦ នៅក្នុង Trading Economics (2016) ព្រោះមិនអាចចេញផ្សាយរូបិយវត្ថុក្នុងស្រុករបស់ខ្លួនបាន។ កត្តាមួយដែលចូលរួមចំណែកកាត់បន្ថយដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ចនៅបូលីវី និងប៉េរូ គឺការចេញផ្សាយប័ណ្ណរតនាគារជារូបិយវត្ថុក្នុងស្រុក។ ដោយស្ថិតនៅចំណាត់ថ្នាក់ទី៦ កម្ពុជាមានស្ថានភាពល្អ ដើម្បីចេញផ្សាយប័ណ្ណរតនាគារជាប្រាក់រៀល។ ការធ្វើដូច្នេះ អាចជួយជំរុញការប្រើប្រាស់ប្រាក់រៀល ហើយបង្កើនបំណុលក្នុងស្រុក ជាជាងបំណុលបរទេស។

ក្នុងចំណោមគោលនយោបាយប្រយ័ត្នប្រយែង បានអនុម័តប្រើដោយប្រទេសទាំងបី ដូចបានលើកយកមកសិក្សាប្រៀបធៀបនេះ គោលនយោបាយដែលហុចលទ្ធផលជាផ្លែផ្កាច្រើនជាងគេក្នុងការគ្រប់គ្រងដុល្លារូបនីយកម្ម មានបីសំខាន់ៗ គឺអត្រាប្រាក់បម្រុងកាតព្វកិច្ច ការបង្កើតសំវិធានធន សម្រាប់ហានិភ័យលើឥណទាន និងអន្តរាគមន៍លើអត្រាប្ដូរប្រាក់។ បូលីវី និង ប៉េរូ បានកំណត់ឲ្យមានគម្លាតគ្នាយ៉ាងធំរវាង អត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេស និងជារូបិយវត្ថុក្នុងស្រុក ប៉ុន្តែកម្ពុជាកំណត់គម្លាតនេះ តូចណាស់ គឺ ៨% សម្រាប់ប្រាក់រៀល និង ១២,៥% សម្រាប់រូបិយប័ណ្ណបរទេស (NBC 2016)។ ប្រទេសដែលបានយកមកប្រៀបធៀបទាំងបី បានដាក់អនុវត្តនូវ គោលនយោបាយដែលផ្ដល់អត្ថប្រយោជន៍ដល់រូបិយវត្ថុក្នុងស្រុក ច្រើនជាងរូបិយប័ណ្ណបរទេស។ ប៉ុន្តែ គោលនយោបាយកម្ពុជាផ្ដល់លក្ខខណ្ឌស្ទើរតែប្រហាក់ប្រហែលគ្នា សម្រាប់ការប្រើប្រាក់រៀល និងប្រាក់ដុល្លារ។ គេឃើញមានការជំរុញឲ្យប្រើប្រាស់ប្រាក់រៀលដែរ ហើយបញ្ញើជាប្រាក់រៀល ទទួលបានអត្រាការប្រាក់ខ្ពស់ជាង ប៉ុន្តែកម្ចីជាប្រាក់រៀល ត្រូវបានគិតការប្រាក់ខ្ពស់ជាងបន្តិចទៅវិញ បើប្រៀបធៀបនឹងកម្ចីជាប្រាក់ដុល្លារ (NBC 2013)។ ប្រទេសបូលីវីបានអនុវត្តយកពន្ធលើប្រតិបត្តិការជារូបិយប័ណ្ណបរទេស និងបានកំណត់ពីទំហំនៃសំណុំកម្ចីជារូបិយវត្ថុក្នុងស្រុក។ កម្ពុជានៅមិនទាន់មានអនុវត្តគោលនយោបាយនេះទេ។

## សេចក្ដីសន្និដ្ឋាន

ដុល្លារូបនីយកម្មកម្រិតខ្ពស់យូរអង្វែង នៅកម្ពុជា បង្កឡើងជាចម្បងមកពី ភាពមិនស៊ីគ្នានៃគោលនយោបាយដែលបង្កើតឡើង សម្រាប់លើកកម្ពស់ប្រាក់រៀល និងទាក់ទាញលំហូរចូលមូលធន។ កម្ពុជា ពិបាកនឹងអនុវត្តតាមបទពិសោធន៍នៅប្រទេសបូលីវី និងប៉េរូ ព្រោះ NBC មានតិចជាងនូវឧបករណ៍ខាងគោលនយោបាយ ដែលខ្លួនអាចប្រើបាន ហើយគោលនយោបាយដែលមានស្រាប់ មិនបានលើកទឹកចិត្តគ្រប់គ្រាន់ សម្រាប់លើកកម្ពស់ ការប្រើប្រាស់ប្រាក់រៀលឲ្យបានទូលំទូលាយឡើយ។ ម្យ៉ាងទៀត ទីផ្សារមូលធននៅកម្ពុជានៅមិនទាន់រីកលូតលាស់ពេញលេញទេ។ ប្រសិនបើកម្ពុជាចង់រក្សាវិស័យម៉ាក្រូសេដ្ឋកិច្ច និង នយោបាយឲ្យនៅតែមានលក្ខណៈវិជ្ជមានទៅអនាគតនោះ កម្ពុជាត្រូវធ្វើការកែលំអទីផ្សារមូលធនរបស់ខ្លួន។ ចំណុចនេះ អាចសម្រេចបាន តាមរយៈការចេញផ្សាយប័ណ្ណរតនាគារ។ ម្យ៉ាងវិញទៀត ដើម្បីបង្កើតនូវការលើកទឹកចិត្តឲ្យគេចង់ប្រើប្រាស់ប្រាក់រៀល គួរមានគោលនយោបាយប្រយ័ត្នប្រយែងច្រើនថែមទៀត និងសមស្របតាមស្ថានភាពទីផ្សារ និងគួរកាត់បន្ថយភាពមិនស៊ីគ្នាផ្នែកគោលនយោបាយឲ្យមកនៅកម្រិតទាបបំផុត។

## ឯកសារយោង

Alvarez-Plata, P., and A. García-Herrero. 2007. "To Dollarize or De-dollarize: Consequences for Monetary Policy." Manila: Asian Development Bank.

Beresford, Melanie, Nguon Sokha, Rathin Roy, Sau Sisovanna and Ceema Namazie**.** 2004. *The Macroeconomics of Poverty Reduction in Cambodia.* Phnom Penh: UNDP.

Catacora, Luis Alberto Arce. 2014. "The Model that Changed Bolivia's Economy." PowerPoint presentation at Harvard University, 5 September.

Duma, Nombulelo. 2011. *Dollarization in Cambodia: Causes and Policy Implications*. Working Paper 11/49. Washington: International Monetary Fund.

García-Escribano, Mercedes. 2010. *Peru: Drivers of De-dollarization*. Working Paper 10/169. Washington: International Monetary Fund.

García-Escribano, Mercedes, and Sebastian Sosa. 2011. *What is Driving Financial De-dollarization in Latin America?* Working Paper 11/10. Washington: International Monetary Fund.

Irvin, George. 1993. *Rebuilding Cambodia's Economy: UNTAC and Beyond.* Working Paper No. 149. The Hague: Institute of Social Studies.

Kang, K. 2005. " Is Dollarization Good for Cambodia?" *Global Economic Review* 34(2): 201-211.

Khorn Dalin. 2015. "The Obstacles to Promoting Local Currency: A Cross-Country Study of Bolivia, Ecuador and Peru", Master's thesis, Korea Development Institute School of Public Policy and Management.

Khou Vouthy and Ken Odajima. 2015. *Dollarization or Dedollarization? Dollarization in Cambodia Policy to Promote the Usage of Riel*. Phnom Penh: National Bank of Cambodia and JICA Research Institute.

McGrath, Cam 2015. "Central Bank Seeks To Promote Riel Use." *Khmer Times*, 1 July.

Menon, Jayant. 2008. "Cambodia's Persistent Dollarization: Causes and Policy Options."*ASEAN Economic Bulletin* 25(2): 228-237.

MEPF (Ministry of Economy and Public Finance). 2013. *Memoria De La Economía Boliviana 2013.* Phnom Penh: Ministry of Economy and Public Finance.

NBC (National Bank of Cambodia). 2005. *Annual Report 2005.* Phnom Penh: National Bank of Cambodia.

NBC. 2010. *Annual Report 2010.* Phnom Penh: National Bank of Cambodia.

NBC. 2013. *Annual Report 2013.* Phnom Penh: National Bank of Cambodia.

NBC. 2014. *2014 Annual Report: General Directorate of Banking Supervision.* Phnom Penh: National Bank of Cambodia.

NBC.2016. "Reserve Requirements." Accessed 2 Feb 2016, http://nbc.org.kh/english/monetary_ policy/reserve_ requirements.php.

Prasso, S.T. 2001. "The Riel Value of Money: How the World's Only Attempt to Abolish Money Has Hindered Cambodia's Economic Development." *AsiaPacific Issues No. 49*. Honolulu: East-West Center.

Rossini, Renzo, Zenon Quispe and Enrique Serrano. 2013. *Foreign Exchange Intervention in Peru.* BIS Papers No 73. Accessed 26 Apr 2016, http://www.bis.org/publ/bppdf/bispap 73r.pdf.

Staines, N. 2014. "De-Dollarization: A Cross-Country Perspective." Washington: International Monetary Fund.

Tal Nay Im and Michael Dabadie. 2007. "Dollarization in Cambodia." Phnom Penh: National Bank of Cambodia.

Trading Economics. 2016. "Credit Rating." Accessed 3 Oct 2015, www.tradingeconomics.com/ country-list/rating.

World Bank. 2015. "Maintaining High Growth: Cambodia Economic Update". Phnom Penh: World Bank.

World Bank. 2016. "World Development Indicators 2015." Accessed 26 Apr 2016, http://data.worldbank.org/country/cambodia.

WTTC (World Travel and Tourism Council). 2015. "Travel and Tourism: Economic Impact 2015 Cambodia." London: World Travel and Tourism Council.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាពីសូចនាករសេដ្ឋកិច្ចនៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍។

នៅត្រីមាសទី៤ ឆ្នាំ២០១៥ ផសស ពិត នៅឥណ្ឌូនេស៊ីកើន ៥,០%។ កំណើន ផសស នៅម៉ាឡេស៊ី មានកម្រិត ៤,៥%។ សេដ្ឋកិច្ចប្រទេសសិង្ហបុរី មានកំណើន ១,៨% ធៀបនឹង ២,១% នៅត្រីមាសដូចគ្នា កាលពីឆ្នាំមុន។ ថៃមានអត្រាកំណើន ផសស ប្រចាំឆ្នាំ ២,៨% ប៉ុន្តែទាបជាងឆ្នាំមុន ០,១ឯកតាភាគរយ។ កំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំនៅវៀតណាម ឡើងដល់ ៧,០% ដោយសារមានកំណើនផលិតផលផ្នែកឧស្សាហកម្ម និងវិនិយោគបរទេសកម្រិតខ្ពស់។

នៅត្រីមាសទី៤ ឆ្នាំ២០១៥ កំណើន ផសស ពិត នៅចិនឡើងដល់ ៦,៨% និង ហុងកុង ដល់ ១,៩% ។ កំណើននៅកូរ៉េខាងត្បូង ឡើងដល់ ៣,០% រីឯនៅតៃវ៉ាន់ វាធ្លាក់ចុះដល់ -០,៥%។ តៃវ៉ាន់មានកំណើនទាបបំផុតនៅត្រីមាសនេះ គិតចាប់ពីអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុសាកលមក។

នៅត្រីមាសទី៤ នេះដែរ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅសហភាពអឺរ៉ុប មានកម្រិត ១,៥%។ កំណើន ផសស ពិតនៅជប៉ុនធ្លាក់ចុះមកត្រឹម ០,៥%។ ចំណាយផ្ទាល់ខ្លួនកម្រិតទាបនៅជប៉ុនវារួមចំណែកនៅក្នុងកំណើនទាបនេះ។ កំណើន ផសស ពិតនៅសហរដ្ឋអាមេរិក ធ្លាក់ចុះមកត្រឹម ១,៨% ធៀបនឹង ២,៤% កាលពីមួយឆ្នាំមុន។តម្លៃរឹងមាំនៃប្រាក់ដុល្លារបានបង្កើនថ្លៃទំនិញនាំចេញនៅសហរដ្ឋអាមេរិក។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០១៥ អត្រាអតិផរណានៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ី បានកើនឡើង រីឯប្រទេសអាស៊ានខ្លះទៀតនៅតែមានបរិត្តផរណា។

អតិផរណានៅកម្ពុជា មានកម្រិត ២,០% ធៀបមួយឆ្នាំមុន។ កំណើនថ្លៃសាំងនៅឥណ្ឌូនេស៊ី ធ្វើឲ្យអតិផរណាកើនឡើង ចាប់តាំងពីឆ្នាំ២០១៣ មក។ នៅត្រីមាសទី៤ ឆ្នាំ២០១៥ អតិផរណានៅឥណ្ឌូនេស៊ី ចុះទាបជាងត្រីមាសមុន ២,៣ឯកតាភាគរយ ប៉ុន្តែវានៅតែមានកម្រិតខ្ពស់ នៅក្នុងចំណោមប្រទេសអាស៊ាន។ អតិផរណានៅម៉ាឡេស៊ី មានអត្រា ២,៦% គឺចុះទាបជាងត្រីមាសមុន ០,៤ឯកតាភាគរយ។ បរិត្តផរណានៅតែបន្តកើតមាននៅសិង្ហបុរី ក្នុងអត្រា ០,៧%។ បរិត្តផរណា កើតមានឡើង ៤ត្រីមាសជាប់ៗគ្នានៅប្រទេសថៃ ហើយក្នុងត្រីមាសទី៤ នេះ វាមានអត្រា ០,៩%។ អតិផរណានៅវៀតណាម មានអត្រា ០,៣% ហើយក្នុងឆ្នាំ២០១៥ នេះ វាបានថយចុះគួរឲ្យកត់សំគាល់ បើធៀបនឹងឆ្នាំ២០១៤។

អតិផរណា បានធ្លាក់ចុះបន្តិច មកត្រឹម ១,៥% នៅប្រទេសចិន ប៉ុន្តែវាឡើងដល់ ២,៤% នៅហុងកុង និង ១,១% នៅកូរ៉េខាងត្បូង។ អតិផរណានៅតៃវ៉ាន់ មានដល់ ០,៣% តែមានត្រឹម ០% កាលពីត្រីមាសមុន។ អតិផរណា ឡើងដល់ ០,៣% នៅតំបន់អឺរ៉ូ ០,៧% នៅជប៉ុន និង ០,៤% នៅសហរដ្ឋអាមេរិក។

នៅត្រីមាសទី៤ ប្រាក់រៀល ឡើងថ្លៃ ១,០% ធៀបនឹងត្រីមាសមុន ទល់នឹងប្រាក់ដុល្លារ ដល់ ៤០៥១រៀល/ដុល្លារ រីឯប្រាក់បាតថៃ ធ្លាក់ថ្លៃ ១,៧% និង ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ១,២%។ ប្រាក់យ័ន់ចិន ធ្លាក់ថ្លៃ ១,៦% ទល់នឹងប្រាក់ដុល្លារ ធៀបនឹងត្រីមាសមុន រីឯប្រាក់យេនជប៉ុន ឡើងថ្លៃ ០,៧%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៤ ទំនិញសំខាន់ៗនៅលើទីផ្សារពិភពលោក ធ្លាក់ថ្លៃធៀបនឹងឆ្នាំមុន។ ពោត ធ្លាក់ថ្លៃ ៣,៧% មកត្រឹម ១៦៧,១ដុល្លារ/តោន ប្រេងដូងប្រេង ធ្លាក់ថ្លៃ ២៧,៦% មកត្រឹម ៥១៨,០ដុល្លារ/តោន ហើយកៅស៊ូ ធ្លាក់ថ្លៃ ២០,១% មកត្រឹម ១២២៩,១ដុល្លារ/តោន។ អង្ករ ធ្លាក់ថ្លៃ ១២,៥% មកត្រឹម ៣៧៦,៣ដុល្លារ/តោន ហើយសណ្តែកសៀង ធ្លាក់ថ្លៃ ១៨,៦% មកត្រឹម ៣៥៨,០ដុល្លារ/តោន។ ប្រេងឆៅ ធ្លាក់ថ្លៃ ៤៨,៣% មកត្រឹម ៣៨,០ដុល្លារ/ធុង ហើយវារួមចំណែកក្នុងការធ្លាក់ថ្លៃប្រេងសាំង ៣១,៩% និងប្រេងម៉ាស៊ូត ៤០,៩% ។

---

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផាវ័ន្ត ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១០-២០១៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.0 | 7.1 | 7.3 | 7.4 | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 5.1 | 5.0 | 5.4 | 4.7 | 4.7 | 4.7 | 5.0 |
| ម៉ាឡេស៊ី | 9.0 | 4.9 | 5.4 | 4.6 | 6.2 | 6.4 | 5.6 | 5.8 | 5.6 | 4.9 | 4.7 | 4.5 |
| សិង្ហបុរី | 14.7 | 4.7 | 1.3 | 3.8 | 5.1 | 2.4 | 2.4 | 2.1 | 2.6 | 1.8 | 1.9 | 1.8 |
| ថៃ | 7.9 | 0.0 | 6.7 | 2.8 | 3.1 | 0.3 | 0.6 | 2.2 | 3.3 | 2.2 | 2.9 | 2.8 |
| វៀតណាម | 6.4 | 6.2 | 5.2 | 5.4 | 4.8 | 5.5 | 6.4 | 6.8 | 6.1 | 6.5 | 6.8 | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.4 | 9.3 | 7.7 | 7.7 | 7.1 | 7.5 | 7.3 | 7.3 | 7.1 | 7.0 | 6.9 | 6.8 |
| ហុងកុង | 6.9 | 4.9 | 2.9 | 3.0 | 2.5 | 1.8 | 2.7 | 2.2 | 2.1 | 2.8 | 2.3 | 1.9 |
| កូរ៉េខាងត្បូង | 6.1 | 3.6 | 2.1 | 2.8 | 4.1 | 3.5 | 3.2 | 2.8 | 2.4 | 2.2 | 2.7 | 3.0 |
| តៃវ៉ាន់ | 11.1 | 4.2 | 1.2 | 2.2 | 3.1 | 3.7 | 3.8 | 3.3 | 3.4 | 0.5 | -1.0 | -0.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.6 | 1.6 | -0.5 | 0.1 | 0.9 | 0.7 | 0.3 | 0.9 | 1.0 | 1.2 | 1.6 | 1.5 |
| ជប៉ុន | 4.1 | -0.8 | 1.7 | 1.7 | 3.1 | -0.1 | -1.2 | 0.5 | -0.9 | 0.7 | 1.0 | 0.5 |
| សហរដ្ឋអាមេរិក | 2.7 | 1.8 | 2.1 | 1.8 | 2.3 | 2.6 | 2.3 | 2.4 | 2.7 | 2.3 | 2.2 | 1.8 |

Sources: International Monetary Fund, *Economist* and countries' statistics offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១០-២០១៥ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.1 | 5.5 | 3.0 | 3.0 | 4.5 | 4.9 | 4.0 | 2.2 | 1.0 | 1.0 | 0.8 | 2.0 |
| ឥណ្ឌូណេស៊ី | 5.1 | 5.4 | 4.3 | 7.0 | 7.7 | 7.1 | 4.3 | 6.5 | 6.6 | 7.1 | 7.1 | 4.8 |
| ម៉ាឡេស៊ី | 1.7 | 3.2 | 1.7 | 2.1 | 3.5 | 3.3 | 3.0 | 2.8 | 0.7 | 2.1 | 3.0 | 2.6 |
| សិង្ហបុរី | 2.9 | 5.2 | 4.6 | 2.3 | 1.0 | 2.3 | 0.9 | -0.1 | -0.3 | -0.4 | -0.6 | -0.7 |
| ថៃ | 3.1 | 3.8 | 3.0 | 2.2 | 2.0 | 2.5 | 2.0 | 1.1 | -0.5 | -1.1 | -1.1 | -0.9 |
| វៀតណាម | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 4.7 | 4.5 | 5.4 | 0.7 | 1.0 | 0.5 | 0.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 3.2 | 5.4 | 2.7 | 2.6 | 2.1 | 2.2 | 2.0 | 1.5 | 1.2 | 1.4 | 1.7 | 1.5 |
| ហុងកុង | 2.4 | 5.3 | 4.1 | 4.0 | 4.1 | 3.6 | 4.9 | 5.0 | 4.4 | 3.1 | 2.3 | 2.4 |
| កូរ៉េខាងត្បូង | 3.0 | 4.4 | 2.1 | 1.1 | 1.1 | 1.6 | 1.4 | 1.0 | 0.6 | 0.5 | 0.6 | 1.1 |
| តៃវ៉ាន់ | 1.0 | 1.4 | 1.9 | 0.8 | 1.1 | 1.6 | 1.5 | 1.6 | 2.9 | -0.7 | 0.0 | 0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.6 | 2.7 | 2.5 | 1.4 | 0.6 | 0.6 | 0.4 | 0.2 | -0.3 | 0.2 | 0.0 | 0.3 |
| ជប៉ុន | -0.7 | 0.1 | -0.03 | 0.4 | 1.5 | 3.6 | 3.4 | 2.6 | 2.3 | 0.5 | 0.2 | 0.7 |
| សហរដ្ឋអាមេរិក | 1.7 | 3.2 | 2.1 | 1.5 | 1.4 | 2.1 | 1.8 | 1.3 | -0.4 | 0.0 | 0.1 | 0.4 |

Sources: International Monetary Fund, *Economist* and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១០-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4187.1 | 4063.6 | 4037.8 | 5369.6 | 3993.8 | 4026.9 | 4059.5 | 4070.1 | 4042.2 | 4056.7 | 4091.8 | 4050.9 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9089.9 | 4374.0 | 9363.0 | 13892.2 | 11765.8 | 11615.3 | 11775.7 | 12244.1 | 12809.9 | 13125.2 | 13858.0 | 13786.3 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.2 | 1.5 | 3.1 | 4.2 | 3.3 | 3.2 | 3.2 | 3.4 | 3.6 | 3.7 | 4.1 | 4.3 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.4 | 1.3 | 1.2 | 1.7 | 1.3 | 1.3 | 1.3 | 1.3 | 1.4 | 1.3 | 1.4 | 1.4 |
| ថៃ (បាត) | 31.7 | 30.5 | 31.1 | 41.0 | 32.6 | 32.4 | 32.1 | 32.7 | 32.6 | 33.2 | 35.2 | 35.8 |
| វៀតណាម (ដុង) | 19200.8 | 20574.3 | 20856.9 | 27987.1 | 21093.8 | 20923.2 | 21221.9 | 21314.0 | 21372.9 | 21712.7 | 22164.6 | 22420.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.8 | 6.5 | 6.3 | 8.2 | 6.1 | 6.2 | 6.2 | 6.1 | 6.2 | 6.2 | 6.3 | 6.4 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 10.3 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1156.3 | 1108.6 | 1126.6 | 1460.0 | 1069.7 | 1028.9 | 1027.5 | 1088.4 | 1101.7 | 1097.4 | 1170.0 | 1158.3 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.3 | 29.4 | 29.6 | 39.6 | 30.3 | 30.1 | 30.0 | 30.9 | 31.6 | 30.8 | 32.0 | 32.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.7 | 0.8 | 1.0 | 0.7 | 0.7 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 87.8 | 79.9 | 79.8 | 130.2 | 102.8 | 102.1 | 104.0 | 114.6 | 119.2 | 121.4 | 122.2 | 121.4 |

Sources: International Monetary Fund, *Economist* and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១០-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No. 2) - USA (USD/តោន) | 185.9 | 291.7 | 298.4 | 259.4 | 209.9 | 214.0 | 174.1 | 173.5 | 174.2 | 168.4 | 169.5 | 167.1 |
| ប្រេងដូងប្រេង-អឺរ៉ុបពាយព្យ (USD/តោន) | 900.8 | 1125.4 | 999.3 | 856.9 | 911.3 | 887.1 | 772.0 | 715.3 | 627.9 | 664.0 | 514.6 | 518.0 |
| កៅស៊ូ SMR 5 (USD/តោន) | 3405.7 | 4630.6 | 3200.7 | 2575.3 | 2034.7 | 1777.6 | 1672.1 | 1538.1 | 1450.2 | 1525.9 | 1365.5 | 1229.1 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 506.6 | 558.5 | 594.8 | 533.8 | 450.7 | 411.7 | 447.0 | 430.3 | 426.0 | 396.3 | 383.3 | 376.3 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 449.8 | 540.7 | 591.4 | 538.4 | 552.3 | 517.8 | 457.3 | 439.7 | 363.9 | 393.7 | 347.6 | 358.0 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 76.8 | 106.2 | 109.5 | 105.9 | 104.7 | 105.9 | 100.8 | 73.4 | 50.9 | 60.5 | 48.2 | 38.0 |
| សាំង - US Gulf Coast (សេន/លីត្រ) | 53.3 | 71.9 | 74.6 | 71.2 | 70.1 | 74.1 | 70.0 | 48.3 | 40.1 | 49.0 | 42.2 | 32.9 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 56.1 | 75.7 | 80.7 | 78.4 | 77.5 | 77.1 | 73.7 | 57.5 | 44.6 | 48.4 | 39.9 | 34.0 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០១៥ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ កើន ៨៣,១% ធៀបនឹងត្រីមាសមុន និង ២៤១,៤% ធៀបនឹងមួយឆ្នាំមុន ដល់ ២៥៤,៦លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្មធ្លាក់ចុះ ៦៦,១% ធៀបត្រីមាសមុន មកត្រឹម ២៦,៨លានដុល្លារ។ វិនិយោគក្នុងវិស័យឧស្សាហកម្ម កើន ២១៤,៣% ដល់ ៤១០,៤លានដុល្លារ ប៉ុន្តែដោយឡែកក្នុងអនុវិស័យកាត់ដេរ វាធ្លាក់ចុះ ១៣,៣%។ វិនិយោគក្នុងវិស័យសេវាកម្ម កើន ៦,៩% ធៀបត្រីមាសមុន ដល់ ៧៤,៥លានដុល្លារ ដោយក្នុងនោះអនុវិស័យសណ្ឋាគារ និងទេសចរណ៍ រួមចំណែក ៣៨,០ លានដុល្លារ។

នៅត្រីមាសទី៤ នេះដែរ ភ្ញៀវបរទេសមកដល់កម្ពុជាសរុប កើន ៣៦,៧% ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ៩,៦% បើធៀបនឹងត្រីមាសដូចគ្នា កាលពីឆ្នាំមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ២០,៩% ហើយតាមផ្លូវគោក និងផ្លូវទឹក កើន ៥៥,៣% ធៀបនឹងត្រីមាសមុន។

ការនាំចេញសរុប ធ្លាក់ចុះ ១១,០% ធៀបត្រីមាសមុន ប៉ុន្តែកើន ៨,១% ធៀបឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ រួមចុះ ១៥,៧% ធៀបត្រីមាសមុន មកត្រឹម ១៦៨១,២លានដុល្លារ។ ការនាំចេញទៅសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ធ្លាក់ចុះ ១០,៤% និង ២៥,០% រៀងគ្នា ធៀបត្រីមាសមុន ប៉ុន្តែការនាំចេញទៅប្រទេសអាស៊ាន កើន ៤,៣%។ ការនាំចេញផលិតផលកសិកម្ម កើន ៤៣,៤% ធៀបនឹងត្រីមាសមុន ក្នុងនោះ ការនាំចេញឈើ កើន ១១០,០% ត្រី កើនឡើង ៥០% និង អង្ករ កើនឡើង ៨០,៥%។ ការនាំចេញកៅស៊ូ ធ្លាក់ចុះ ៣,៤% ហើយការនាំចេញផលិតផលកសិកម្មផ្សេងទៀត ធ្លាក់ចុះ ៣២,៤%។

នៅត្រីមាសទី៤ ដដែលនេះ ការនាំចូល កើន ១,៤% ធៀបត្រីមាសមុន និង ៥,០% ធៀបឆ្នាំមុន ដល់ ២៩៤៩,១លានដុល្លារ។ ការនាំចូលប្រេងម៉ាស៊ូត កើន ៧,៥% ដល់ ១៥០លានដុល្លារ រីឯការនាំចូលប្រេងសាំង ធ្លាក់ចុះ ៣២,៦% មកត្រឹម ៦៥,១ លានដុល្លារ ហើយការនាំចូលសម្ភារសំណង់ ធ្លាក់ចុះ ៨,៣% មកត្រឹម ៤២,១លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ឆ្នាំ២០១៥ ចំណូលរដ្ឋាភិបាលសរុប រួមចុះ ៧,២%ធៀបត្រីមាសមុនមកត្រឹម៣០៦៣,៨ប៊ីលានរៀលក្នុងនោះ ចំណូលចរន្ត ធ្លាក់ចុះ ៧,៥% មកត្រឹម ៣០២៨,៧ប៊ីលានរៀល។ ចំណូលពន្ធ រួមចំណែក ៨៦,៧% ក្នុងចំណូលរដ្ឋាភិបាលសរុប ដោយបានធ្លាក់ចុះ ១១,៦% មកត្រឹម ២៦៥៦,២ប៊ីលានរៀល។ ចំណូលមិនមែនពន្ធ កើន ៣៨,៨% ដល់ ៣៧២,៥ប៊ីលានរៀល។ នៅត្រីមាសដដែលនេះ ចំណាយសរុបកើន៦៩,៩%ធៀបត្រីមាសមុន ដល់ ៣៣៣៧,៥ប៊ីលានរៀល ដោយសារកំណើន ១១,១% (៦៤៩,៩ប៊ីលានរៀល) នៃចំណាយមូលធន និង ៩៤,៨% (២៦៨៧,៧ប៊ីលានរៀល) នៃចំណាយចរន្ត។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០១៥ អតិផរណា មានអត្រា ២,០%។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៤,៧% ប៉ុន្តែថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៨,៩%។ ប្រាក់រៀល ឡើងថ្លៃ ១,០% ទល់នឹងប្រាក់ដុល្លារ, ២,៧% ទល់នឹងប្រាក់បាតថៃ និង ២,២% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ មាស ធ្លាក់ថ្លៃ ៣,៨% ធៀបត្រីមាសមុន រីឯប្រេងម៉ាស៊ូត ធ្លាក់ថ្លៃ ១១,៧% ហើយសាំង ធ្លាក់ថ្លៃ ១១,៥%។

## ស្ថានភាពក្រីក្រ

ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់បន្លែ អ្នករើសអេតចាយ កម្មករសំណង់មានជំនាញ អ្នករត់ម៉ូតូឌុប និងអ្នកស៊ីឈ្នួលធ្វើស្រែ បានកើនឡើងធៀបនឹងខែកុម្ភៈ ឆ្នាំមុន រីឯប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ ៤ក្រុមពលករងាយរងគ្រោះផ្សេងទៀត ធ្លាក់ចុះ។

នៅខែកុម្ភៈ ៩៤% នៃអ្នកឆ្លើយសម្ភាសន៍ គឺជាប្រភពចំណូលចម្បងសម្រាប់គ្រួសារគាត់។ ជាមធ្យម ពួកគេធ្វើការ ៩,៥ម៉ោង/ថ្ងៃ ដោយមាន ៥៦% ប្រកបមុខរបរតែមួយគត់ និង ៤៤% ផ្សេងទៀត មានមុខរបរពីរ។

នៅខែកុម្ភៈ ២០១៦ ប្រាក់កម្រៃប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើន ២,០% ធៀបនឹងខែកុម្ភៈ ឆ្នាំមុន ដល់ ១៤.៩៣៧រៀល។ កម្រិតការអប់រំជាមធ្យមរបស់អ្នកឆ្លើយសម្ភាសន៍ទាំងអស់ គឺថ្នាក់បឋមសិក្សា។ ៦៤% នៃពួកគេ ទទួលបានការបណ្តុះបណ្តាលភ្ជាប់នឹងការងារតែម្តង ហើយមានតែ ១០% ប៉ុណ្ណោះ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលឯកជន។ កម្មករកាត់ដេរ ជាមធ្យម ធ្វើការ ៦ថ្ងៃ ឬ ៥៤ម៉ោង/សប្តាហ៍ ក្នុងនោះប្រហែល ៤៧% មានការងារថែមម៉ោងម្តងម្កាល និង ២៨% មានការងារថែមម៉ោងជាញឹកញាប់។ ចំណាយសរុបរបស់កម្មករកាត់ដេរ អស់ដល់ ៤៣% នៃប្រាក់ចំណូលរបស់គាត់ ហើយក្នុងចំណាយសរុបនេះ ចំណាយលើអាហារ មាន ៦៧% និងចំណាយលើការជួលផ្ទះ មាន ១៩%។ ពួកគេ ៧៧% មិនអាចសន្សំប្រាក់សម្រាប់ថ្ងៃអនាគតឡើយ ហើយប្រសិនបើរោងចក្រត្រូវបិទទ្វារ ពួកគេ ៥៥% នឹងស្វែងរកការងារផ្សេងទៀតធ្វើនៅរាជធានីភ្នំពេញ ហើយ ៤៥% ទៀតនឹងវិលត្រឡប់ទៅស្រុកកំណើតវិញ។

នៅខែកុម្ភៈដដែល ចំណូលរបស់អ្នកលក់បន្លែ កើន ៣៦% ធៀបនឹងខែកុម្ភៈ ឆ្នាំមុន ដល់ ២០.៤០៣រៀល/ថ្ងៃ។ ពួកគេភាគច្រើនរស់នៅក្នុងខេត្តកណ្តាល (៣០%) ឬស្វាយរៀង (២៨%) ហើយ ៨% រស់នៅរាជធានីភ្នំពេញ។ ពួកគេ ៩៥% ជាអ្នករកចំណូលចម្បងនៅក្នុងគ្រួសារ។ ពួកគេជួលផ្ទះស្នាក់នៅជាមួយមនុស្សបីនាក់ផ្សេងទៀតជាមធ្យម ហើយចំណាយអស់ ៣៨% នៃប្រាក់ចំណូលទៅលើអាហារ ការថែទាំសុខភាព និងការដឹកជញ្ជូន។

---
អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រី បុប្ផាវត្តី ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

ប្រាក់ចំណូលរបស់អ្នករើសអេតចាយ កើន ៥,៤% ធៀបនឹងឆ្នាំមុន ដល់ ១១.១៩៦រៀល/ថ្ងៃ។ ពួកគេមានដើមកំណើតមកពី ខេត្តព្រៃវែង (៤៩%) តាកែវ (១៥%) កំពង់ចាម កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ស្វាយរៀង និងរាជធានីភ្នំពេញ ហើយស្ទើរតែគ្រប់គ្នា ជាអ្នករកចំណូលចម្បងនៅក្នុងគ្រួសារ។ អ្នកឆ្លើយសម្ភាសន៍ ៨០% ផ្លាស់ទីមករស់នៅឯភ្នំពេញជាមួយគ្រួសារខ្លួន។ អ្នករើសអេតចាយ ត្រូវចំណាយអស់ជាមធ្យម ៣៤% នៃចំណូលសរុបរបស់ខ្លួន ពិសេសទៅលើអាហារ។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ២,៨% មកត្រឹម ១៦.២១៧រៀល។ ពួកគេមួយភាគធំ មកពីខេត្តស្វាយរៀង និងព្រៃវែង ហើយជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ពួកគេត្រូវចំណាយអស់ ៨៤% នៃការចាយវាយសរុបប្រចាំថ្ងៃ ទៅលើអាហារ។

ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង ធ្លាក់ចុះ ១១,១% ធៀបនឹងខែកុម្ភៈ ឆ្នាំមុន មកត្រឹម ១៤.៩៣៧រៀល។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ជាអ្នករកចំណូលចម្បងនៅក្នុងគ្រួសារ។ ពួកគេ ៧៨% មកភ្នំពេញតែម្នាក់ឯង ហើយស្នាក់នៅរួមគ្នាជាមួយមនុស្ស ៥នាក់ទៀតជាមធ្យម។ ពួកគេចំណាយភាគច្រើនទៅលើ អាហារ គឺរហូតដល់ ៣៨% នៃចំណូលសរុប។ ពួកគេមួយភាគធំ ជួយទ្រទ្រង់គ្រួសារ និងមិនអាចសន្សំប្រាក់សម្រាប់ថ្ងៃអនាគតឡើយ។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់តុ ធ្លាក់ចុះ ៦,៩% ធៀបមួយឆ្នាំមុន មកត្រឹម ៧៨៨៦រៀល។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ស្នាក់នៅតាមភោជនីយដ្ឋានដែលខ្លួនធ្វើការ។ ពួកគេ ចំណាយ ២៧% នៃចំណូលប្រចាំថ្ងៃទៅលើអាហារ និង ៣,៧% ទៅលើការថែទាំសុខភាព។ ពួកគេមិនអាចសន្សំប្រាក់ទេ ព្រោះប្រាក់នៅសល់ត្រូវផ្ញើទៅឲ្យក្រុមគ្រួសារ។

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១០-១៥*

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 530.7 | 725 | 531.6 | 930.5 | 28.9 | 27.6 | 0.0 | 0.0 | 25.8 | 38.08 | 79.1 | 26.8 |
| ឧស្សាហកម្ម | 403.7 | 2860.1 | 829.3 | 3257 | 179.0 | 239.3 | 434.3 | 149.9 | 342.8 | 130.91 | 130.6 | 410.4 |
| *កាត់ដេរ* | 122.8 | 393.9 | 497 | 324.1 | 109.3 | 172.4 | 81.6 | 30.3 | 63.9 | 42.4 | 63.7 | 55.2 |
| សេវាកម្ម | 1337.3 | 3425.4 | 916.6 | 140.7 | 219.1 | 114.4 | 191.5 | 0.0 | 2504.6 | 85.64 | 69.7 | 74.5 |
| *សណ្ឋាគារ និងទេសចរណ៍* | 1105.1 | 2850.9 | 691.5 | 106 | 163.3 | 15.4 | 268.1 | 0.0 | 60.6 | 0.0 | 0 | 38.0 |
| សរុប | 2271.7 | 7010.42 | 2278.0 | 4328 | 426.9 | 302.2 | 625.8 | 149.9 | 2873.2 | 254.6 | 279.4 | 511.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -75.8 | -29.2 | 64.1 | -76.0 | 1816.8 | -91.1 | 9.7 | 83.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -61.3 | 209 | -67.5 | 90.1 | 95.1 | -81.8 | 142.7 | -91.5 | 573.0 | -33.2 | -55.3 | 241.4 |

*Including expansion project approvals. Source: Cambodian Investment Board

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | - |
| ផ្សេងៗ | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | - |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១០-១៥

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1304.3 | 1480.4 | 1722.1 | 2017.7 | 699.0 | 438.2 | 497.5 | 638.8 | 725.1 | 497.4 | 563.8 | 681.3 |
| តាមផ្លូវគោក និងទឹក | 1094.6 | 1401.4 | 1862.2 | 2192.5 | 569.0 | 495.2 | 501.2 | 663.9 | 647.6 | 496.7 | 481.1 | 747.0 |
| សរុប | 2398.9 | 2881.8 | 3584.3 | 4210.2 | 1268.0 | 933.4 | 998.7 | 1302.7 | 1372.6 | 994.2 | 1044.9 | 1428.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | | 10.0 | -26.4 | 7.0 | 30.4 | 5.4 | -27.6 | 5.1 | 36.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 13.6 | 20.1 | 24.4 | 17.5 | 8.0 | 1.4 | 3.5 | 13.0 | 8.3 | 6.5 | 4.6 | 9.6 |

Source: Ministry of Tourism

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០១០-១៥ *

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3630.2 | 4929.5 | 6106.4 | 6982.4 | 1976.5 | 1859.8 | 2132.5 | 2137.1 | 2170.1 | 2182 | 2595 | 2309.3 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 3223.4 | 4259.6 | 5015.4 | 5386.1 | 1464.0 | 1379.2 | 1624.7 | 1492.6 | 1548.8 | 1601.7 | 1995.3 | 1681.2 |
| - *សហរដ្ឋអាមេរិក* | 1853.9 | 2055.3 | 2143.3 | 2075.2 | 531.1 | 452.5 | 511.2 | 468.8 | 491.08 | 494.3 | 585.3 | 438.8 |
| - *សហភាពអឺរ៉ុប* | 809.5 | 1322.2 | 1716.9 | 1969.6 | 532.7 | 558.5 | 673.8 | 638.7 | 617.3 | 685.9 | 844.1 | 756.6 |
| - *អាស៊ាន* | 9.9 | 17.6 | 39.4 | 60.2 | 21.9 | 19.3 | 20.5 | 21.7 | 24.8 | 24.6 | 26.4 | 27.5 |
| - *ជប៉ុន* | 86.5 | 147.0 | 188.6 | 278.7 | 101.4 | 74.9 | 117.6 | 89.2 | 121.4 | 93.6 | 170.8 | 138.4 |
| - *ប្រទេសផ្សេងៗ* | 463.6 | 717.5 | 927.2 | 1002.9 | 277.0 | 273.9 | 301.6 | 274.2 | 294.2 | 303.4 | 368.8 | 319.9 |
| កសិកម្ម | 164.9 | 362.1 | 376.7 | 554.5 | 167.0 | 157.3 | 133.7 | 166.4 | 150.3 | 127.3 | 111.4 | 159.7 |
| - *កៅស៊ូ* | 89.1 | 197.6 | 176.6 | 175.2 | 31.7 | 40.0 | 34.8 | 47.5 | 41.7 | 40.9 | 42.1 | 40.7 |
| - *ឈើ* | 34.1 | 48.8 | 36.8 | 73.6 | 55.9 | 48.4 | 19.6 | 8.2 | 13.9 | 9.8 | 7.3 | 15.3 |
| - *ត្រី* | 2.8 | 3.1 | 2.0 | 1.2 | 0.3 | 0.2 | 0.1 | 0.2 | 0.2 | 0.2 | 0.08 | 0.1 |
| - *អង្ករ* | 34.7 | 106.6 | 146.4 | 262.3 | 57.9 | 52.8 | 55.8 | 82.0 | 89.5 | 72.4 | 54.7 | 98.8 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 4.1 | 6.0 | 14.9 | 42.4 | 21.2 | 16.0 | 23.5 | 28.5 | 5.2 | 4.0 | 7.2 | 4.9 |
| ផ្សេងៗ | 242.0 | 307.9 | 714.4 | 1088.2 | 345.5 | 323.3 | 373.0 | 478.2 | 471.0 | 452.9 | 488.0 | 468.4 |
| ការនាំចូលសរុប ក្នុងនេះ៖ | 5190.6 | 6375.9 | 8593.3 | 8639.4 | 2238.2 | 2454.4 | 2794.8 | 2807.9 | 2717.3 | 2920.3 | 2907.9 | 2949.07 |
| សាំង | 108.6 | 294.4 | 308.0 | 306.4 | 77.4 | 83.2 | 80.2 | 93.9 | 34.5 | 92.2 | 96.5 | 65.1 |
| ម៉ាស៊ូត | 203.8 | 447 | 559.5 | 569.1 | 148.5 | 142.5 | 163.4 | 147.9 | 45.1 | 152.7 | 139.6 | 150.0 |
| សម្ភារសំណង់ | 57.6 | 48.1 | 66.1 | 80.8 | 27.8 | 29.2 | 29.0 | 31.6 | 12.4 | 42.0 | 45.9 | 42.1 |
| ផ្សេងៗ | 4820.6 | 5586.4 | 7659.1 | 7682.6 | 1984.5 | 2199.5 | 2522.2 | 2534.0 | 835.2 | 2633.0 | 2626.0 | 2691.9 |
| ជញ្ជីងពាណិជ្ជកម្ម | -1560.5 | -1446.4 | -1341.6 | -1610.9 | -261.7 | -589.5 | -662.3 | -670.8 | -547.2 | -738.3 | -312.9 | -639.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | 9.8 | -5.8 | 17.8 | -8.1 | 3.8 | 3.4 | 24.6 | -15.7 |
| ការនាំចេញសរុប | - | - | - | - | 8.9 | -5.9 | 14.7 | 0.2 | 1.5 | 0.5 | 18.9 | -11.0 |
| ការនាំចូលសរុប | - | - | - | - | 5.1 | 9.4 | 14.1 | 0.5 | -3.2 | 7.5 | -0.4 | 1.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 25.7 | 32.1 | 17.7 | 7.4 | 19.5 | 9.6 | 3.6 | 11.9 | 5.8 | 16.1 | 22.8 | 12.6 |
| ការនាំចេញសរុប | 25.1 | 35.8 | 23.9 | 14.3 | 25.3 | 14.8 | 8.3 | 17.7 | 9.8 | 17.3 | 21.7 | 8.1 |
| ការនាំចូលសរុប | 19.8 | 22.8 | 16.8 | 0.5 | 2.1 | 10.8 | 35.7 | 31.8 | 21.4 | 19.2 | 4.0 | 5.0 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៩-១៥ (ប៊ីលានរៀល)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 4885.2 | 5989.0 | 6251.4 | 7691.9 | 8255.2 | 2220.5 | 2793.7 | 2580.6 | 2948.6 | 2647.8 | 3301.6 | 3063.8 |
| ចំណូលចរន្ត | 4855.9 | 5859.1 | 6179.3 | 7443.8 | 8233.2 | 2219.2 | 2765.2 | 2571.4 | 2803.6 | 2638.0 | 3274.5 | 3028.7 |
| ចំណូលពន្ធ | 4268.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 1988.7 | 2383.1 | 2264.6 | 2358.8 | 2430.6 | 3006.1 | 2656.2 |
| ពន្ធក្នុងស្រុក | 3088.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 1593.6 | 1943.2 | 1798.0 | 1891.6 | 2012.6 | 2481.6 | 2153.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1064.7 | 1159.4 | 1205.9 | 1331.7 | 1470.0 | 449.0 | 439.9 | 466.5 | 467.2 | 418.0 | 524.5 | 502.3 |
| ចំណូលមិនមែនពន្ធ | 702.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 176.6 | 382.1 | 306.9 | 444.8 | 207.4 | 268.5 | 372.5 |
| ចំណូលលើទ្រព្យសម្បត្តិ | 64.6 | 291.1 | 63.8 | 143.0 | 84.0 | 11.1 | 40.8 | 21.2 | 15.4 | 3.0 | 16.7 | 35.9 |
| លក់ទំនិញ និងសេវា | 408.0 | 460.1 | 588.7 | 667.4 | 750.3 | 160.3 | 197.5 | 212.9 | 300.5 | 189.6 | 219.2 | 304.6 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 228.2 | 408.9 | 249.3 | 298.8 | 200.8 | 5.2 | 143.7 | 72.7 | 128.9 | 14.8 | 32.6 | 31.8 |
| ចំណូលជាមូលធន | 29.3 | 129.9 | 72.1 | 247.9 | 73.4 | 1.3 | 28.5 | 9.2 | 145.0 | 9.8 | 27.1 | 35.0 |
| ចំណាយសរុប | 7383.5 | 8784.6 | 9032.4 | 9660.9 | 12535.7 | 2618.8 | 2867.2 | 3349.0 | 4471.4 | 2093.3 | 1964.8 | 3337.5 |
| ចំណាយជាមូលធន | 2694.9 | 2853.2 | 3546.9 | 3628.3 | 5567.5 | 1187.1 | 1395.9 | 1421.7 | 1586.0 | 654.4 | 584.7 | 649.9 |
| ចំណាយចរន្ត | 4440.0 | 4773.1 | 5341.2 | 6188.4 | 6968.3 | 1431.7 | 1471.4 | 1927.3 | 2885.4 | 1438.9 | 1380.1 | 2687.7 |
| បៀវត្សរ៍ | 2012.0 | 2048.8 | 2170.6 | 2486.6 | 2997.3 | 860.0 | 931.0 | 918.4 | 1046.1 | 945.3 | 959.1 | 1281.2 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 871.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 213.1 | 259.6 | 434.8 | 719.5 | 194.3 | 207.1 | 544.0 |
| ចំណាយចរន្តផ្សេងទៀត | 1556.6 | 1624.8 | 1651.8 | 2115.1 | 2408.0 | 358.6 | 280.8 | 574.1 | 1119.9 | 299.3 | 213.9 | 862.4 |
| សមតុល្យជាទូទៅ | -2498.3 | -2795.7 | -1271.4 | -1969.0 | -4280.6 | -398.4 | -73.5 | -768.5 | -522.8 | 554.5 | 1336.8 | -273.8 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1746.1 | 1845.2 | -2781.0 | 2457.8 | 4326.2 | 977.9 | 1123.9 | 1,012.5 | 857.9 | 368.9 | 330.1 | 297.6 |
| ហិរញ្ញប្បទានក្នុងស្រុក | 474.9 | 938.6 | 2379.2 | -332.9 | 824.4 | -915.0 | -172.9 | -279.3 | -61.4 | -2464.8 | -793.3 | -259.1 |

Source: MEF website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១០-១៥

| | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| (ឆ្នាំគោល ២០០៦) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.1 | 5.4 | 2.3 | 3.9 | 4.6 | 4.8 | 4.0 | 2.1 | 1.0 | 1.0 | 0.8 | 2.0 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 4.4 | 6.5 | 2.5 | 4.9 | 5.7 | 5.3 | 5.1 | 3.4 | 4.2 | 3.9 | 3.3 | 4.7 |
| - ដឹកជញ្ជូន | 7.0 | 6.9 | 3.3 | -1.0 | -1.1 | 0.5 | -0.2 | -3.3 | -10.9 | -7.9 | -9.1 | -8.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4187.1 | 4063.6 | 4039.2 | 4036.2 | 3993.8 | 4026.9 | 4059.5 | 4064.7 | 4042.2 | 4056.7 | 4091.8 | 4050.9 |
| រៀលក្នុង ១ បាតថៃ | 133.1 | 133.2 | 130.0 | 124.9 | 123.0 | 124.8 | 127.1 | 124.6 | 124.4 | 122.6 | 116.8 | 113.6 |
| រៀលក្នុង ១០០ ដុងវៀតណាម | 21.7 | 19.7 | 19.4 | 19.1 | 19.1 | 19.2 | 19.2 | 19.1 | 19.0 | 18.8 | 18.6 | 18.2 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 147.5 | 184.5 | 200.9 | 152.3 | 156.6 | 155.9 | 155.5 | 141.1 | 150.9 | 144.4 | 136.0 | 130.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3859.3 | 4761.2 | 4941.2 | 4852.1 | 4971.2 | 5006.7 | 5047.6 | 4382.8 | 3823.4 | 4032.0 | 3840.2 | 3389.4 |
| ថ្លៃសាំង (រៀល/លីត្រ) | 4368.1 | 5044.5 | 5312.7 | 5083.3 | 5171.5 | 5200.0 | 5348.6 | 4613.0 | 3986.2 | 4189.0 | 4048.9 | 3582.5 |

Sources: NIS, NBC and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៩-១៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 21,260.1 | 23,344.4 | 26,235.8 | 26,817.8 | 26,699.7 | 26,823 | 27,975.3 | 26,359.2 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1573.0 | 2778.9 | 5760.8 | 10,437.4 | 11,508.3 | 11,817.4 | 12,024.4 | 13,950.5 | 15,859.8 | 16,863.2 | 18,178.3 | 20,600.9 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -3349.3 | -3747.3 | -4113.0 | -4359.1 | -5064 | -5666.1 | -5933.1 |
| ឥណទានដល់វិស័យឯកជន | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 27,608.8 | 28,584.5 | 30,621.3 | 33,226.4 | 36,244.6 | 37,759.4 | 40995 | 43,807.1 |
| រូបិយវត្ថុទូទៅ M2 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 32,768.4 | 35,161.8 | 38,259.9 | 40,768.3 | 42,559.5 | 43,685.2 | 46,153.7 | 46,960.1 |
| រូបិយវត្ថុ M1 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 5376.2 | 5231.3 | 5583.1 | 6308.4 | 6628.0 | 6293.1 | 6287.5 |
| រូបិយវត្ថុផ្សេងៗ | 13,108.0 | 16,255.9 | 19,698.5 | 24,546.2 | 27,890.2 | 29,785.7 | 33,028.5 | 35,185.2 | 36,251.1 | 37,058.2 | 39,860.6 | 40,672.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 15.4 | 20.8 | 38.9 | 29.9 | 24.2 | 20.6 | 15.2 |
| រូបិយវត្ថុ M1 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 19.5 | 14.1 | 18.3 | 29.3 | 23.3 | 20.3 | 12.6 |
| រូបិយវត្ថុផ្សេងៗ | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 14.6 | 22.0 | 42.8 | 30.0 | 24.4 | 20.7 | 15.6 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2012 | 2013 | 2014 | | | | 2015 | | 2016 | 2014 | 2015** | 2016 |
| | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | | | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 10,303 | 10,438 | 10,764 | 9867 | 11,634 | 12,950 | 12,467 | 11,799 | 11,919 | 3.2 | 15.1 | -8.0 |
| អ្នកលីសែង | 12,143 | 13,247 | 12,590 | 13,399 | 16,189 | 16,798 | 15,782 | 14,314 | 14,937 | 2.5 | 15.1 | -11.1 |
| អ្នកលក់បន្លែតូចតាច | 10,771 | 11,366 | 13,581 | 15,373 | 17,735 | 15,007 | 18,171 | 14,423 | 20,403 | 29.8 | 7.6 | 36.0 |
| អ្នករើសអេតចាយ | 8680 | 9819 | 9214 | 8337 | 9548 | 10,627 | 14,169 | 12,237 | 11,196 | -6.6 | 34.6 | 5.4 |
| អ្នកបម្រើភោជនីយដ្ឋាន* | 6111 | 6697 | 6696 | 7565 | 9435 | 8466 | 8742 | 8100 | 7,886 | 12.8 | 6.9 | -6.9 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 6151 | 6599 | 5836 | 8494 | 6781 | 8303 | 8063 | 9869 | 8,512 | 16.3 | 0.1 | 2.5 |
| កម្មកររោងចក្រកាត់ដេរ | 8932 | 10,161 | 11,412 | 11,607 | 12,092 | 14,644 | 14,803 | 15,515 | 14,937 | -0.5 | 8 | 2.0 |
| អ្នករត់ម៉ូតូឌុប | 12,930 | 13,450 | 13,401 | 12,656 | 14,259 | 14,549 | 14,692 | 14,124 | 15,577 | 16.3 | 8.3 | 7.1 |
| កម្មករសំណង់គ្មានជំនាញ | 11,078 | 13,184 | 15,343 | 15,401 | 15,437 | 16,678 | 15,453 | 13,916 | 16,217 | 13.9 | 16.4 | -2.8 |
| កម្មករសំណង់មានជំនាញ | 13,743 | 15,442 | 15,792 | 20,420 | 18,303 | 17,050 | 19,918 | 18,905 | 18,915 | 10.0 | 34.1 | 10.9 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. **Data in November 2015 is not available.

Source: CDRI

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗ...**

អ្នកវិទ្យាសាស្ត្រក្នុងស្រុកផ្នែកសង្គម ឲ្យធ្វើការស្រាវជ្រាវក្នុងបំណង ផ្តល់ព័ត៌មានដល់អ្នកធ្វើការសម្រេចចិត្តផ្នែកគោលនយោបាយ។

**ថ្ងៃទី៧ មីនា៖** CDRI ដោយរួមសហការជាដៃគូជាមួយធនាគារ ANZ Royal និងមានកិច្ចសហការឧបត្ថម្ភពី ក្រុមហ៊ុនធានារ៉ាប់រង Manulife បានរៀបចំសន្និសីទចក្ខុវិស័យលើកទី១០ ស្តីពី "ជំរុញការងារទៅមុខ៖ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស និងនៅក្នុងតំបន់ និងឡូជីស្ទីកសម្រាប់ការតភ្ជាប់ កំណើន និងអភិវឌ្ឍន៍" នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភោគីត្រា។ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ អញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ។ សន្និសីទនេះ មានការចូលរួមពីសំណាក់វាគ្មិនជាភ្ញៀវកិត្តិយស មកពី ស្ថាប័នខ្ពស់ៗរបស់រដ្ឋ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកសិក្សាស្រាវជ្រាវ ដែលមានជំនាញឯកទេសផ្នែកឡូជីស្ទីក និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបំផុសការពិភាក្សាស្តីពី បញ្ហាប្រឈម - តើត្រូវធ្វើអ្វីខ្លះ? តួអង្គសំខាន់ៗ និងបញ្ហាចោទ (ការធ្វើផែនការ ការអនុវត្ត និងក្របខ័ណ្ឌបទបញ្ញត្តិ) និងធ្វើការរួមគ្នាដើម្បីសម្រេចជោគជ័យ និងកត្តាចម្បងៗនាំឲ្យមានជោគជ័យ។

**ថ្ងៃទី៨ មីនា៖** ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាភិបាល CDRI ដែលមានឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ជាប្រធាននោះ សមាជិកក្រុមប្រឹក្សាភិបាលក្នុងស្រុក និងមកពីបរទេស បានធ្វើការពិភាក្សាពី ស្ថានភាពបច្ចុប្បន្នរបស់ CDRI បញ្ហាប្រឈម ឱកាស និងមធ្យោបាយដើម្បីលូតលាស់ទៅមុខ។

**ថ្ងៃទី១៦ មីនា៖** ស្ថានទូតសិង្ហបុរីប្រចាំនៅកម្ពុជា បានអញ្ជើញលោកនាយកប្រតិបត្តិផ្តល់នូវបទឧទ្ទេសនាមមួយស្តីពី "ការអភិវឌ្ឍ និងសេដ្ឋកិច្ចកម្ពុជា" ជូនដល់មន្ត្រី ២០រូប មកពីក្រសួងការបរទេសប្រទេសសិង្ហបុរី។

**ថ្ងៃទី១៨ មីនា៖** លោកនាយកប្រតិបត្តិ បានចូលរួមក្នុងវេទិកាសន្ទនាមួយស្តីពី "ការប្រែប្រួលអាកាសធាតុ និងផែនការបន្សាំនៅសហគមន៍" ដែលរៀបចំឡើងដោយ CDRI នៅខេត្តសៀមរាប និងទទួលបានការអញ្ជើញចូលរួមពី ឯកឧត្តម គឹម ឆៃហៀង អភិបាលខេត្តរង នៃខេត្តសៀមរាប។ កិច្ចប្រជុំនេះ ជាឱកាសល្អមួយទៀតសម្រាប់លោកនាយកប្រតិបត្តិ ធ្វើទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធផ្សេងៗ និងតំណាងមកពី ក្រសួងធនធានទឹកនិងឧតុនិយម អាជ្ញាធរអប្សរា ក្រសួងបរិស្ថាន និង ដៃគូអភិវឌ្ឍន៍នានា ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជាដើម។

**ថ្ងៃទី២១ មីនា៖** ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាល CDRI និង លោកនាយកប្រតិបត្តិ បានទទួលការសម្ភាសន៍ពីសំណាក់សារព័ត៌មាន Blue Media ស្តីពីលទ្ធផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៦។

**ថ្ងៃទី២២ មីនា៖** នៅក្នុងកិច្ចជួបសំណេះសំណាលជាមួយលោកស្រី Ruth Stewart អនុប្រធានផ្នែកបេសកកម្មប្រចាំកម្ពុជា នៃស្ថានទូតអូស្ត្រាលី ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងអ្នកស្រាវជ្រាវនៃ CDRI បានធ្វើការផ្លាស់ប្តូរមតិយោបល់គ្នាស្តីពី វិធីសាស្ត្រចូលពាក់ព័ន្ធដោយមានផលប្រយោជន៍ទៅវិញទៅមក ក្នុងពេលអនុវត្តកម្មវិធីស្រាវជ្រាវផ្នែកអប់រំដែលទទួលបានមូលនិធិពី DFAT។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

ក្រុមស្រាវជ្រាវ កំពុងអនុវត្តគម្រោងសិក្សាចំនួន ៧។ របាយការណ៍សម្រេចលើកទី២ សម្រាប់ការសិក្សាស្តីពី សកម្មភាពបង្កើតប្រាក់ចំណូលមិនមែនកសិកម្មនៅកម្ពុជា ដែលទទួលមូលនិធិពី អង្គការកសិកម្ម និងស្បៀងអាហារ (FAO) បានចងក្រងរួចរាល់ហើយ ដោយផ្អែកលើមតិយោបល់ និងព័ត៌មានត្រឡប់ពីជំនាញការ FAO។ ការវិភាគទិន្នន័យសម្រាប់គម្រោងផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង បានចប់សព្វគ្រប់ ហើយការពិនិត្យឯកសារពាក់ព័ន្ធ និងការចងក្រងរបាយការណ៍ កំពុងដំណើរការទៅមុខ។ សម្រាប់គម្រោងស្រាវជ្រាវពី ផលប៉ះពាល់នៃចំណាយសាធារណៈផ្នែកអប់រំទៅលើមូលធនមនុស្ស ភាពក្រីក្រ និងវិសមភាព៖ វិធីសាស្ត្រ CGE សម្រាប់កម្ពុជា ដែលទទួលបានជំនួយទ្រទ្រង់ពី អង្គការភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច (PEP) នោះ ម៉ូដែលតុល្យភាពទូទៅអាចគណនាបាន (computable general equilibrium) បានកសាងរួចរាល់ហើយ ក្នុងអំឡុងពេលទស្សនកិច្ចសិក្សានៅទីក្រុងប៉ារីស របស់ប្រធានក្រុមស្រាវជ្រាវ ហើយរបាយការណ៍សម្រេច ក៏បានដាក់ជូនទៅម្ចាស់ជំនួយដែរ។ របាយការណ៍បង្ហាញគំនិតផ្តួចផ្តើមសម្រាប់គម្រោងកសិកម្មមានការស្រោចស្រពនៅកម្ពុជា ក្រោមជំនួយទ្រទ្រង់ពី មហាវិទ្យាល័យជាតិអូស្ត្រាលីនោះ បានដាក់ជូនពិនិត្យរួចរាល់ ហើយក្រុមស្រាវជ្រាវកំពុងរៀបចំសិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធបឋម ដែលគ្រោងធ្វើឡើងនៅខែឧសភា។ ឧបករណ៍អង្កេតសម្រាប់គម្រោង ការសាកល្បងគំរូបែបថ្មីនៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម នៅក្នុងគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE) របស់កម្ពុជា ដែលផ្តល់មូលនិធិដោយ វិទ្យាស្ថានស្រាវជ្រាវពីគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) បានកសាងរួចរាល់ ហើយការបណ្តុះបណ្តាល និងការចុះសិក្សាដល់កន្លែង គ្រោងចាប់ផ្តើមនៅខែឧសភា។

កម្មវិធី គំនិតផ្តួចផ្តើមផ្នែកគោលនយោបាយសារធារណៈសម្រាប់តំបន់មេគង្គក្រោម (LMPPI) បានទទួលយកសំណើអនុវត្តគម្រោងមួយ ដែលក្រុមស្រាវជ្រាវដាក់ស្នើឡើងកាលពីត្រីមាសមុន ហើយកិច្ចសន្យាអនុវត្តគម្រោង នឹងរៀបចំរួចរាល់នៅខែមេសា។ គម្រោងស្តីពី ការវាយតម្លៃលើផលប៉ះពាល់ចុងក្រោយនៃកម្មវិធី HARVEST ដែលទទួលជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) នោះ កំពុងដំណើរការទៅមុខ។ តាមសំណើរបស់ សាកលវិទ្យាល័យរដ្ឋមីឈីហ្គិន (MSU) ការវាយតម្លៃលើផលប៉ះពាល់នោះ ត្រូវបានលើកទៅអនុវត្តនៅខែសីហា-កញ្ញា ២០១៦។

## ផ្នែកសេដ្ឋកិច្ច

ការសិក្សាស្ដីពី លទ្ធផលលើយុវជន និងកត្តាកំណត់ភាពងាយរងគ្រោះ និងលទ្ធផលអវិជ្ជមានសម្រាប់យុវជន និង ការស្វែងយល់ពី ជម្រើសចិញ្ចឹមជីវិតរបស់សិស្សបោះបង់ការសិក្សាថ្នាក់មធ្យមសិក្សា ដែលទទួលបានជំនួយទ្រទ្រង់ពី អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានបញ្ចប់ដោយជោគជ័យ។ ក្រុមស្រាវជ្រាវ នឹងចែករំលែកលទ្ធផលស្រាវជ្រាវជាមួយ ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងកិច្ចប្រជុំ ធ្វើបទបង្ហាញត្រួសៗមួយ គ្រោងរៀបចំឡើងក្នុងខែឧសភា។ គម្រោងស្ដីពី ការកំណត់ច្រកផ្ញើប្រាក់ និងការគ្រប់គ្រងប្រាក់ផ្ញើមកផ្ទះនៅកម្ពុជា ហើយនិងសៀវភៅណែនាំពីសហគមន៍សេដ្ឋកិច្ចអាស៊ានសម្រាប់សហគ្រាសអាជីវកម្មនៅកម្ពុជា ក៏ជិតបានរួចរាល់ដែរ។

របាយការណ៍កែសម្រួលឡើងវិញស្ដីពី ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈរបស់ប្រទេសជាដៃគូ ចំណាកស្រុក និងការអភិវឌ្ឍ៖ ករណីសិក្សា និងមតិមួយចំនួនផ្នែកគោលនយោបាយដែលជាការសិក្សាទទួលបានជំនួយទ្រទ្រង់ពី OECD នោះ បានបញ្ជូនទៅឲ្យម្ចាស់ជំនួយដើម្បីសុំយោបល់ត្រឡប់ពី អ្នកមានជំនាញពាក់ព័ន្ធ។ ក្រុមស្រាវជ្រាវ ត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលចុងក្រោយក្នុងខែមិថុនា។ការចងក្រងរបាយការណ៍សម្រាប់សមាសភាគនៅសល់ចុងក្រោយ ស្ដីពីប្រសិទ្ធភាពស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៃគម្រោងស្រាវជ្រាវរយៈពេល ៥ឆ្នាំ ស្ដីពី កំណើនសម្រាប់គ្រប់គ្នា ដែលទទួលបានជំនួយទ្រទ្រង់ពី Sida កំពុងដំណើរការទៅមុខ។ របាយការណ៍បណ្ដោះអាសន្នស្ដីពី ការពិនិត្យឡើងវិញលើការងារមិនទាន់ចប់៖ កត្តាកំណត់នៃលទ្ធភាពទទួលបានឥណទាន និងផលប៉ះពាល់លើផលិតកម្មកសិកម្ម និងការប្រើប្រាស់ដីនៅជនបទកម្ពុជា បានបញ្ជូនទៅម្ចាស់ជំនួយហើយ ដើម្បីសុំយោបល់ត្រឡប់។ គម្រោងស្ដីពី ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការវិវត្តក្នុងទីផ្សារពលកម្ម៖ ការពិសោធន៍ដោយចៃដន្យ ក្នុងចំណោមជនកម្ពុជាទើបពេញវ័យក៏កំពុងជឿនលឿនទៅមុខដែរ។ការស្រាវជ្រាវចំពេលល្អនេះ ទទួលបានមូលនិធិពីកម្មវិធី បណ្ដាញស្រាវជ្រាវមហាអនុតំបន់មេគង្គ (GMS-Net) ដែល មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC) ផ្ដល់ជំនួយទ្រទ្រង់ឲ្យ។ ក្រុមស្រាវជ្រាវកំពុងជ្រើសរើសអ្នកចូលរួមក្នុងគម្រោងនេះ ដើម្បីទៅទទួលការបណ្ដុះបណ្ដាលជំនាញ ដែលផ្ដល់ឲ្យដោយ អង្គការដើម្បីភាពញញឹមនៃកុមារ (PSE)។

## ផ្នែកអប់រំ

នៅខែមករា អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកអប់រំ បានចូលរួមជាតំណាងវិទ្យាស្ថាន CDRI នៅក្នុងសន្និសីទ Biennial លើកទី១០ នៃសមាគម Comparative Education Society of Asia នៅទីក្រុងម៉ានីល។ កម្ពុជា ដែលមានអ្នកតំណាងមកពី CDRI និងដៃគូក្នុងស្រុកជាច្រើនទៀត បានទទួលជោគជ័យក្នុងការដាក់សំណើទទួលរៀបចំសន្និសីទ Biennial ថ្នាក់តំបន់ នៅខេត្តសៀមរាប នៅខែឧសភា ២០១៨ ខាងមុខ។ CDRI កំពុងធ្វើការជាមួយសាកលវិទ្យាល័យក្នុងស្រុកមួយ និងក្រសួងអប់រំ ក្នុងការរៀបចំសន្និសីទផ្នែកអប់រំដ៏ល្បីល្បាញនេះ។

រដ្ឋាភិបាលអូស្ត្រាលី បានអញ្ជើញប្រធានផ្នែកអប់រំនៃ CDRI ដើម្បីតំណាងឲ្យវិទ្យាស្ថាន នៅក្នុងកម្មវិធីទស្សនកិច្ចពិសេសរបស់ពួកគេ។ ជាលទ្ធផល CDRI បានបង្កើតភាពជាដៃគូជាមួយសមភាគីអូស្ត្រាលីជាច្រើន មានជាអាទិ៍ មជ្ឈមណ្ឌលម៉ែលប៊ិនសម្រាប់ការសិក្សាពីឧត្តមសិក្សា, វិទ្យាស្ថាន LH Martine សម្រាប់ការដឹកនាំ និងគ្រប់គ្រងឧត្តមសិក្សា និង ក្រសួងអប់រំនិងបណ្ដុះបណ្ដាលនៃប្រទេសអូស្ត្រាលី។

សំណើស្រាវជ្រាវ និងកសាងសមត្ថភាពសំខាន់ៗពីរ បានបញ្ជូនទៅម្ចាស់ជំនួយក្នុងខែកុម្ភៈ និង មីនា។ CDRI បានធ្វើការជាមួយសាកលវិទ្យាល័យម៉ាឡេស៊ី និងដៃគូក្នុងផ្នែកសិក្សាស្រាវជ្រាវនៅអាស៊ី និងអឺរ៉ុប ជាង ១០ស្ថាប័នទៀត ក្នុងការដាក់សំណើស្រាវជ្រាវមួយស្ដីពី "ការជួយសម្រួលដល់សហប្រតិបត្តិការ និងការលើកស្ទួយអាស៊ាន" បន្ទាប់ពី កម្មវិធី Erasmus+ បានប្រកាសឲ្យដាក់សំណើស្រាវជ្រាវលើប្រធានបទ "ការកសាងសមត្ថភាពក្នុងផ្នែកឧត្តមសិក្សា"។ សំណើស្រាវជ្រាវទី២ ស្ដីពី "ភាពជាអ្នកដឹកនាំក្នុងការអប់រំពីទេសចរណ៍ប្រកបដោយចីរភាព ដើម្បីកំណើនសេដ្ឋកិច្ច និងការផ្ដល់សិទ្ធិអំណាចឲ្យស្ត្រី" បានបញ្ជូនទៅ ក្រសួងការបរទេស និងពាណិជ្ជកម្ម នៃប្រទេសអូស្ត្រាលី រួចហើយ។ គម្រោងនេះ ជាកិច្ចសហការរវាង CDRI, សាកលវិទ្យាល័យ Griffith, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, នាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ និងក្រសួងទេសចរណ៍។

## ផ្នែកបរិស្ថាន

គម្រោងស្រាវជ្រាវរយៈពេល ៣ឆ្នាំ ទទួលបានមូលនិធិពី IDRC ស្ដីពី ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា បានចប់សព្វគ្រប់នៅខែមីនា ដោយមានការបោះពុម្ពផ្សាយជាសៀវភៅមួយមានចំណងជើងថា "ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖ អភិបាលកិច្ច និងដំណោះស្រាយល្អៗសម្រាប់ប្រជាជនមូលដ្ឋាន និងស្ថាប័នថ្នាក់ក្រោមជាតិ"។ ក្នុងខែមីនា នេះ មានការរៀបចំព្រឹត្តិការណ៍សំខាន់ៗ ៤។ ទី១ សិក្ខាសាលាបណ្ដុះបណ្ដាលគ្រូបង្គោល រៀបចំឡើងនៅខេត្តសៀមរាប និងមានការចូលរួមពី ថ្នាក់ដឹកនាំសហគមន៍កសិករប្រើប្រាស់ទឹក ក្រុមប្រឹក្សាឃុំ អាជ្ញាធរខេត្ត និងស្រុកមកពីខេត្តគោលដៅចំនួន ៣ គឺខេត្តកំពង់ធំ កំពង់ឆ្នាំង និងពោធិ៍សាត់។ កិច្ចប្រជុំពិគ្រោះយោបល់មួយ បានរៀបចំឡើងនៅថ្ងៃបន្ទាប់ពីសិក្ខាសាលា ដោយមានការចូលរួមពីអ្នកចូលរួមក្នុងសិក្ខាសាលា និងតំណាងមកពីដៃគូអភិវឌ្ឍន៍ ស្ថាប័នរដ្ឋាភិបាល និង NGOs។ បន្ទាប់មកទៀត មានសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានមួយនៅរាជធានីភ្នំពេញ លើប្រធានបទ "ការជួយសម្រួលការចែករំលែកចំណេះដឹង អំពីការវាយតម្លៃលើការប្រែប្រួលអាកាសធាតុ និងការបន្សាំនៅអាងទន្លេសាប"។ ព្រឹត្តិការណ៍ចុងក្រោយ គឺកិច្ចប្រជុំពិគ្រោះយោបល់មួយ ជាមួយដៃគូអនុវត្តគម្រោង ដែលរៀបចំឡើងក្នុងខេត្តកំពត ដើម្បីជាសំខាន់ធ្វើការកែសម្រួលសំណើស្រាវជ្រាវចំនួនបី សម្រាប់បញ្ជូនទៅម្ចាស់ជំនួយនៅថ្ងៃក្រោយ។ ព្រឹត្តិការណ៍ជាបន្តបន្ទាប់ទាំងនេះ បានបញ្ចប់ទៅជាមួយនឹងដំណើរទស្សនកិច្ចរបស់បណ្ឌិត Jean Lebel

ប្រធាន IDRC មកកាន់ CDRI ដើម្បីពិភាក្សាពីការអនុវត្តគម្រោងនានារបស់ IDRC ដោយវិទ្យាស្ថាន CDRI នៅកម្ពុជា។

ការវាយតម្លៃចុងគ្រានៃគម្រោង ការជំរុញជីវភាពធន់នឹងការប្រែប្រួលអាកាសធាតុ សម្រាប់កសិករខ្នាតតូចនៅតំបន់ដីស្ងួតងាយរងគ្រោះបំផុត ក្នុងខេត្តសៀមរាប និងកំពង់ចាម ដែល អង្គការភ្លែនអន្តរជាតិកម្ពុជា បានចុះកិច្ចសន្យាឲ្យអនុវត្ត ក៏បានចប់សព្វគ្រប់ដែរ ហើយរបាយការណ៍សម្រេចម្ចាស់ជំនួយក៏បានទទួលយកដោយពេញចិត្ត។ សម្រាប់គម្រោងទទួលមូលនិធិពី Sida សំដៅពិនិត្យរកវិធីកែលំអការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ ដើម្បីថែរក្សា ឬពង្រីកការរួមចំណែករបស់វាក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀង ខាងក្រុមស្រាវជ្រាវកំពុងចងក្រងបង្ហើយរបាយការណ៍ ដោយផ្អែកលើមតិរបស់ អ្នកស្រាវជ្រាវក្នុងជំនាញពាក់ព័ន្ធ ដែលបានជួយពិនិត្យឡើងវិញ។

សំណើស្រាវជ្រាវស្តីពី "បញ្ហាយេនឌ័រក្នុងការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាននៅកម្ពុជា" ដែលបានដាក់ជូនទៅដល់ គម្រោងភាពជាដៃគូតំបន់មេគង្គ ដើម្បីបរិស្ថាន (Mekong Partnership for the Environment) បានទទួលជោគជ័យ និងកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃ ការសម្រេចផ្តល់មូលនិធិស្រាវជ្រាវ។

## ផ្នែកអភិបាលកិច្ច

ក្រុមស្រាវជ្រាវ បាននិងកំពុងអនុវត្តការសិក្សាដល់កន្លែង និង ធ្វើទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធថ្នាក់ក្រោមជាតិសំខាន់ៗ សម្រាប់ការសិក្សាស្តីពី សមត្ថភាពសម្រាប់ធ្វើកំណែទម្រង់វិសហមជ្ឈការនៅកម្ពុជា និងការស្រាវជ្រាវ ជំរុញសកម្មភាពមានការចូលរួម ដើម្បីមានអភិបាលកិច្ចទឹកល្អនៅតំបន់មេគង្គ។ ក្រុមស្រាវជ្រាវផ្នែកអភិបាលកិច្ច ក៏បានរៀបចំសិក្ខាសាលាវេទិកាអ្នកពាក់ព័ន្ធចម្រុះលើកដំបូង លើប្រធានបទ "អភិបាលកិច្ចទឹកនៅកម្ពុជា" កាលពីខែមករា នៅសណ្ឋាគារភ្នំពេញ។ សិក្ខាសាលានេះ បានប្រមូលផ្តុំ អ្នកតំណាង ៣១រូប មកពីស្ថាប័នរដ្ឋនៅគ្រប់កម្រិត NGOs ជាតិ និងអន្តរជាតិ ក្រុមហ៊ុនឯកជន និងសហគមន៍ដែលរងផលប៉ះពាល់ពី គម្រោងកសាងទំនប់វារីអគ្គិសនីសេសានក្រោម ២។ សិក្ខាសាលានេះ ផ្តល់ឱកាសឲ្យអ្នកចូលរួមចែករំលែកចំណេះដឹង និងពិភាក្សាយ៉ាងផុលផុសពីបញ្ហាប្រឈមនៃអភិបាលកិច្ចទឹកល្អ ដើម្បីឲ្យការយល់ឃើញនៃសហគមន៍រងផលប៉ះពាល់ពីគម្រោង ជាពិសេសយោបល់របស់ប្រជាជនក្រីក្រទាំងប្រុសទាំងស្រី បានជ្រួតជ្រាបដល់ និងមានឥទ្ធិពលលើដំណើរការសម្រេចចិត្តខាងគោលនយោបាយ ហើយអាចសម្រេចបានលទ្ធផលជាការអភិវឌ្ឍមានសមធម៌ ចីរភាព និងសម្រាប់គ្រប់គ្នា។ នៅខែមីនា ក្រុមស្រាវជ្រាវ ដោយរួមសហការជាមួយ សាកលវិទ្យាល័យជាតិសិង្ហបុរី និងវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (ដៃគូអនុវត្តគម្រោង) បានរៀបចំ ទិវាបណ្តុះបណ្តាលលើកទី២ ស្តីពី ជំនាញចរចាសម្រាប់អ្នកតំណាងមកពីសហគមន៍រងផលប៉ះពាល់ និង NGOs ដែលចូលរួមជួយការពារផលប្រយោជន៍សហគមន៍មូលដ្ឋាន ទាក់ទងនឹងការសាងសង់ និងប្រតិបត្តិការទំនប់វារីអគ្គិសនី។

## Cambodia Development Review—2016 Subscription Rates

**Domestic subscription (individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........................................................................

**Domestic subscription (discount price for bulk orders—five copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........................................................................

**International subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒Other ..........................................................................

First name: .................................... Last name: .................................... Position: ....................................

Organisation / Company: ..........................................................................

Address (CCC Box if applicable): ..........................................................................

City / Province: .................................... Country: ....................................

Telephone: .................................... Fax: ....................................

e-mail: .................................... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Unit at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

**ថ្ងៃទី៤ មករា៖** នាយកប្រតិបត្តិវិទ្យាស្ថាន CDRI បានជួបសំណេះសំណាលជាមួយ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំមតិអំពី ទិសដៅសម្រាប់ការសិក្សាស្រាវជ្រាវពីគោលនយោបាយដើម្បីសកម្មភាព ដែលអាចចូលរួមចំណែកបានច្រើនក្នុងការអភិវឌ្ឍ និងកែលំអឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅពេលជួបសំណេះសំណាលនោះ ក៏មានវត្តមានមន្ត្រីជាន់ខ្ពស់ផ្នែកគោលនយោបាយឧត្តមសិក្សាជាច្រើនរូបផងដែរ។

**ថ្ងៃទី៥-៦ មករា៖** នាយកប្រតិបត្តិ CDRI បានអញ្ជើញចូលរួម និងថ្លែងសុន្ទរកថាគន្លឹះ លើប្រធានបទ "ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា" នៅក្នុងសន្និសីទស្តីពី ការកសាងវប្បធម៌ស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនៅកម្ពុជា ដែលរៀបចំឡើងដោយ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ថ្ងៃទី២០ មករា៖** នាយកប្រតិបត្តិ CDRI បានទទួលការអញ្ជើញ និងទៅចូលរួមក្នុងការបង្កើត "ក្រុមសីលធម៌អប្សរា" សម្រាប់អ្នកសិក្សាស្រាវជ្រាវពី ប្រវត្តិសាស្ត្រវប្បធម៌អង្គរ នៅឯទីស្នាក់ការកណ្តាលនៃអាជ្ញាធរអប្សរា ក្នុងខេត្តសៀមរាប។ សកម្មភាពនេះ ជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់អាជ្ញាធរអប្សរា ដើម្បីកសាងជំនាញ និងសមត្ថភាពស្រាវជ្រាវក្នុងស្ថាប័ន ។

**ថ្ងៃទី៥-៦ កុម្ភៈ៖** កិច្ចប្រជុំពិគ្រោះយោបល់ផ្នែកអប់រំមួយលើ "ការស្រាវជ្រាវពីគោលនយោបាយដើម្បីសកម្មភាព សម្រាប់ឧត្តមសិក្សានៅកម្ពុជា" បានប្រព្រឹត្តទៅនៅ គិរីរម្យ។ កិច្ចប្រជុំនេះ សំដៅជំរុញនូវកិច្ចសន្ទនាយ៉ាងសកម្ម ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗនឹងផ្នែកអប់រំ និងទទួលបានមតិយោបល់ផ្សេងៗ សម្រាប់ញ៉ាំងឲ្យសកម្មភាពស្រាវជ្រាវទាំងឡាយ ដូចមានស្នើឡើងនៅក្នុងគម្រោងទទួលបានមូលនិធិពី ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT) មានភាពពាក់ព័ន្ធល្អ។ ក្នុងកិច្ចប្រជុំនេះ មានការចូលរួមពីតំណាងមកពី ក្រសួងអប់រំ យុវជននិងកីឡា សាកលវិទ្យាល័យរដ្ឋ និងឯកជន វិស័យឯកជន និងអ្នកសិក្សាស្រាវជ្រាវផ្នែកឧត្តមសិក្សា។

**ថ្ងៃទី១០ កុម្ភៈ៖** នាយកប្រតិបត្តិ CDRI បានអញ្ជើញចូលរួម និងថ្លែងសុន្ទរកថាស្តីពី "ការសិក្សាពេញមួយជីវិត" នៅក្នុងវេទិកា "ការពិចារណាជ្រៅជ្រះអំពី ផែនទីបង្ហាញផ្លូវ សម្រាប់សកម្មភាពការអប់រំនៅកម្ពុជាឆ្នាំ២០៣០" ដែលរៀបចំឡើងដោយក្រសួងអប់រំ នៅរាជធានីភ្នំពេញ។ វេទិកានេះ ជាឱកាសល្អមួយសម្រាប់ឲ្យនាយកប្រតិបត្តិ CDRI កសាងទំនាក់ទំនងជាមួយមន្ត្រីជាន់ខ្ពស់មកពីក្រសួងអប់រំ និងគ្រូបង្រៀនមកពីខេត្តនានា និងចែករំលែកគំនិតស្តីពី វិធីជំរុញសិស្ស និងគ្រូបង្រៀន ឲ្យក្លាយជាអ្នករៀនសូត្រពេញមួយជីវិត ស្របតាម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទី៤៖ ធានានូវការអប់រំមានគុណភាពសម្រាប់គ្រប់គ្នា និងជំរុញការរៀនសូត្រពេញមួយជីវិត។

**ថ្ងៃទី១៩ កុម្ភៈ៖** បណ្ឌិត Susan Stone នាយកផ្នែកពាណិជ្ជកម្ម វិនិយោគ និងការបង្កើតថ្មីនៃ គណៈកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (ESCAP) បានមកធ្វើទស្សនកិច្ចនៅ CDRI ដើម្បីផ្លាស់ប្តូរមតិយោបល់ជាមួយលោកនាយកប្រតិបត្តិស្តីពី តួនាទីនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការបង្កើតថ្មី ក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងការសម្រេចបាននូវ SDGs ។

**ថ្ងៃទី៤ មីនា៖** អ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកស្រាវជ្រាវ បានចូលរួមក្នុង ពិធីជប់លៀងកសាងបណ្តាញទំនាក់ទំនងមួយរៀបចំឡើងដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា ក្នុងឱកាសទស្សនកិច្ចនៅរាជធានីភ្នំពេញ របស់លោក Jean Lebel ប្រធាន IDRC និង លោកស្រី Joanne Charette អនុប្រធាន IDRC ហើយបានឆ្លៀតពន្យល់ត្រួសៗប្រាប់លោក Lebel និង គណៈប្រតិភូ អំពីសកម្មភាពជារួមរបស់ CDRI កម្មវិធីនិងគម្រោងទទួលបានជំនួយទ្រទ្រង់ពី IDRC និងលទ្ធផលជាវិជ្ជមាននៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (DRF)។ CDRI ក៏បានរៀបចំសម្ភាសន៍មួយជាមួយស្ថានីយទូរទស្សន៍ CNC សម្រាប់លោក Lebel ដើម្បីពិភាក្សាពីប្រធានបទផ្សេងៗទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចនៅកម្ពុជា និងតួនាទីរបស់ IDRC ក្នុងការជំរុញ

*តទៅទំព័រ ១៧*

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី២០ លេខ១ ខែមីនា ឆ្នាំ២០១៦

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសម្រួល: យូ សិទ្ធិរិទ្ធ
កែសម្រួលផលិតកម្ម: អ៊ុំ ចាន់ថា ខេង សេង និង ម៉េន ច័ន្ទធីតា
សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh